**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


៙៙៙✻៚៚៚

# សារណាបញ្ចប់ការសិក្សា

# ដំណើរការនៃការអភិវឌ្ឍដំណាំកសិកម្មដំណាំមៀនប៉ៃលិន (តាំប៉ែន) នៅក្នុងខេត្តបាត់ដំបង ករណីសិក្សាចម្ការ លោក ហ៊ាប សុភា

ស្រាវជ្រាវ ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **មាស កន្និដ្ឋា**

និស្សិតឈ្មោះ កញ្ញា **ហេង ណាកី**

ណែនាំដោយ

សាស្ត្រាចារ្យរងបណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរបាយការណ៍ ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **មាស កន្និដ្ឋា** និង **ហេង លាតី** ជានិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី ៤ ជំនាន់ទី ៨ នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ តាមរយៈការណែនាំ និងផ្តល់យោបល់ជាច្រើនដែលជួយឱ្យរបាយការណ៍បញ្ចប់ការសិក្សារបស់ពួកយើងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។

## សូមសម្តែងការគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

លោកឪពុក អ្នកម្តាយរបស់យើងខ្ញុំដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តីប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន។ លោកជាព្រះព្រហ្មរបស់កូន ជាគ្រូរបស់កូន ជាពេទ្យរបស់កូន ជា អ្នកចាំជួយលើកទឹកចិត្តដល់កូនគ្រប់ពេលវេលា។ ដើម្បីឱ្យកូនបានចេះដឹងបានបញ្ជូនកូនឱ្យទៅរៀននៅសាលា រៀនតាំងពីថ្នាក់កុមារដ្ឋាន បន្តរហូតមកដល់ថ្នាក់ឧត្តមសិក្សា។ គុណនូបការៈលោកដ៏ធំធេងនេះ ពិតជាមិន អាចយកអ្វីមកប្រៀបផ្ទឹមបានឡើយ។

ឯកឧត្តមសាកលវិទ្យាការ លោក លោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យសិក្សា និងបណ្ឌិតសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយកម្លាំងចិត្តក្នុងការអប់រំបង្ហាត់បង្រៀន និងបាន ផ្តល់ចំណេះដឹងដល់យើងខ្ញុំ ព្រមទាំងនិស្សិតដទៃទៀតតាំងពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់ សាស្ត្រាចារ្យរងបណ្ឌិត **ឈុន ពហុ** ដែលជាសាស្ត្រចារ្យណែនាំ ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ បង្ហាត់បង្រៀន និង ដឹកនាំ ត្រួតពិនិត្យ កែតម្រូវ ដល់ក្រុមយើងខ្ញុំ ព្រមទាំងបញ្ចេញគំនិតសម្រាប់ការច្នៃប្រឌិតបន្ថែមទៀតក្នុងកិច្ចការស្រាវជ្រាវនេះចាប់តាំងពីដំណើរការចាប់ផ្តើមរហូត ដល់របាយការណ៍មួយចងក្រងប្រកបដោយជោគជ័យ។

សូមថ្លែងអំណរគុណទៅដល់លោក **ហ៊ាប សុភា** ជាម្ចាស់ចម្ការមៀនប៉ៃលិន (តាង៉ែន) នៅក្នុងខេត្តបាត់ដំបង ដែលបានចំណាយពេលវេលាដ៏មានតម្លៃដល់ពួកយើងខ្ញុំក្នុងការធ្វើបទសម្ភាសន៍ និងបានផ្តល់ជាព័ត៌មានលម្អិតពាក់ព័ន្ធទៅនឹងដំណើរការនៃការអភិវឌ្ឍមៀនប៉ៃលិន (តាង៉ែន) នៅក្នុងខេត្តបាត់ដំបង។

ជាចុងក្រោយយើងខ្ញុំសូមគោរពជូនពរដល់អ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាការ សាកលវិទ្យាការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ ព្រមទាំងមិត្តនិស្សិតគ្រប់រូប សូមទទួលបាននូវ សេចក្តីសុខ សុខភាពបរិបូរណ៍ ទទួលជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

និស្សិតគ្រប់រូបដែលបានសិក្សាថ្នាក់បរិញ្ញាបត្ររយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបញ្ចប់ការសិក្សារបស់ខ្លួនតាមរយៈការប្រឡង ឬការសរសេរសារណា ឬអាចបញ្ចប់ដោយជ្រើសរើសយកការសរសេររបាយការណ៍ចុះកម្មសិក្សាទៅតាមជំនាញដែលខ្លួនបានសិក្សាមក។ ចំពោះក្រុមយើងខ្ញុំបានសម្រេចជ្រើសរើសសរសេរសារណា ទាក់ទងទៅនឹងចម្ការនៅក្នុងខេត្តបាត់ដំបង ដែលទាក់ទងនឹងប្រធានបទ "**ដំណើរការនៃការអភិវឌ្ឍដំណាំកសិកម្មដំណាំមៀនប៉ៃលិន (តាង៉ែន) នៅក្នុងខេត្តបាត់ដំបង ករណីសិក្សាចម្ការ លោក ហ៊ាប សុភា**" តាមរយៈពេលដែលសាលាបានកំណត់។

ការសិក្សាស្រាវជ្រាវនេះ គឺចង់ផ្តោតទៅលើការសិក្សាពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃការដាំដុះដំណាំមៀនប៉ៃលិន ដោយស្វែងយល់ពីយុទ្ធសាស្ត្រដាំដំណាំពិសេសដែលកសិករប្រើប្រាស់ និងផលប៉ះពាល់នៃកត្តាខាងក្រៅ ដូចជាការប្រែប្រួលទីផ្សារ និងជំងឺរាតត្បាតកូវីដ-១៩ ជាដើម។ តាមរយៈករណីសិក្សានេះ ក្រុមយើងខ្ញុំមានគោលបំណងចូលរួមចំណែកនូវការយល់ដឹងដ៏មានតម្លៃទៅក្នុងការអនុវត្តកសិកម្មដ៏ទូលំទូលាយនៅក្នុងតំបន់ ដោយផ្តល់នូវការយល់ដឹងយ៉ាងច្បាស់លាស់អំពីរបៀបដែលកត្តាសេដ្ឋកិច្ច សង្គម និងបរិស្ថានមានអន្តរកម្មក្នុងការបង្កើតលទ្ធផលនៃបណ្តាក់ទុនកសិកម្ម។

បើទោះបីជារបាយការណ៍មួយនេះបានលេចចេញជារូបរាងហើយក្តី តែក្រុមយើងខ្ញុំជឿជាក់ថាសារណាមួយនេះនឹងមាននូវចំណុចខ្វះខាតខ្លះជាក់ជាមិនខាន។ តែវាអាចជាឯកសារសិក្សាពិគ្រោះរបស់មិត្តនិស្សិតដែលចង់ស្វែងយល់ពីខេត្តបាត់ដំបង ជាពិសេសនោះគឺវិស័យកសិកម្មលើដំណាំមៀនប៉ៃលិន ឬតាង៉ែននេះផងដែរ។ វាអាចជាទុនសម្រាប់ពង្រីកចំណេះដឹងរបស់និស្សិតផ្ទាល់ខ្លួន ឬជាឯកសារយោងសម្រាប់អ្នកស្រាវជ្រាវផងដែរ។

ជាមួយគ្នានេះដែរយើងខ្ញុំទាំងពីររូបសូមអភ័យទោសពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងមិត្តអ្នកអាន និងអ្នកសិក្សាទាំងអស់នូវរាល់ចំណុចខ្វះខាតទាំងខ្លឹមសារ អត្ថន័យ និងអក្ខរាវិរុទ្ធ មិនត្រឹមត្រូវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ។

ជាចុងក្រោយនេះក្រុមយើងខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រ និងការណែនាំដ៏មានតម្លៃពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកទាំងអស់ដែលបានចូលរួមចំណែកក្នុងការរៀបចំសារណានេះ។ ក្រុមយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍ស្រាវជ្រាវនេះនឹងអាចបម្រើជាធនធានដ៏មានប្រយោជន៍សម្រាប់ការស្រាវជ្រាវនាពេលអនាគត និងជាឧបករណ៍សម្រាប់ អ្នកបង្កើតគោលនយោបាយ កសិករ និងសហគ្រិន ដើម្បីកែលម្អនិរន្តរភាព និងប្រាក់ចំណេញនៃវិស័យកសិកម្មរបស់កម្ពុជា។

# មាតិកា

**ទំព័រ**


បញ្ជីអក្សរកាត់ ..................................................................................... vii

បញ្ជីតារាង ..................................................................................... viii

បញ្ជីក្រាហ្វិក ..................................................................................... ix

បញ្ជីឧបសម្ព័ន្ធ ..................................................................................... x


## សេចក្ដីផ្ដើម


១. លំនាំបញ្ហា ..................................................................................... ១

២. ចំណោទបញ្ហា ..................................................................................... ១

៣. គោលបំណងនៃការស្រាវជ្រាវ ..................................................................................... ២

៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ..................................................................................... ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ..................................................................................... ៣

  ៥.១. វិធីសាស្ត្រប្រមូលទិន្នន័យ ..................................................................................... ៣

    ៥.១.១. ទិន្នន័យចម្បង (Primary Data) ..................................................................................... ៣

    ៥.១.២. ទិន្នន័យបន្ទាប់បន្សំ (Secondary Data) ..................................................................................... ៣

  ៥.២. វិធីសាស្ត្រវិភាគទិន្នន័យ ..................................................................................... ៤

៦. សារៈសំខាន់នៃការស្រាវជ្រាវ ..................................................................................... ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..................................................................................... ៥


## ជំពូកទី ១
## ការសិក្សាទៅលើទ្រឹស្ដី


១.១. ការសិក្សាលើនិយមន័យ និងទ្រឹស្ដីនៃពាក្យគន្លឹះ ..................................................................................... ៧

  ១.១.១. ដំណាំកសិកម្ម ..................................................................................... ៧

  ១.១.២. ដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន ..................................................................................... ៧

១.២. ទ្រឹស្ដីនៃការអភិវឌ្ឍ ..................................................................................... ៨

  ១.២.១. ទ្រឹស្ដីរបស់លោក Walt Whitman Rostow ..................................................................................... ៩

១.២.២. ទ្រឹស្តីរបស់លោក Amartya Sen ........ ៩
១.២.៣. ទ្រឹស្តីរបស់លោក Paul Streeten ........ ១០
១.៣. គោលបំណង និងគោលដៅនៃការអភិវឌ្ឍ ........ ១០
១.៣.១. គោលបំណងនៃការអភិវឌ្ឍ ........ ១០
១.៣.២. គោលដៅនៃកាអភិវឌ្ឍ ........ ១១
១.៣.៣. ការរីកចម្រើន និងចរន្តថ្មីនៃការអភិវឌ្ឍកសិកម្ម ........ ១១
១.៤. ប្រវត្តិរបស់កសិកម្ម ........ ១២
១.៤.១. ដំណាក់កាលមិនទាន់មានកសិកម្ម ........ ១២
១.៤.២. ដំណាក់កាលកសិកម្មបុរាណ ........ ១២
១.៤.៣. ដំណាក់កាលកសិកម្មទំនើប ........ ១២
១.៥. ការសិក្សាពីដំណាំកសិកម្មនៅកសិដ្ឋានបែបលក្ខណៈគ្រួសារ ........ ១៣
១.៥.១. ទ្រឹស្តីកសិកម្មគ្រួសារ ........ ១៤
១.៥.២. ទ្រឹស្តីផលិតកម្មគ្រួសារ ........ ១៤
១.៥.៣. វិធីសាស្ត្រចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ........ ១៥
១.៦. ការសិក្សាអំពីតួនាទីរបស់ដំណាំកសិកម្មនៅកម្ពុជា ........ ១៥
១.៦.១. ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ........ ១៥
១.៦.២. សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........ ១៦
១.៦.៣. ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ........ ១៦
១.៦.៤. និរន្តរភាព និងភាពធន់នឹងបរិស្ថាន ........ ១៦
១.៧. ការសិក្សាអំពីគោលនយោបាយ និងការអភិវឌ្ឍដំណាំកសិកម្មនៅកម្ពុជា ........ ១៧
១.៧.១. កំណើនសេដ្ឋកិច្ច និងការផ្លាស់ប្តូររចនាសម្ព័ន្ធ ........ ១៧
១.៧.២. សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........ ១៧
១.៧.៣. ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ........ ១៨
១.៧.៤. សមាហរណកម្មទីផ្សារ និងពាណិជ្ជកម្ម ........ ១៨
១.៨. ស្ថានភាពប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង ........ ១៨
១.៩. វិស័យដែលមានសក្តានុពលក្នុងខេត្តបាត់ដំបង ........ ២០
១.៩.១. វិស័យកសិកម្ម ........ ២០

១.៩.២. វិស័យឧស្សាហកម្ម ........................................................................................................ ២១
១.៩.៣. វិស័យទេសចរណ៍ ........................................................................................................ ២១
១.៩.៤. វិស័យពាណិជ្ជកម្ម ........................................................................................................ ២១
១.១០. សក្តានុពលនៃដំណាំមៀនប៉ៃលិន ឬតាង៉ែន ........................................................................ ២២
១.១១. ស្ថិតិនៃផ្ទៃដីដាំដុះ និងការប៉ាន់ស្មានបិរមាណផលដំណាំមៀនប៉ៃលិន ........................................ ២៣
១.១២. គោលនយោបាយ និងការគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ដំណាំមៀនប៉ៃលិន .................................. ២៤
១.១២.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ ........................................ ២៤
១.១២.២. ការបង្កើតគម្រោង និងកម្មវិធីជំរុញ ........................................................................ ២៥
១.១២.៣. ការផ្តល់បច្ចេកទេស និងការបណ្តុះបណ្តាល ................................................................ ២៥
១.១២.៤. ការគាំទ្រដើម្បីការនាំចេញ ........................................................................................ ២៦
១.១២.៥. ការសហការជាមួយវិស័យឯកជន .................................................................................. ២៦
១.១២.៦. កម្មវិធីហិរញ្ញប្បទានពិសេស ...................................................................................... ២៦
១.១៣. ទស្សនវិស័យពេលអនាគតសម្រាប់ដំណាំមៀនប៉ៃលិន .......................................................... ២៧
១.១៣.១. ទីផ្សារអន្តរជាតិ ...................................................................................................... ២៧
១.១៣.២. ការប្រែប្រួលអាកាសធាតុ ............................................................................................ ២៧
១.១៣.៣. ការអភិវឌ្ឍបច្ចេកវិទ្យា ............................................................................................ ២៧
១.១៤. ការណែនាំសម្រាប់កសិករ និងរាជរដ្ឋាភិបាល .................................................................... ២៧
១.១៤.១. សម្រាប់កសិករ ........................................................................................................ ២៧
១.១៤.២. សម្រាប់រាជរដ្ឋាភិបាល .............................................................................................. ២៨
១.១៥. ឥទ្ធិពលសង្គមដែលកើតមានអំពីកសិកម្មមៀនប៉ៃលិន .......................................................... ២៨
១.១៥.១. ការងារ និងជីវភាពរស់នៅ .......................................................................................... ២៨
១.១៥.២. ការអភិវឌ្ឍសហគមន៍ .................................................................................................. ២៩
១.១៥.២.១. ស្ថិរភាពសេដ្ឋកិច្ច ................................................................................................ ២៩
១.១៥.២.២. ការអប់រំ និងសុខភាព .............................................................................................. ២៩
១.១៥.៣. ទំនាក់ទំនងវប្បធម៌ និងសង្គម .................................................................................... ៣០
១.១៥.៣.១. ការអភិរក្សប្រពៃណីកសិកម្ម ...................................................................................... ៣០
១.១៥.៣.២. ការរួមរស់ក្នុងសង្គម ................................................................................................ ៣០
១.១៥.៤. បញ្ហាប្រឈម និងបញ្ហាសង្គម ...................................................................................... ៣០

១.១៥.៤.១. លក្ខខណ្ឌការងារ...............................................................................................................៣០
១.១៥.៤.២. ការធ្វើចំណាកស្រុក និងនគរូបនីយកម្ម..................................................................................៣១
១.១៥.៥. ការយល់ដឹងអំពីបរិស្ថាន និងនិរន្តរភាព...................................................................................៣១
១.១៥.៦. ការសហការរវាងកម្ពុជា និងប្រទេសនាំចូល ..............................................................................៣១

## ជំពូកទី ២

## ស្ថានភាពទូទៅនៃដំណាំមៀនប៉ៃលិន ឬតាង៉ែន

២.១. ប្រវត្តិនៃការដាំដុះដំណាំមៀនប៉ៃលិន និងទីតាំងភូមិសាស្ត្រ .......................................................................៣៤
២.១.១. ប្រវត្តិនៃការដាំដុះដំណាំមៀនប៉ៃលិន..........................................................................................៣៤
២.១.២. ទីតាំងភូមិសាស្ត្រ...............................................................................................................៣៥
២.២. ការគ្រប់គ្រង (រចនាសម្ពន្ធ័គ្រប់គ្រងរបស់ចម្ការ)................................................................................៣៦
២.៣. លក្ខណៈពិសេសរបស់ដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន..........................................................................៣៦
២.៤. ការសិក្សាអំពីបច្ចេកទេស និងដំណើការដាំដុះដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន............................ ៣៧
២.៤.១. ការរៀបចំដី និងបច្ចេកទេសគ្រប់គ្រងដី ................................................................................... ៣៧
២.៤.២. វិធីសាស្ត្រដាំ និងដកឃ្លា ...................................................................................................... ៣៧
២.៤.៣. ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក......................................................................................៣៨
២.៤.៤. ការអនុវត្តការបង្កកំណើត......................................................................................................៤០
២.៤.៥. វិធីសាស្ត្រថែទាំ (ការគ្រប់គ្រងសត្វល្អិត និងជំងឺ).............................................................................៤០
២.៤.៥.១. រយៈពេលលាស់ស្លឹកខ្ចី និងបែកមែក................................................................................៤១
២.៤.៥.២. រយៈពេលផ្កា ...............................................................................................................៤១
២.៤.៥.៣. រយៈពេលនៃការកាន់ផ្លែទំហំតូច.......................................................................................៤២
២.៥. បច្ចេកទេសនៃការប្រមូលផល និងក្រោយការប្រមូលផល ......................................................................៤២

## ជំពូកទី ៣

## ការពិភាក្សាទៅលើលទ្ធផលនៃការស្រាវជ្រាវ

៣.១. សមិទ្ធផលនៃការដាំដុះដំណាំផ្លែមៀនប៉ៃលិន ឬផ្លែតាង៉ែន (ទិន្នន័យពីឆ្នាំ២០១៨-២០២៣).............៤៤
៣.១.១. ទិន្នផលនៃដំណាំតាង៉ែន (ឆ្នាំ២០១៨-២០២៣)...........................................................................៤៤

៣.១.២. លិទ្ធផលសម្រេចបាន (ឆ្នាំ២០១៨-២០២៣) ............................................................ ៤៥
៣.១.៣. ប្រសិទ្ធភាពសេដ្ឋកិច្ច (តារាងហិរញ្ញវត្ថុ) ............................................................ ៤៨
៣.២. បញ្ហាប្រឈម ឬ កត្តាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍន៍ដំណាំផ្លែមៀនប៉ៃលិន ............................ ៥៣
៣.២.១. កត្តាអាកាសធាតុ ............................................................ ៥៣
៣.២.២. កត្តាហេដ្ឋារចនាសម្ព័ន្ធ ............................................................ ៥៤
៣.២.២.១. ការផ្គត់ផ្គង់ទឹក ............................................................ ៥៤
៣.២.២.២. ភាពលំបាកក្នុងការដឹកជញ្ជូន ............................................................ ៥៤
៣.២.៣. កត្តាប្រកួតប្រជែង (តម្លៃ និងទីផ្សារ) ............................................................ ៥៤
៣.២.៤. កត្តាបច្ចេកវិទ្យាថ្មី ............................................................ ៥៤
៣.២.៥. កត្តាសេដ្ឋកិច្ច និងសង្គម ............................................................ ៥៥
៣.២.៥.១. បញ្ហាគោលនយោបាយ និងការគាំទ្រពីរដ្ឋាភិបាល ............................................................ ៥៥
៣.២.៥.២. បញ្ហាវិបត្តិសកល ............................................................ ៥៥
៣.២.៥.៣. បញ្ហាតម្រូវការទីផ្សារ និងភាពមិនស្ថិតស្ថេររបស់ទីផ្សារ ............................................................ ៥៦
៣.៣. ដំណោះស្រាយទៅលើកត្តាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍដំណាំផ្លែមៀនប៉ៃលិន ............................ ៥៦
៣.៣.១. កត្តាអាកាសធាតុ ............................................................ ៥៦
៣.៣.២. កត្តាហេដ្ឋារចនាសម្ព័ន្ធ ............................................................ ៥៦
៣.៣.២.១. ការផ្គត់ផ្គង់ទឹក ............................................................ ៥៦
៣.៣.២.២. ភាពលំបាកក្នុងការដឹកជញ្ជូន ............................................................ ៥៧
៣.៣.៣. កត្តាប្រកួតប្រជែង (តម្លៃ និងទីផ្សារ) ............................................................ ៥៧
៣.៣.៤. កត្តាបច្ចេកវិទ្យាថ្មី ............................................................ ៥៧
៣.៣.៥. កត្តាសេដ្ឋកិច្ច និងសង្គម ............................................................ ៥៧
៣.៣.៥.១. បញ្ហាគោលនយោបាយ និងការគាំទ្រពីរដ្ឋាភិបាល ............................................................ ៥៧
៣.២.៥.២. បញ្ហាវិបត្តិសកល ............................................................ ៥៨
៣.២.៥.៣. បញ្ហាតម្រូវការទីផ្សារ និងភាពមិនស្ថិតស្ថេររបស់ទីផ្សារ ............................................................ ៥៨
៣.៤. ការវិភាគ SWOT ............................................................ ៥៨
៣.៤.១. ការវិភាគទៅលើភាពខ្លាំង (Strengths) ............................................................ ៥៩
៣.៤.២. ការវិភាគទៅលើភាពខ្សោយ (Weaknesses) ............................................................ ៥៩

៣.៤.៣. ការវិភាគទៅលើឱកាស (Opportunities) ..... ៥៩
៣.៤.៤. ការវិភាគទៅលើហានិភ័យ (Threats) ..... ៥៩
៣.៥. ការជ្រៀបចូលក្នុងទីផ្សារនិងបណ្ដាញចែកចាយរបស់មៀនប៉ៃលិន ..... ៦០
៣.៥.១. ទិដ្ឋភាពទូទៅនៃទីផ្សារសម្រាប់មៀនប៉ៃលិន ..... ៦០
៣.៥.២. ការជ្រៀបចូលទីផ្សារ (Market Entry) ..... ៦០
៣.៥.៣. បណ្ដាញចែកចាយ (Distribution Network) ..... ៦០

## សេចក្ដីសន្និដ្ឋាន និង ការផ្ដល់អនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ..... ៦២
២. ការផ្ដល់អនុសាសន៍ ..... ៦៣
២.១. ការប្រើប្រាស់បច្ចេកវិទ្យាថ្មីសម្រាប់គ្រប់គ្រងអាកាសធាតុ ..... ៦៣
២.២. ការវិនិយោគក្នុងការជួសជុល និងការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ..... ៦៣
២.៣. ការបង្រៀន និងបណ្ដុះបណ្ដាលបុគ្គល (កម្មករ) ..... ៦៣
២.៤. ការបង្កើតផែនការគ្រប់គ្រងស្តុក និងការប្រកួតប្រជែង ..... ៦៤
២.៥. ការអភិវឌ្ឍយុទ្ធសាស្រ្តផ្សព្វផ្សាយ និងការអភិវឌ្ឍទីផ្សារ ..... ៦៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| គ.ម. | ៖ | គីឡូម៉ែត្រ |
| គ.ម$^2$ | ៖ | គីឡូម៉ែត្រការេ |
| គ.ម$^3$ | ៖ | គីឡូម៉ែត្រគីប |
| ស.ម. | ៖ | ខ្នាតប្រវែងគិតជាសង់ទីម៉ែត្រ |
| ADB | ៖ | Asian Development Bank |
| ADI | ៖ | Agricultural Development International |
| AIMS | ៖ | Accelerating Inclusive Markets for Smallholders |
| BMZ | ៖ | Federal Ministry for Economic Cooperation and Development |
| CACC | ៖ | Cambodia Agricultural Cooperative Center |
| CARDI | ៖ | Cambodian Agricultural Research and Development Institute |
| CEDAC | ៖ | Cambodian Center for Study and Development in Agriculture |
| CWCDD | ៖ | Cambodian Women´s Development Agency |
| FACT | ៖ | Foundation for the Advancement of Community Technologies |
| FAO | ៖ | Food and Agriculture Organization |
| GIZ | ៖ | Deutsche Gesellschaft für Internationale Zusammenarbeit |
| IFAD | ៖ | International Fund for Agricultural Development |
| IPM | ៖ | Integrated Pest Management |
| JICA | ៖ | Japan International Cooperation Agency |
| KE | ៖ | Khmer Enterprise |
| MAFF | ៖ | Ministry of Agriculture, Forestry, and Fisheries |
| NGO | ៖ | Non-Government Organization |
| NH5 | ៖ | National Highway 5 |
| NPK | ៖ | Nitrogen, Phosphorus, and Potassium |
| SRECA | ៖ | Support of Regional Economic Cooperation of Asia |
| SDC | ៖ | Swiss Agency for Development and Cooperation |
| WB/IFC | ៖ | World Bank/International Finance Corporation |

# បញ្ជីតារាង

**ទំព័រ**

តារាងទី ១: រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

តារាងទី ២: ទិន្នន័យប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង (២០០៨-២០១៩) ........ ១៩

តារាងទី ៣: រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ចម្ការ ........ ៣៦

តារាងទី ៤: ទិន្នផលនៃការដាំដុះដំណាំផ្លែមៀនប៉ៃលិន (ទិន្នន័យពីឆ្នាំ២០១៨-២០២៣) ........ ៤៤

តារាងទី ៥: លិទ្ធផលសម្រេចបាន (ឆ្នាំ២០១៨-២០២៣) ........ ៤៦

តារាងទី ៦: ទិន្នផលសរុប និងប្រាក់ចំណូលសរុប (២០១៨-២០២៣) ........ ៤៨

តារាងទី ៧: ថ្លៃដើមក្នុងមួយតោន និងដើមទុនវិនិយោគ (២០១៨-២០២៣) ........ ៤៩

តារាងទី ៨: ប្រាក់ចំណេញសុទ្ធ និងអត្រាប្រាក់ចំណេញសុទ្ធ - Net Profit Margin (២០១៨-២០២៣) .... ៥០

តារាងទី ៩: ប្រាក់ចំណូលក្នុងមួយតោន និងអត្រាផលតបស្នងនៃវិនិយោគ (ROI %) ........ ៥០

# បញ្ជីក្រាហ្វិក

**ទំព័រ**


ក្រាហ្វិកទី ១: អត្រាកំណើនប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង ឆ្នាំ២០០៨ ........................................ ១៩

ក្រាហ្វិកទី ២: អត្រាកំណើនប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង ឆ្នាំ២០១៩ ........................................ ២០

ក្រាហ្វិកទី ៣: ទិន្នផលនៃការដាំដុះដំណាំផ្លែមៀនប៉ៃលិន (ទិន្នន័យពីឆ្នាំ ២០១៨-២០២៣) .................... ៤៥

ក្រាហ្វិកទី ៤: ទិន្នន័យដើមទុនវិនិយោគសរុប (ឆ្នាំ ២០១៨-២០២៣) ................................................ ៤៧

ក្រាហ្វិកទី ៥: ទិន្នន័យប្រាក់ចំណូលសរុប (ឆ្នាំ ២០១៨-២០២៣) .................................................... ៤៧

ក្រាហ្វិកទី ៦: ទិន្នន័យប្រាក់ចំណេញសរុប (ឆ្នាំ ២០១៨-២០២៣) .................................................. ៤៨

ក្រាហ្វិកទី ៧: តម្លៃលក់របស់មៀនប៉ៃលិន គិតជារៀល/គីឡូក្រាម (ឆ្នាំ ២០១៨-២០២៣) ....................... ៤៩

ក្រាហ្វិកទី ៨: អត្រាប្រាក់ចំណេញសុទ្ធ Net Profit Margin (%) ..................................................... ៥២

ក្រាហ្វិកទី ៩: អត្រាផលតបស្នងនៃវិនិយោគ (ROI %) .................................................................. ៥៣

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១: ទីតាំងភូមិសាស្ត្ររបស់ចម្ការ លោក ហ៊ាប សុភា

ឧបសម្ព័ន្ធទី ២: ទិដ្ឋភាពនៃការដាំដកឃ្លា

ឧបសម្ព័ន្ធទី ៣: រយៈពេលផ្កា

ឧបសម្ព័ន្ធទី ៤: ទិដ្ឋភាពនៅក្នុងចម្ការមៀនប៉ៃលិន

ឧបសម្ព័ន្ធទី ៥: រូបភាពនៅក្នុងចម្កាមៀនប៉ៃលិន

ឧបសម្ព័ន្ធទី ៦: រូបភាពជាមួយនឹងម្ចាស់ចម្ការ លោក ហ៊ាប សុភា

ឧបសម្ព័ន្ធទី ៧: កិច្ចសម្ភាសន៍ជាមួយនឹងម្ចាស់ចម្ការ លោក ហ៊ាប សុភា

ឧបសម្ព័ន្ធទី ៨: ផ្នែកផ្សេងៗនៃដំណាំមៀនប៉ៃលិន

ឧបសម្ព័ន្ធទី ៩: ប្រភពទឹករបស់ចម្ការ លោក ហ៊ាប សុភា

ឧបសម្ព័ន្ធទី ១០: ជី និងថ្នាំសម្រាប់ដំណាំមៀនប៉ៃលិន

ឧបសម្ព័ន្ធទី ១១: រូបភាពសត្វល្អិតដែលបំផ្លាញដំណាំមៀនប៉ៃលិន

ឧបសម្ព័ន្ធទី ១២: រូបភាពម៉ាស៊ីនបូមទឹករបស់ចម្ការ

ឧបសម្ព័ន្ធទី ១៣: រូបភាពពេលប្រមូលផលមៀនប៉ៃលិន

# សេចក្តីផ្តើម

ដំណើរការនៃការអភិវឌ្ឍដំណាំកសិកម្ម គឺជាប្រភេទនៃការអភិវឌ្ឍសំខាន់មួយសម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចផ្អែកលើកសិកម្មដូចប្រទេសកម្ពុជាជាដើម។ ក្នុងប្រទេសកម្ពុជា ការវិវត្តនៃការដាំដំណាំកសិកម្មបានរីកចម្រើនយ៉ាងខ្លាំង នៅក្នុងជួសជុលស្ថាប័នកសិកម្ម និងបច្ចេកវិទ្យា ដែលបានជួយពង្រឹងស្ថានភាពសេដ្ឋកិច្ច និងកែលម្អជីវភាពរបស់កសិករ។ ក្នុងចំណោមដំណាំកសិកម្មមួយចំនួន ដំណាំមៀនប៉ៃលិន (តាង៉ែន) ជាដំណាំដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់បំផុតក្នុងការកសាងសហគមន៍នៅក្នុងខេត្តបាត់ដំបង។

របាយការណ៍នៃការស្រាវជ្រាវនេះ គឺជាការសិក្សាអំពីដំណើរការនៃការអភិវឌ្ឍដំណាំមៀនប៉ៃលិន ក្នុងករណីសិក្សាចម្ការ លោក ហ៊ាប សុភា ដែលជាកសិករ និងជាម្ចាស់ចម្ការដែលបានចូលរួមដំណើរការនៃការដាំដុះ និងពង្រីកផលិតកម្ម ដោយប្រើប្រាស់បច្ចេកទេស និងវិធីសាស្ត្រនានា។ សិក្សានេះនឹងផ្តល់នូវការឆ្លុះបញ្ចាំងអំពីការកែសម្រួលក្នុងវិស័យកសិកម្ម និងបញ្ហាប្រឈមដែលកសិករដំណាំមៀនប៉ៃលិនបានជួបប្រទះ អមដោយការវិភាគផែនការសម្រាប់ការអភិវឌ្ឍនាពេលអនាគត។

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

វិស័យកសិកម្ម គឺជាវិស័យមួយដែលបានដើរតួនាទីយ៉ាងសំខាន់ដែលបានជួយដល់ការជំរុញសេដ្ឋកិច្ចជាតិនៅក្នុងប្រទេសកម្ពុជា ដោយប្រជាពលរដ្ឋខ្មែរបានចាត់ទុកវិស័យនេះ ជាវិស័យអាទិភាពក្នុងការអភិវឌ្ឍទាំងសេដ្ឋកិច្ចគ្រួសារ និងប្រទេសជាតិ។ ក្នុងនោះផងដែលការនិយមធ្វើកសិកម្មមានតាំងពីយូរលង់ណាស់មកហើយ ព្រោះតែការអំណោយផលនៃផ្ទៃដី ដោយការដាំដុះមានលក្ខណៈខុសៗគ្នាទៅតាមប្រភេទដីនីមួយៗ។ តួយ៉ាងការដាំដុះដំណាំមៀនប៉ៃលិន ឬតាង៉ែន ដែលប្រជាជននៅខេត្តបាត់ដំបងនិយមក្នុងការដាំដុះបានក្លាយជាចំណែកមួយដែលនាំអោយជីវភាពក៏ដូចជាសេដ្ឋកិច្ចប្រជាជននៅតំបន់នោះមានការល្អប្រសើរ ក្នុងនោះយើងឃើញថាការដាំដុះក៏មានគុណសម្បត្តិ និងគុណវិបត្តិមួយចំនួនផងដែលដែលនាំឱ្យមានជាបញ្ហា និងដំណោះស្រាយផ្សេងៗ។ ការដាំដុះមៀនប៉ៃលិននៅខេត្តបាត់ដំបង បើទោះបីជាមានសក្តានុពលខ្ពស់ក្នុងការជំរុញសេដ្ឋកិច្ចក៏ដោយ ក៏មានបញ្ហាប្រឈមជាច្រើនដែលកំពុងរារាំងការអភិវឌ្ឍរបស់វា ដែលបញ្ហាទាំងនេះបានក្លាយជាបញ្ហាចោទសម្រាប់ប្រជាកសិករកម្ពុជា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែការដាំដុះដំណាំមៀនប៉ៃលិន ឬតាង៉ែន ជាផ្នែកមួយនៃសេដ្ឋកិច្ចដែលនាំឱ្យជីវភាពប្រជាកសិករដែលបានដាំដុះមានលក្ខណៈល្អប្រសើរឡើង តែក៏មានបញ្ហាមួយចំនួនដែលបានកើតឡើងដែលប៉ះពាល់

ដល់ការប្រមូលផលដែលនាំឱ្យចំណូលធ្លាក់ចុះក្នុងនោះរួមមាន៖

- បញ្ហាអាកាសធាតុជាបញ្ហាចម្បងដែលគ្មានអ្វីអាចទប់ស្កាត់បាន
- ការខ្វះខាតដើមទុនទុនបម្រុង, ការខ្វះខាតបច្ចេកទេសក្នុងការដាំដុះមួយចំនួន
- ការប្រកួតប្រជែងក្នុងទីផ្សារព្រមទាំងបញ្ហាបន្ទាប់បន្សំជាច្រើនដែលនាំឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការប្រកួតប្រជែងទីផ្សារ ព្រមទាំងបញ្ហាជាច្រើនទៀតដែលនាំអោយប៉ះពាល់ខ្លាំងដល់ការប្រមូលផល និងព្រមទាំងទិន្នផលដែលប្រមូលបាន។

ចំណោទបញ្ហាដែលចោទសួរនៅក្នុងការស្រាវជ្រាវនេះ គឺថាតើប្រជាកសិករគួរដោះស្រាយបែបណានៅពេលដែលមានបញ្ហាប្រឈមផ្សេងៗទៅលើដំណាំមៀនប៉ៃលិននេះ? តើមានកត្តាអ្វីខ្លះដែលអាចធ្វើឱ្យការដាំដុះមានការកើនឡើង ឬការធ្លាក់ចុះនៅក្នុងតម្លៃទីផ្សារ និងផលចំណេញសេដ្ឋកិច្ច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការតាក់តែងសារណានេះ គឺធ្វើឡើងក្នុងគោលបំណងបង្ហាញពីទំហំនៃដំណាំកសិកម្មជាពិសេសដំណាំមៀនប៉ៃលិន ឬតាង៉ែន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមិនថាលក្ខណៈគ្រួសារ និងសេដ្ឋកិច្ចជាតិ ព្រមទាំងរបៀបនៃការដាំដុះ និងបច្ចេកទេសមួយចំនួនដែលអាចកែប្រែ និងបង្ការទប់ស្កាត់ទៅលើបញ្ហាដែលកើតឡើង និងបម្រុងនឹងកើតទៅលើដំណាំនេះផងដែរ ។ មិនតែប៉ុណ្ណោះ គឺដើម្បីបង្ហាញ និងវិភាគអំពីការអភិវឌ្ឍនៃការដាំដុះដំណាំមៀនប៉ៃលិន ឬតាង៉ែននេះ នៅក្នុងខេត្តបាត់ដំបង។ យើងចង់សិក្សាអំពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃយុទ្ធសាស្ត្រការដាំដុះ និងវាយតម្លៃនូវការប្រែប្រួលនៃផលិតភាព និងតម្រូវការទីផ្សារ ដោយគិតពីកត្តាបែបផែនផ្សេងៗដែលមានឥទ្ធិពលលើកសិករ និងកំណត់យុទ្ធសាស្ត្រដែលអាចប្រើប្រាស់បានសម្រាប់ការកែលម្អនាពេលអនាគត។

## ៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវនេះមានលក្ខណៈកាន់តែស៊ីជម្រៅ និងវិភាគបានគ្រប់ជ្រុងជ្រោយ វិសាលភាពនៃការស្រាវជ្រាវលើប្រធានបទនេះស្តីអំពី ដំណើរការនៃការអភិវឌ្ឍដំណាំកសិកម្មមៀនប៉ៃលិន (តាង៉ែន) ត្រូវបានផ្តោត និងធ្វើការយកចិត្តយ៉ាងខ្លាំងទៅលើតែករណីសិក្សាទៅលើចម្ការរបស់លោក ហ៊ាប សុភា នៅក្នុងខេត្តបាត់ដំបង ដែលបានបង្ហាញពីការវិភាគលើផលិតភាព តម្រូវការទីផ្សារ តម្លៃទីផ្សារ និងយុទ្ធសាស្ត្រការដាំដុះ។

ដែនកំណត់នៃការស្រាវជ្រាវនេះមានការលើកឡើងទៅលើការសិក្សាដោយកំណត់អំពីការប្រើប្រាស់ធនធាន និងបច្ចេកវិទ្យា ផលវិបាកសេដ្ឋកិច្ចនៃការដាំដុះ និងការប្រកួតប្រជែងនៅក្នុងទីផ្សារ ដោយមិនរាប់បញ្ចូលការពិចារណានៅលើចំណុចផ្សេងៗរបស់កសិករនៅតំបន់ផ្សេងទៀត និងការវិភាគជាក់លាក់លើការប្រតិបត្តិការកសិករផ្សេងៗឡើយ។

# ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៥.១. វិធីសាស្ត្រប្រមូលទិន្នន័យ

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះ យើងបានប្រើប្រាស់ការប្រមូលទិន្នន័យតាមវិធីសាស្ត្រពីរបែបដើម្បីកំណត់វិធីសាស្ត្រស្រាវជ្រាវគឺ វិធីសាស្ត្របែបគុណវិស័យ (Qualitative Method) និងវិធីសាស្ត្របែបបរិមាណ (Quantity Method) ហើយព័ត៌មានដែលយើងប្រមូលមកសរសេរដោយសំអាងលើទិន្នន័យចម្បង (Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data) ហើយទិន្នន័យដែលបានមកពីការសាកសួរ ដោយផ្ទាល់ទៅកាន់ម្ចាស់ចម្ការផ្ទាល់តាមរយៈកម្រងសំណួរ និងប៉ាន់គំរូដែលយើងបានកំណត់ទុក។

ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវនេះប្រកបដោយជោគជ័យ គឺទាមទារនូវតម្រូវការទិន្នន័យជាច្រើន ដែលទទួលបានពីប្រភពចម្បងពីរដែលសម្រួលក្នុងការប្រមូលទិន្នន័យ និងវិភាគឱ្យគ្រប់គ្រាន់គឺ:

### ៥.១.១. ទិន្នន័យចម្បង (Primary Data)

- ការចុះពិនិត្យ / សង្កេតនៅទីតាំងរបស់ចម្ការដោយផ្ទាល់ទៅលើការគ្រប់គ្រង និងការអភិវឌ្ឍក្នុងចម្ការមៀនប៉ៃលិនរបស់ **លោក ហ៊ាប សុភា** នៅខេត្តបាត់ដំបង។
- ការជួបសាកសួរដោយផ្ទាល់ជាមួយនឹងម្ចាស់ចម្ការ **លោក ហ៊ាប សុភា**។
- ការជួបសាកសួរដោយផ្ទាល់ជាមួយនឹងម្ចាស់ចម្ការដទៃទៀតនាតំបន់នោះ។
- ការណែនាំពីសាស្ត្រាចារ្យរង បណ្ឌិត **ឈុន ពហុ** ដែលជាសាស្ត្រាចារ្យដឹកនាំ បានកែតម្រូវ និងផ្តល់មតិយោបល់សម្រាប់ការកែច្នៃ និងការកែលម្អបន្ថែម។

### ៥.១.២. ទិន្នន័យបន្ទាប់បន្សំ (Secondary Data)

- ឯកសារដែលទាក់ទងទៅនឹងប្រធានបទមានដូចជាគោលការណ៍ណែនាំស្តីអំពីការនាំចេញមៀនប៉ៃលិនពីប្រទេសកម្ពុជាទៅប្រទេសចិនដែលត្រូវបានបង្កើតឡើងរួមគ្នាដោយអគ្គនាយកដ្ឋានកសិកម្ម និងគម្រោង "ការគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចថ្នាក់តំបន់នៅតំបន់អាស៊ី" (SRECA) អនុវត្តដោយអង្គការ GIZ តំណាងឱ្យ ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់ កិច្ចប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច (BMZ)។
- ឯកសារដែលទាក់ទងនឹងប្រធានបទដូចជា សៀវភៅណែនាំបច្ចេកដាំដំណាំមៀនប៉ៃលិន។
- ការស្រាវជ្រាវបន្ថែមតាមរយៈរបាយការណ៍របស់ក្រសួងរុក្ខាប្រមាញ់ និង នេសាទ និងក្រសួងពាក់ព័ន្ធ។
- ការស្រាវជ្រាវបន្ថែមតាមរយៈឯកសារព័ត៌មានទាក់ទងនឹងដំណាំមៀនប៉ៃលិន។

- ការស្រាវជ្រាវបន្ថែមតាមរយៈឯកសារបរទេសដែលពាក់ព័ន្ធនឹងដំណាំមៀនប៉ៃលិន និងទ្រឹស្តីផ្សេងៗទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច។
- ការស្រាវជ្រាវបន្ថែមតាមរយៈបណ្ណាល័យ (បណ្ណាល័យកសិកម្ម), សៀវភៅមេរៀន, សារណាដែលជាស្នាដៃរបស់និស្សិតជំនាន់មុន និងឯកសារផ្សេងៗនៅក្នុងបណ្ណាល័យ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### ៥.២. វិធីសាស្ត្រវិភាគទិន្នន័យ

ចំពោះវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ក្នុងការវិភាគលើដំណើរការនៃការអភិវឌ្ឍដំណាំកសិកម្មដំណាំមៀនប៉ៃលិន (ឬតាង៉ែន) នៅក្នុងខេត្តបាត់ដំបង តាមរយៈករណីសិក្សាចម្ការ លោក ហ៊ាប សុភា ត្រូវបានកំណត់ និងអនុវត្តន៍ដោយយកព័ត៌មានដែលទទួលបានពីការសាកសួរម្ចាស់ចម្ការ លោក ហ៊ាប សុភា និងអ្នកភូមិនៅតំបន់នោះមួយចំនួនទៀត ត្រូវបានប្រើប្រាស់ក្នុងការសិក្សា។ ដោយសកម្មភាពមួយចំនួនទទួលបានពីការចុះពិនិត្យទិដ្ឋភាពនៅចម្ការផ្ទាល់ នេះបានអនុញ្ញាតឱ្យយើងធ្វើការវិភាគដោយប្រើប្រាស់ទ្រឹស្តីជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងទូទៅនាពេលបច្ចុប្បន្ន ដើម្បីឈានទៅដល់ការទាញចេញសេចក្តីសន្និដ្ឋានរួមមួយ និងការផ្តល់នូវអនុសាសន៍សម្រាប់ការស្រាវជ្រាវនេះ។ បន្ទាប់ពីប្រមូលបានព័ត៌មាន យើងបានជ្រើសរើសព័ត៌មានដែលមានគុណភាពខ្ពស់មកចងក្រង ដើម្បីធ្វើជារបាយការណ៍។ ការវិភាគបានធ្វើតាមការព្យាករណ៍សម្រាប់ឆ្នាំខាងមុខដោយប្រើកម្មវិធី Excel ជាជំនួយ ក្នុងការផ្តល់នូវភាពសុក្រិត និងបង្ហាញជាតារាងទិន្នន័យ និងក្រាហ្វិកព្យាករណ៍នៅក្នុងឧបសម្ព័ន្ធ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវនេះ មានដូចខាងក្រោម ៖

- ការយល់ដឹងអំពីការអភិវឌ្ឍកសិកម្មអាចជំរុញកំណើនសេដ្ឋកិច្ចដោយការលើកកម្ពស់ផលិតភាព និងកម្រិតប្រាក់ចំណូលសម្រាប់កសិករក្នុងស្រុក។
- ផ្តល់ទិន្នន័យដើម្បីជូនដំណឹង និងកែលម្អគោលនយោបាយ និងកម្មវិធីកសិកម្មដែលស្របតាមតម្រូវការជាក់លាក់នៃដំណាំមៀនប៉ៃលិន។
- ពង្រឹងសន្តិសុខស្បៀងដោយកំណត់វិធីបង្កើនទិន្នផលដំណាំ និងកាត់បន្ថយការពឹងផ្អែកលើប្រភពអាហារខាងក្រៅ។
- ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមទាំងមូល តាមរយៈការលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្រក្នុងចំណោមសហគមន៍កសិកម្ម។

- ជំរុញឱ្យមានការទទួលយកនូវបច្ចេកវិទ្យា និងការអនុវត្តកសិកម្មទំនើប ដែលនាំឱ្យមានការបង្កើនប្រសិទ្ធភាព និងទិន្នផល។
- ផ្តល់ឱកាសអប់រំ និងបណ្តុះបណ្តាលដល់កសិករក្នុងការសិក្សា និងអនុវត្តបច្ចេកទេសកសិកម្មដែលប្រសើរឡើង។
- បង្កើតស្តង់ដារសម្រាប់ការអភិវឌ្ឍកសិកម្ម និងជួយក្នុងការតាមដានវឌ្ឍនភាពតាមពេលវេលា ជួយសម្រួលដល់ការកែលម្អជាបន្តបន្ទាប់។
- ទាក់ទាញការវិនិយោគដោយបង្ហាញពីសក្តានុពលនៃការអភិវឌ្ឍកសិកម្ម និងលទ្ធភាពទទួលបានបរិយាកាសគោលនយោបាយគាំទ្រ។

## ៧. រចនាសម្ព័ន្ធនៃស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះត្រូវបានបែងចែកជា **៥ផ្នែក** ដូចខាងក្រោម៖

- **សេចក្តីផ្តើម ៖** លំនាំបញ្ហា, ចំណោទបញ្ហា, គោលបំណងនៃការស្រាវជ្រាវ, វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ, សារៈសំខាន់នៃការស្រាវជ្រាវ, និងវិធីសាស្ត្រនៃការស្រាវជ្រាវ។
- **ជំពូកទី១ ៖ ការសិក្សាទៅលើទ្រឹស្តី ៖** ការសិក្សា និងរំលឹកទ្រឹស្តីដែលពាក់ព័ន្ធនឹងបច្ចេកទេសនៃការដាំដុះមៀនប៉ៃលិន, រៀបរាប់ពន្យល់អំពីនិយមន័យនៃកសិកម្ម និងការអភិវឌ្ឍ, ទ្រឹស្តីមួយចំនួនរបស់សេដ្ឋវិទូ និងទស្សនៈវិទូអំពីការអភិវឌ្ឍសេដ្ឋកិច្ច, ប្រវត្តិរបស់កសិកម្ម, តួនាទីរបស់កសិកម្ម, គោលនយោបាយ និងការអភិវឌ្ឍដំណាំកសិកម្មនៅកម្ពុជា, ស្ថានភាពប្រជាសាស្ត្រ វិស័យសក្តានុពលនៅក្នុងខេត្ត, សក្តានុពលនៃដំណាំមៀនប៉ៃលិន។ លើសពីនេះទៀតនោះយើងក៏បានធ្វើការសិក្សាស្វែងយល់អំពីបច្ចេកទេសសំខាន់ៗដែលចាំបាច់ទាក់ទងនឹងការដាំដុះមៀនប៉ៃលិន។
- **ជំពូកទី២ ៖ ស្ថានភាពទូទៅនៃដំណាំមៀនប៉ៃលិន ឬតាម៉េង ៖** ការសិក្សាទៅលើលក្ខណៈទូទៅដូចជាប្រវត្តិនៃការដាំដុះ, ទីតាំងភូមិសាស្ត្រ, រចនាសម្ពន្ធ៍គ្រប់គ្រងរបស់ចម្ការ, ការសិក្សាអំពីបច្ចេកទេស និងដំណើរការដាំដុះដំណាំផ្លែមៀនប៉ៃលិន (វិធីសាស្ត្រដាំ និងដកឃ្លា, ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក, ការអនុវត្តការបង្កកំណើត, វិធីសាស្ត្រថែទាំ, បច្ចេកទេសនៃការប្រមូលផល និងក្រោយការប្រមូលផល….)
- **ជំពូកទី៣ ៖ ការវិភាគ និងការពិភាក្សាទៅលើលទ្ធផលនៃការស្រាវជ្រាវ ៖** ក្នុងជំពូកនេះនឹងបង្ហាញពីការសិក្សាដោយធ្វើការរបកស្រាយពីសមិទ្ធផលនៃការដាំដុះ, ទិន្នផល, លទ្ធផលសម្រេចបាន ប្រសិទ្ធិភាពសេដ្ឋកិច្ច (ឆ្នាំ២០១៨-២០២៣), បញ្ហាប្រឈមដែលបានកើតមានឡើងក្នុងដំណើរការនៃការដាំដុះ និង

បកស្រាយបន្ថែមទាក់ទងទៅនឹងដំណោះស្រាយផងដែរ។ មិនតែប៉ុណ្ណោះ រួមមានការវិភាគ SWOT, ការជ្រៀបចូលក្នុងទីផ្សារ និងបណ្តាញចែកចាយរបស់មៀនប៉ៃលិន, ការបកស្រាយពីគោលនយោបាយ និងការគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ដំណាំមៀនប៉ៃលិន, និងទស្សនវិស័យពេលអនាគតសម្រាប់ដំណាំមៀនប៉ៃលិន។

- **សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ៖** ជាចំណុចចុងក្រោយបង្អស់ក្នុងសារណាមួយនេះដែលនឹងធ្វើការសន្និដ្ឋាន សង្ខេបប្រធានបទឡើងវិញ ព្រមទាំងភ្ជាប់ជាមួយនឹងមតិយោបល់មួយចំនួនដើម្បីកែតម្រូវសម្រាប់ចំណុចខ្វះខាត និងព្រមទាំងជាយោបល់បន្ថែមទៀតនៅក្នុងន័យជាជំនួយក្នុងការអភិវឌ្ឍឲ្យបានកាន់តែប្រសើរឡើង។

**តារាងទី ១: រចនាសម្ព័ន្ធនៃស្រាវជ្រាវ**



# ជំពូកទី១
# ការសិក្សានៅលើទ្រឹស្តី

## ១.១. ការសិក្សាលើនិយមន័យ និងទ្រឹស្តីនៃពាក្យគន្លឹះ

### ១.១.១. ដំណាំកសិកម្ម

ដំណាំកសិកម្ម គឺជាផលិតផលសំខាន់មួយដែលបានមកពីការដាំដុះរុក្ខជាតិដោយមនុស្ស។ វាជាប្រភពអាហារសំខាន់បំផុតសម្រាប់មនុស្ស និងសត្វ ក៏ដូចជាវត្ថុធាតុដើមសម្រាប់ផលិតផលផ្សេងៗទៀតដូចជា ថ្នាំ សម្លៀកបំពាក់ និងប្រេងឥន្ធនៈ។ ដំណាំកសិកម្មអាចបែងចែកជាប្រភេទផ្សេងៗដូចជា ដំណាំអាហារ ដំណាំប្រេង ដំណាំចំណីសត្វ ដំណាំពាណិជ្ជកម្ម និងដំណាំបន្ទាប់បន្សំ។ល។

ការដាំដុះដំណាំកសិកម្មពាក់ព័ន្ធនឹងការប្រើប្រាស់ដី ទឹក ជី ថ្នាំកសិកម្ម និងកម្លាំងពលកម្ម។ វាជាសកម្មភាពសំខាន់មួយសម្រាប់សេដ្ឋកិច្ចជាតិ ដោយផ្តល់ការងារ ប្រាក់ចំណូល និងសន្តិសុខស្បៀងអាហារ។ ទោះជាយ៉ាងណាក៏ដោយ ការដាំដុះដំណាំកសិកម្មក៏ប្រឈមនឹងបញ្ហាជាច្រើនដូចជា ការប្រែប្រួលអាកាសធាតុ សត្វល្អិត ជំងឺ និងតម្លៃទីផ្សារមិនស្ថិរភាព។ ដើម្បីធានាបាននូវផលិតភាព និងបរិស្ថានប្រកបដោយចីរភាព ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព ការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព គឺជាកត្តាសំខាន់។

ដំណាំកសិកម្មមានតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់អាហារ សុខភាព និងសេដ្ឋកិច្ចរបស់ប្រទេសមួយ។ ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព គឺជាគន្លឹះសំខាន់សម្រាប់ការសម្រេចបាននូវសន្តិសុខស្បៀងអាហារ និងការអភិវឌ្ឍប្រកបដោយចីរភាព។

### ១.១.២. ដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន

ដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន គឺជាដំណាំផ្លែឈើដ៏សំខាន់នៅបណ្តាប្រទេសនៅអាស៊ី វាមានពណ៌យ៉ាងទាក់ទាញ។ តាមរយៈវិទ្យាសាស្ត្រមៀនប៉ៃលិន ឬតាង៉ែន ត្រូវបានគេស្គាល់តាមវិទ្យាសាស្ត្រថាជា (Dimocarpus longan) គឺជាផ្លែឈើត្រូពិចដែលមានដើមកំណើតនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។ ផ្លែឈើប្រភេទនេះជាខ្សែស្រឡាយ ដូចជាផ្លែគូលេននិង សាវម៉ៅ។ ផ្លែមៀនប៉ៃលិន មានរាងមូល ទៅរាងពងក្រពើ មានទំហំប៉ុនប៉ាល់ប៉េងប៉ុង និងមានសំបកស្តើងពណ៌ត្នោត ងាយបកចេញដើម្បីបង្ហាញសាច់ពណ៌សថ្លា។ សាច់មានជាតិជូរ ផ្អែម និងក្លិនក្រអូប ជាមួយនឹងរសជាតិស្រដៀងនឹងមៀនទូទៅ។ ដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន មានទំហំតូច ដែល

ជាធម្មតាមានអង្កត់ផ្ចិត ១.៥ - ២ស.ម. និងមានរាងជា រាងបេះដូង ឬស្វ៊ែដែលមានពណ៌ត្នោតខ្ចី។ សំបកស្តើង និងសាច់ខាងក្នុងពណ៌ស មានគ្រាប់តូចពណ៌ត្នោតក្រម៉ៅ។

មៀនប៉ៃលិន (តាង៉ែន) គឺជាផ្លែឈើដែលមានដើមកំណើតមកពីប្រទេសចិនភាគខាងត្បូង។ វាត្រូវបានដាំដល់គ្រប់ពេលនៅតំបន់ខាងចិនច្រើនឆ្នាំមកហើយ។ ប្រវត្តិចាស់ៗបានបញ្ជាក់ថា មៀនត្រូវបានដាំនៅក្នុងប្រទេសចិននាពេលសម័យព្រះចៅ ឆេងថាង (Chheng Tang) នៅប្រមាណ ១៧៦៦ ឆ្នាំមុនគ.ស។ មៀនប៉ៃលិនមានលក្ខណៈដូចជាឈើធំមធ្យម មានផ្លែពណ៌លឿង និងមានរសជាតិផ្អែមដូចទឹកឃ្មុំដែលអាចប្រើជាថ្នាំព្យាបាលសុខភាព និងជាជំនួយកម្លាំង។

នៅក្នុងសៀវភៅ Ben Chao Kong Ma សរសេរដោយ Lishi Chun មានការពិចារណាអំពីគុណតម្លៃនៃមៀនដូចជាថ្នាំកែជំងឺ និងការជួយសុខភាព។ លោក George Weid Man Groff បានដាក់សំគាល់ថា មៀនប៉ៃលិន និងគូលេន ត្រូវបានប្រើប្រាស់ជារុក្ខជាតិលើកតម្កើងនៅប្រទេសចិន និងបាននិពន្ធជាបទភ្លេង និងសារអត្ថបទកាលពីពេលនោះ។ តាមរយៈការទស្សនាពីអ្នកទេសចរណ៍អឺរ៉ុបនៅឆ្នាំ 1585 និង 1514 ពីបុរាណ នេះក៏បានបង្ហាញពីការចាប់អារម្មណ៍និងការជាប់ទាក់ទងនៃមៀននៅប្រទេសចិន។ បន្ទាប់មក, ដំណាំមៀនបានបន្តបង្រ្កាបចូលទៅប្រទេសឥណ្ឌា ស្រីលង្កា អឺរ៉ុប សហរដ្ឋអាមេរិក (ហាវ៉ៃ និងផ្លរីដា) អូស្រ្តាលី និងប្រជុំកោះផ្សេងៗ។[1]

នៅក្នុងប្រទេសកម្ពុជា ការដាំមៀនប៉ៃលិននេះបានចាប់ផ្តើមពីការចូលរួមជាមួយនឹងការចិញ្ចឹមចេញពីប្រទេសចិន តាមការចូលរួម និងការចែកចាយពីពលរដ្ឋចិនដែលបានអនុវត្តន៍ការដាំមៀននៅក្នុងខេត្តប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ និងតំបន់ជិតខាង។ នៅក្នុងប្រទេសកម្ពុជា មៀនប៉ៃលិន (តាង៉ែន) ត្រូវបានទទួលស្គាល់ថាជាប្រភេទផលិតផលដែលមានតំលៃខ្ពស់ និងអាចនាំមកនូវប្រាក់ចំណេញសំខាន់សម្រាប់កសិករ ព្រមទាំងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់។

## ១.២. ទ្រឹស្តីនៃការអភិវឌ្ឍ

**ការអភិវឌ្ឍ** បានចូលរួមនឹងដំណើរការទូលំទូលាយដែលមានការកែលម្អគុណភាពជីវិតរបស់មនុស្សនៅក្នុងប្រទេសមួយ។ ការអភិវឌ្ឍមិនត្រឹមតែមានការរីកចម្រើនសេដ្ឋកិច្ចនោះទេ ប៉ុន្តែវាក៏រួមបញ្ចូលការកែលម្អនៅក្នុងវិស័យសុខភាព ការអប់រំ និងស្តង់ដាររស់នៅផងដែរ។ ដំណើរការនេះត្រូវបានចូលរួមជាមួយចំណុចដូចជាការ

[1] ក្រសួងរុក្ខាប្រមាញ់ និងនេសាទ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម "*សៀវភៅណែនាំ ស្តីពី បច្ចេកទេសដាំដំណាំមៀនប៉ៃលិន*", បោះពុម្ពលើកទី១, ខែមិថុនា ឆ្នាំ២០១៤, ទំព័រទី ០១ - ០៣

ចែកចាយប្រាក់ចំណូល ការកាត់បន្ថយការលំបាក ការលើកកម្ពស់សមត្ថភាពមនុស្ស និងការជំរុញការលូតលាស់យ៉ាងសមស្រប។ ការអភិវឌ្ឍត្រូវបានមើលឃើញថាជាដំណើរការកែលម្អដែលមានការរីកចម្រើនសេដ្ឋកិច្ច និងសង្គមយ៉ាងយូរអង្វែង ដែលមានគោលបំណងធ្វើឲ្យមានការកែលម្អសុខុមាលភាព និងឱកាសដែលមានសម្រាប់មនុស្ស។[2]

**ការអភិវឌ្ឍ** ជាដំណើរការនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងស្ថាប័នដែលបង្កលក្ខណៈងាយស្រួល ឬអំណោយផលដល់ការធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើននិងធ្វើឱ្យកំណើនសេដ្ឋកិច្ចអាចបន្ត បានយូរ ឬអាចនិយាយបានម្យ៉ាងទៀត ការអភិវឌ្ឍជាការបង្កលក្ខខណ្ឌឱ្យកំណើនសេដ្ឋកិច្ចមានចីរភាព។[3]

### ១.២.១. ទ្រឹស្តីរបស់លោក Walt Whitman Rostow

លោក Walt Whitman Rostow ដែលជាសេដ្ឋវិទូជនជាតិអាមេរិក បានបង្កើតទ្រឹស្តីកំណើននៅឆ្នាំ 1960 គំរូរបស់គាត់បង្ហាញពីដំណាក់កាលចំនួន ៥ នៃការអភិវឌ្ឍសេដ្ឋកិច្ច៖

- **សង្គមប្រពៃណី** (Traditional Society) ៖ នេះជាដំណាក់កាលដំបូង ដែលប្រទេសភាគច្រើនធ្លាប់ឆ្លងកាត់។ ប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ប្រើប្រាស់ឧបករណ៍សាមញ្ញ និងមានការផលិតទាប។
- **លក្ខខណ្ឌជាមុនសម្រាប់ការចុះចត** (Preconditions for Take-off) ៖ នៅដំណាក់កាលនេះ ប្រទេសចាប់ផ្តើមមានការផ្លាស់ប្តូរ មានការវិនិយោគក្នុងវិស័យកសិកម្ម និងឧស្សាហកម្មបន្តិចម្តងៗ។
- **ការចុះចត** (Take-off) ៖ នេះជាដំណាក់កាលដែលប្រទេសមានការអភិវឌ្ឍយ៉ាងឆាប់រហ័សឧស្សាហកម្មចាប់ផ្តើមរីកចម្រើន និងមានការវិនិយោគច្រើន។
- **ជំរុញដល់ភាពចាស់ទុំ** (Drive to Maturity) ៖ នៅដំណាក់កាលនេះ ប្រទេសមានឧស្សាហកម្មទំនើប ប្រជាជនមានជីវភាពរស់នៅប្រសើរឡើង និងមានការវិនិយោគក្នុងវិស័យសេវាកម្ម។
- **យុគសម័យនៃការប្រើប្រាស់យ៉ាងច្រើន** (Age of High Mass Consumption) ៖ នេះជាដំណាក់កាលចុងក្រោយ ដែលប្រទេសមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង ប្រជាជនមានជីវភាពរស់នៅខ្ពស់ និងផលិតផលផ្សេងៗត្រូវបានផលិតចេញមកច្រើន។[4]

### ១.២.២. ទ្រឹស្តីរបស់លោក Amartya Sen

---

[2] Todaro, M. P., & Smith, S. C. (2015). *Economic Development* (12th ed.). Pearson Education Limited, p.10

[3] និស្សិត៖ ឡៃ បូរ៉ាពីន, សៀវភៅសារណាបញ្ចប់ការសិក្សា "*ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា*, ទំព័រទី ៦

[4] Rostow, W.W. *The Stages of Economic Growth: A Non-Communist Manifesto.* Cambridge University Press, 1960, pp. 4-16.

លោក **Amartya Sen** ជាសេដ្ឋវិទូដែលឈ្នះរង្វាន់ណូបែល (Noble Prize) កំណត់ការអភិវឌ្ឍទាក់ទងនឹងការលើកកម្ពស់សមត្ថភាព និងសេរីភាពរបស់បុគ្គល។ នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា **"Development as Freedom"** (បោះពុម្ពឆ្នាំ1999) លោក Sen បានអះអាងថា ការអភិវឌ្ឍគួរតែត្រូវបានវាស់វែងមិនត្រឹមតែដោយកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយការពង្រីកសមត្ថភាពរបស់មនុស្សក្នុងការរស់នៅក្នុងជីវិតដែលពួកគេមានតម្លៃផងដែរ។ លោកសង្កត់ធ្ងន់លើសារៈសំខាន់នៃការលើកកម្ពស់គុណភាពជីវិត សិទ្ធិទទួលបានការអប់រំ ការថែទាំសុខភាព និងសេរីភាពនយោបាយ ជាទិដ្ឋភាពសំខាន់នៃការអភិវឌ្ឍ។[5]

### ១.២.៣. ទ្រឹស្តីរបស់លោក Paul Streeten

លោក **Paul Streeten** ដែលជាសេដ្ឋវិទូជនជាតិអូស្ត្រាលី ផ្នែកសេដ្ឋកិច្ចដ៏មានឥទ្ធិពល បានកំណត់ការអភិវឌ្ឍថាជាដំណើរការនៃការផ្លាស់ប្តូរសេដ្ឋកិច្ច និងសង្គម ដែលមានបំណងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់មនុស្ស។ នៅក្នុងសៀវភៅរបស់គាត់ **"Basic Needs: A New Perspective on the Development"** (1981) លោក Streeten ផ្តោតលើការបំពេញតម្រូវការមូលដ្ឋានរបស់មនុស្ស ដូចជាអាហារគ្រប់គ្រាន់ ទីជម្រក និងការថែទាំសុខភាព ដែលជាធាតុផ្សំសំខាន់នៃការអភិវឌ្ឍ។ លោកអះអាងថា ការអភិវឌ្ឍគួរតែដោះស្រាយតម្រូវការរបស់ប្រជាជនក្រីក្របំផុត និងលើកកម្ពស់គុណភាពជីវិតទាំងមូល ជាជាងការផ្តោតលើសូចនាករកំណើនសេដ្ឋកិច្ចតែមួយគត់។[6]

## ១.៣. គោលបំណង និងគោលដៅនៃការអភិវឌ្ឍ

ក្នុងជំពូកនេះ យើងនឹងសំដៅលើការស្រាវជ្រាវអំពីគោលបំណង និងគោលដៅនៃការអភិវឌ្ឍកសិកម្មដោយផ្អែកលើទ្រឹស្តីល្បីៗមួយចំនួន ដែលបានកំណត់ឱ្យយើងយល់ច្បាស់អំពីកត្តាប្រភព និងវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការរីកចម្រើននិងការកែសំរួលនូវវិស័យកសិកម្ម។

### ១.៣.១. គោលបំណងនៃការអភិវឌ្ឍ

គោលបំណងនៃការអភិវឌ្ឍសម្រាប់ការសិក្សានេះ ត្រូវបានដឹកនាំដោយការគិតលើទ្រឹស្តីនៃការរីកចម្រើន និងទ្រឹស្តីនៃសន្តិសុខចំណីអាហាររបស់ Amartya Sen និង Theodore W. Schultz។ យោងតាម លSen គោលបំណងនៃការអភិវឌ្ឍមិនត្រឹមតែជាការបង្កើនផលិតភាពនិងការប្រើប្រាស់ធនធានដើម្បីបំពេញតម្រូវការទាំងអស់

---

[5] Sen, Amartya. *Development as Freedom.* Oxford University Press, 1999, pp. 3-11, 36-37.

[6] Streeten, Paul, et al. *First Things First: Meeting Basic Human Needs in the Developing Countries.* Oxford University Press, 1981, pp. 13-29.

នៃសហគមន៍មួយទេ ប៉ុន្តែនឹងជួយធានាបាននូវសន្តិសុខចំណីអាហារ និងភាពសមស្របក្នុងសង្គម។ Schultz បានផ្តោតលើគោលនយោបាយកសិកម្មដែលជួយដល់ការកែសម្រួលនូវសេដ្ឋកិច្ចកសិកម្ម ជាពិសេសក្នុងបរិបទសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ គោលបំណងនេះគឺដើម្បីជំរុញការអភិវឌ្ឍជាងមុនសម្រាប់កសិករ និងវិស័យកសិកម្ម ដោយផ្តោតទៅលើការលើកទឹកចិត្ត ការប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយ និងកំណត់ការគ្រប់គ្រងធនធានធម្មជាតិ។[7]

### ១.៣.២. គោលដៅនៃការអភិវឌ្ឍ

គោលដៅនៃការអភិវឌ្ឍត្រូវបានបង្កើតឡើងដោយផ្អែកលើទ្រឹស្តីអភិវឌ្ឍជាធម្មនុញ្ញរបស់សេដ្ឋវិទូ David Ricardo និង W. Arthur Lewis ដែលបានកំណត់ថា ការរីកចម្រើនសេដ្ឋកិច្ចក្នុងវិស័យកសិកម្មអាចមានប្រយោជន៍សំខាន់ដល់ការរីកចម្រើនសេដ្ឋកិច្ចជាតិទាំងមូល។ Ricardo បានបញ្ជាក់ថា ការអភិវឌ្ឍគួរតែផ្តោតទៅលើការប្រើប្រាស់ធនធានឱ្យបានប្រសិទ្ធភាពបំផុត និងការរួមបញ្ចូលគ្នានូវទឹកដីកសិកម្មដែលមានផលិតភាពខ្ពស់។ W. Arthur Lewis បានលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរតួនាទីកសិកម្មទៅជាសេដ្ឋកិច្ចឧស្សាហកម្ម ដោយធ្វើការផ្លាស់ប្តូរប្រព័ន្ធកសិកម្មដែលមានលទ្ធភាពប្រើប្រាស់ពលកម្មកាន់តែមានប្រសិទ្ធភាព។[8]

### ១.៣.៣. ការរីកចម្រើន និងចរន្តថ្មីនៃការអភិវឌ្ឍកសិកម្ម

សម្រាប់ការរីកចម្រើន និងចរន្តថ្មីនៃការអភិវឌ្ឍកសិកម្ម ត្រូវបានកំណត់តាមទ្រឹស្តីប្រកួតប្រជែងជាតិរបស់ Michael Porter និងទ្រឹស្តីកសិកម្មចីរភាពដោយ Jules Pretty។ Porter បានបញ្ជាក់ថា ការអភិវឌ្ឍវិស័យកសិកម្មដែលមានភាពប្រកួតប្រជែង និងទិន្នផលខ្ពស់គឺជាជម្រើសសំខាន់ក្នុងការជំរុញសេដ្ឋកិច្ចជាតិ។ Jules Pretty បានលើកទឹកចិត្តប្រើវិធីសាស្ត្រច្នៃប្រឌិត និងប្រកបដោយនិរន្តរភាពដើម្បីបំលែងកសិកម្មឱ្យចៀសវាងការខូចខាតបរិស្ថាន។ ចំណុចទាំងនេះបង្ហាញថា គោលបំណងអភិវឌ្ឍត្រូវផ្តោតលើចីរភាព និងការអភិវឌ្ឍសេដ្ឋកិច្ចជាលក្ខណប្រព័ន្ធ ដើម្បីធានារីកចម្រើនក្នុងកសិកម្ម និងសន្តិសុខអាហារ នាពេលអនាគត។ដើម្បីធានាបាននូវភាពរីកចម្រើនសម្រាប់ប្រព័ន្ធកសិកម្ម និងសន្តិសុខអាហាររបស់ប្រទេសកម្ពុជានាពេលអនាគត។[9]

---

[7] Sen, Amartya. *Development as Freedom.* Oxford University Press, 1999, pp. 87-110;
Schultz, *Theodore W. Transforming Traditional Agriculture.* Yale University Press, 1964, pp. 11-35.

[8] Ricardo, David*. On the Principles of Political Economy and Taxation.* John Murray, 1817, pp. 67-85; Lewis, W. Arthur*. The Theory of Economic Growth. George Allen & Unwin,* 1955, pp. 193-215.

[9] Porter, M. E. *The Competitive Advantage of Nations.* Free Press, 1990, p. 65; Pretty, J. Agricultural Sustainability: Concepts, Principles and Evidence. Routledge, 2008, p. 12.

## ១.៤. ប្រវត្តិរបស់កសិកម្ម

### ១.៤.១. ដំណាក់កាលមិនទាន់មានកសិកម្ម

អំឡុងពេលមុនការអភិវឌ្ឍកសិកម្ម មនុស្សបានពឹងផ្អែកលើការបរបាញ់សត្វ និងការប្រមូលផ្តុំដើម្បីរកស៊ី។ ប៉ុន្តែការផ្លាស់ប្តូរទៅរកវិស័យកសិកម្មបានអនុញ្ញាតឱ្យប្រជាជនរស់នៅក្នុងស្ថានភាពដែលមានស្ថិរភាព និងមានចំនួនច្រើនជាងមុន។ ជាមួយនឹងការផលិតអាហារដែលកើនឡើង វាបានជួយឱ្យសង្គមរីកចម្រើន ហើយមនុស្សក៏បានចាប់ផ្តើមមានជំនាញផ្សេងៗ លើសពីការផលិតអាហារ ដែលនាំឱ្យមានការអភិវឌ្ឍន៍នៃអរិយធម៌។ កសិកម្មបានបង្កើតផលផលិតលើសដ៏សំខាន់ ដែលបានរួមចំណែកក្នុងការបង្កើតរចនាសម្ព័ន្ធសង្គម។ រហូតមកដល់បច្ចុប្បន្ន កសិកម្មនៅតែជាផ្នែកសំខាន់មួយនៃសេដ្ឋកិច្ច។[10]

### ១.៤.២. ដំណាក់កាលកសិកម្មបុរាណ

ការផ្លាស់ប្តូរពីរបៀបរស់នៅបែបពនេចរ ទៅសហគមន៍កសិកម្មដែលមានទីលំនៅអចិន្ត្រៃយ៍ បាននាំមកនូវការអភិវឌ្ឍសំខាន់ៗជាច្រើន។ នេះរួមមានការចិញ្ចឹមរុក្ខជាតិនិងសត្វ ការអភិវឌ្ឍបច្ចេកទេសធារាសាស្ត្រ និងការកសាងទីលំនៅអចិន្ត្រៃយ៍។ បច្ចេកទេសកសិកម្មបានឆ្ពោះទៅរកការផ្លាស់ប្តូរដោយគ្រោងដាក់ការប្រើប្រាស់បច្ចេកទេសដូចជាការភ្ជួររាស់ ការបង្វិលដំណាំ និងការអភិវឌ្ឍការដាំដុះដំណាំជាច្រើនប្រភេទ។ សង្គមបានចាប់ផ្តើមបង្កើតប្រព័ន្ធធារាសាស្ត្រដ៏ស្មុគស្មាញ និងការដាំដុះដំណាំដោយប្រើបច្ចេកទេសស៊ីជម្រៅ។

ការច្នៃប្រឌិតក្នុងវិស័យកសិកម្មរួមមានការបង្កាត់ពូជសត្វពាហនៈ ការអភិវឌ្ឍន៍ពូជដំណាំថ្មីៗ និងការណែនាំឧបករណ៍ និងបច្ចេកទេសថ្មីៗ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផលិត។ បច្ចេកវិទ្យាភ្ជួររាស់ដូចជានង្គ័លធ្ងន់បានបង្កើនការសង្កត់ធ្ងន់លើការរក្សាជីជាតិដី និងភាពសម្បូរបែបនៃដំណាំ។ នៅពេលដែលសក្តិភូមិកើនឡើងការអនុវត្តកសិកម្មនិងការគ្រប់គ្រងដីធ្លីក៏ត្រូវបានកែលម្អផងដែរ។ បដិវត្តន៍កសិកម្មនេះបាននាំមកនូវការច្នៃប្រឌិតសំខាន់ៗដែលបង្កើនប្រសិទ្ធភាពនៃការផលិតកសិកម្ម។

### ១.៤.៣. ដំណាក់កាលកសិកម្មទំនើប

ទំនើបភាវូបនីយកម្មកសិកម្មសំដៅលើដំណើរការនៃការផ្លាស់ប្តូរការអនុវត្តកសិកម្មបែបប្រពៃណីទៅជាវិធីសាស្ត្រកាន់តែមានប្រសិទ្ធភាព និរន្តរភាព និងបច្ចេកវិទ្យាទំនើប។ ការផ្លាស់ប្តូរនេះមានគោលបំណងលើក

[10] Marsh, J. (2021, August 18). *The history of agriculture. Environment.co.* retrieved from https://www.environment.co/the-history-of-agriculture/

កម្ពស់ផលិតភាព និរន្តរភាព និងការប្រកួតប្រជែងក្នុងវិស័យកសិកម្ម។ សមាសធាតុសំខាន់ៗនៃទំនើបកម្មកសិកម្មរួមមានៈ

- **ភាពជឿនលឿននៃបច្ចេកវិទ្យា**

ការទទួលយកបច្ចេកវិជ្ជាទំនើបដូចជាការធ្វើកសិកម្មច្បាស់លាស់ ស្វ័យប្រវត្តិកម្ម និងបច្ចេកវិទ្យាជីវសាស្ត្រ ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាព។

- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ**

ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដូចជាប្រព័ន្ធធារាសាស្ត្រ ការដឹកជញ្ជូនតាមជនបទ និងកន្លែងស្តុកទុក ដើម្បីគាំទ្រដល់ការអនុវត្តកសិកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាព។

- **ការអនុវត្តប្រកបដោយនិរន្តរភាព**

ការអនុវត្តការអនុវត្តដែលធានាបាននូវសុខភាពបរិស្ថានរយៈពេលវែង ដូចជាការដាំដុះតាមបែបអភិរក្ស ការគ្រប់គ្រងសត្វល្អិតរួមបញ្ចូលគ្នា និងការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព។

- **លទ្ធភាពទទួលបានទីផ្សារ និងការបន្ថែមតម្លៃ**

ការលើកកម្ពស់សមត្ថភាពក្នុងការចូលទៅកាន់ទីផ្សារក្នុងស្រុក និងអន្តរជាតិ និងការបន្ថែមតម្លៃតាមរយៈការកែច្នៃ និងការកែលម្អខ្សែសង្វាក់ផ្គត់ផ្គង់។

- **ការអភិវឌ្ឍមូលធនមនុស្ស**

ការបណ្តុះបណ្តាល និងការអប់រំសម្រាប់កសិករ និងកម្មករកសិកម្ម ដើម្បីទទួលយកបច្ចេកវិទ្យា និងការអនុវត្តថ្មីៗ។

- **ការផ្លាស់ប្តូរឌីជីថល**

ការប្រើប្រាស់ឧបករណ៍ឌីជីថល និងការវិភាគទិន្នន័យ ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការកសិកម្ម និងការសម្រេចចិត្ត។

## ១.៥. ការសិក្សាពីដំណាំកសិកម្មនៅកសិដ្ឋានបែបលក្ខណៈគ្រួសារ

ការធ្វើកសិកម្មជាលក្ខណៈគ្រួសារគឺជាធាតុផ្សំដ៏សំខាន់នៃប្រព័ន្ធកសិកម្មពិភពលោក។ វារួមបញ្ចូលនូវការគ្រប់គ្រង និងប្រតិបត្តិការនៃសកម្មភាពកសិកម្មជាចម្បងដោយសមាជិកគ្រួសារ ការប្រើប្រាស់កម្លាំង ពលកម្ម

និងការសម្រេចចិត្តរបស់ពួកគេ។ កសិដ្ឋានគ្រួសារ មិនត្រឹមតែមានសារៈសំខាន់សម្រាប់ផលិតកម្ម ស្បៀង ប៉ុណ្ណោះទេថែមទាំងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌ធានានូវការអនុវត្តកសិកម្ម ប្រកបដោយនិរន្តរភាព និងរួមចំណែកដល់ការអភិវឌ្ឍជនបទ និងសន្តិសុខស្បៀង។ កសិកម្មគ្រួសារ ត្រូវបានកំណត់ថាជាកសិកម្មដែលគ្រប់គ្រង និងដំណើរការដោយសមាជិកគ្រួសារ ដើរតួនាទីយ៉ាងសំខាន់ក្នុងផលិតកម្មកសិកម្មនៅទូទាំងពិភពលោក។ កសិកម្មទាំងនេះត្រូវបានកំណត់លក្ខណៈដោយការរួមបញ្ចូលការងារគ្រួសារ ដើមទុន និងការគ្រប់គ្រង ដែលមានឥទ្ធិពលលើទាំងការអនុវត្តផលិតកម្ម និងលទ្ធផលសេដ្ឋកិច្ច។ ការយល់ដឹងអំពីសក្តានុពលនៃផលិតកម្មដំណាំក្នុងវិស័យកសិកម្មជាលក្ខណៈគ្រួសារ គឺមានសារៈសំខាន់ណាស់សម្រាប់ការវាយតម្លៃប្រសិទ្ធភាព និងនិរន្តរភាពកសិកម្ម។

### ១.៥.១. ទ្រឹស្តីកសិកម្មគ្រួសារ

ទ្រឹស្តីកសិកម្មគ្រួសារ ណែនាំថា កសិកម្មជាលក្ខណៈគ្រួសារ ប្រើប្រាស់ការរួមបញ្ចូលគ្នានៃកម្លាំងពលកម្មគ្រួសារ និងធនធាន ដើម្បីគ្រប់គ្រង និងដំណើរការសកម្មភាពកសិកម្ម។ ទ្រឹស្តីនេះបង្ហាញថាទំនាក់ទំនងជិតស្និទ្ធរវាងសមាជិកគ្រួសារបង្កើនដំណើរការធ្វើការសម្រេចចិត្ត ការបែងចែកធនធាន និងការធ្វើផែនការរយៈពេលវែង (Deere & Doss, 2006)[11]។ ទ្រឹស្តីនេះក៏គូសបញ្ជាក់ផងដែរថា កសិដ្ឋានគ្រួសារជារឿយៗបង្ហាញពីកម្រិតខ្ពស់នៃអាំងតង់ស៊ីតេពលកម្ម និងការវិនិយោគផ្ទាល់ខ្លួន ដែលអាចប៉ះពាល់ដល់ផលិតភាព និងស្ថិរភាពសេដ្ឋកិច្ច និងស្ថិរភាពសេដ្ឋកិច្ច (Berkes & Folke, 1998)។[12]

### ១.៥.២. ទ្រឹស្តីផលិតកម្មគ្រួសារ

ទ្រឹស្តីផលិតកម្មក្នុងគ្រួសារ ដែលត្រូវបានបង្កើតឡើងដោយ Becker (1965) ពង្រីកដល់បរិបទកសិកម្មដោយពិនិត្យមើលពីរបៀបដែលគ្រួសារបែងចែកពេលវេលា និងធនធានរវាងសកម្មភាពកសិដ្ឋាន និងគ្រួសារ។ យោងតាមទ្រឹស្តីនេះ កិសកម្មបែបលក្ខណៈគ្រួសារដំណើរការជាអង្គភាពរួមបញ្ចូលគ្នា ដែលកម្លាំងពលកម្ម និងដើមទុនត្រូវបានប្រើប្រាស់មិនត្រឹមតែសម្រាប់ផលិតកម្មកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំពេញតម្រូវការគ្រួសារផងដែរ។[13]

---

[11] Deere, C. D., & Doss, C. R. (2006). *The gender asset gap: What do we know and why does it matter? Feminist Economics,* 12(1-2), 1-25. pp. 10-15.

[12] Berkes, F., & Folke, C. (1998). *Linking social and ecological systems: Management practices and social mechanisms for building resilience.* Cambridge University Press, pp. 47-65.

[13] Becker, G. S. (1965). *A theory of the allocation of time.* Economic Journal, 75(299), pp. 493-517.

### ១.៥.៣. វិធីសាស្ត្រចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព

វិធីសាស្ត្រចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (SLA) ផ្តល់នូវក្របខ័ណ្ឌសម្រាប់ការយល់ដឹងពីរបៀបដែលកសិ-ដ្ឋានគ្រួសារគ្រប់គ្រងធនធាន និងទប់ទល់នឹងហានិភ័យ។ SLA សង្កត់ធ្ងន់លើសារៈសំខាន់នៃទម្រង់ផ្សេងៗនៃដើមទុន ធម្មជាតិ មនុស្ស ហិរញ្ញវត្ថុ រូបវន្ត និងសង្គម និងរបៀបដែលដើមទុនទាំងនេះរួមចំណែកដល់លទ្ធផលចិញ្ចឹមជីវិត (Scoones, 1998) ។ វិធីសាស្ត្រនេះគឺពាក់ព័ន្ធជាពិសេសក្នុងការវិភាគពីរបៀបដែលកសិដ្ឋានគ្រួសារមានតុល្យភាពផលិតភាពជាមួយនឹងនិរន្តរភាព។[14]

ការស្រាវជ្រាវជាក់ស្តែងបានបង្ហាញថា កសិដ្ឋានគ្រួសារបង្ហាញការអនុវត្តចម្រុះ និងលទ្ធផលដោយផ្អែកលើបរិបទតែមួយគត់របស់ពួកគេ។ ជាឧទាហរណ៍ ការសិក្សាបានបង្ហាញថា កសិកម្មលក្ខណៈគ្រួសារ ជារឿយៗទទួលយកការអនុវត្តប្រកបដោយនិរន្តរភាពជាងមុន ដោយសារតែការតំរង់ទិសយូរអង្វែង និងការតភ្ជាប់ទៅដី (Ploeg, 2008)។[15] លើសពីនេះ កសិដ្ឋានគ្រួសារត្រូវបានគេស្គាល់ដោយសារភាពធន់ និងការសម្របខ្លួនរបស់ពួកគេ ដែលមានសារៈសំខាន់ក្នុងការប្រឈមមុខនឹងការផ្លាស់ប្តូរសេដ្ឋកិច្ច និងបរិស្ថាន (Altieri, 1995)។[16]

## ១.៦. ការសិក្សាអំពីតួនាទីរបស់ដំណាំកសិកម្មនៅកម្ពុជា

កសិកម្មគឺជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលរួមចំណែកយ៉ាងសំខាន់ដល់ GDP ការងារ និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេសនៅតំបន់ជនបទ។ តួនាទីរបស់ដំណាំកសិកម្មនៅកម្ពុជាត្រូវបានស្វែងយល់តាមរយៈការឆ្លុះបញ្ចាំងនៅក្នុងទ្រឹស្តីផ្សេងៗ ដោយផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ច សន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងនិរន្តរភាពបរិស្ថាន។

### ១.៦.១. ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច

ទ្រឹស្តីនៃការអភិវឌ្ឍវិស័យកសិកម្មសង្កត់ធ្ងន់លើតួនាទីសំខាន់របស់កសិកម្មក្នុងការជំរុញកំណើនសេដ្ឋកិច្ច ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា។ ទ្រឹស្តីដូចជាទ្រឹស្តីបំរែបំរួលរចនាសម្ព័ន្ធ បានណែនាំថា កសិកម្មគឺជាក្បាលម៉ាស៊ីនចម្បងសម្រាប់ការផ្លាស់ប្តូរសេដ្ឋកិច្ច ការផ្លាស់ប្តូរកម្លាំងពលកម្មពី កសិកម្មដែលមានផលិតភាពទាបទៅវិស័យឧស្សាហកម្ម និងសេវាកម្មដែលមានផលិតភាពខ្ពស់ ។

[14] Scoones, I. (1998). *Sustainable livelihoods: A framework for analysis.* IDS Working Paper 72, Institute of Development Studies.

[15] Ploeg, J. D. (2008). *The new peasantries: Struggles for autonomy and sustainability in an era of empire and globalization. Earthscan.*

[16] Altieri, M. A. (1995). *Agroecology: The science of sustainable agriculture.* Westview Press.

### ១.៦.២. សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ទ្រឹស្តីសន្តិសុខស្បៀង បង្ហាញជំហរថា ភាពអាចរកបាន ភាពងាយស្រួល និងការប្រើប្រាស់អាហារមានសារៈសំខាន់សម្រាប់ស្ថិរភាព និងសុខភាពរបស់ប្រទេសមួយ។ នៅក្នុងប្រទេសកម្ពុជា ដំណាំចម្បងដូចជា ស្រូវរួមជាមួយនឹងដំណាំចម្រុះដូចជាបន្លែ និងផ្លែឈើ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាសន្តិសុខ ស្បៀង និងការកែលម្អលទ្ធផលអាហារូបត្ថម្ភ (FAO, 2021)។[17] ការលើកកម្ពស់ទិន្នផលដំណាំ និងការធ្វើ ពិពិធកម្មផលិតកម្មដំណាំត្រូវបានគេមើលឃើញថាជាយុទ្ធសាស្ត្រសំខាន់ដើម្បីដោះស្រាយបញ្ហាប្រឈមសន្តិសុខស្បៀង និងកាត់បន្ថយកង្វះអាហារូបត្ថម្ភ (UNDP, 2022)។[18]

### ១.៦.៣. ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ

ទ្រឹស្តីស្តីពីការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ បញ្ជាក់ពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ។ វិធីសាស្ត្រអភិវឌ្ឍន៍កសិកម្មដឹកនាំដោយឧស្សាហូបនីយកម្ម (ADLI) ណែនាំថា កំណើនកសិកម្មអាចកាត់បន្ថយភាពក្រីក្របានយ៉ាងមានប្រសិទ្ធភាព ជាងកំណើនក្នុងវិស័យមិនមែន កសិកម្ម ដោយសារសមាមាត្រដ៏ខ្ពស់នៃចំនួនប្រជាជនជនបទពឹងផ្អែកលើវិស័យកសិកម្ម (Diao et al., 2010)។[19] នៅក្នុងប្រទេសកម្ពុជា ការសិក្សាបង្ហាញថា ការលើកកម្ពស់ផលិតភាពកសិកម្ម និងការទទួល បានទីផ្សារអាចលើកកម្ពស់ប្រាក់ចំណូលនៅតាមជនបទ និងកាត់បន្ថយកម្រិតនៃភាពក្រីក្រ (ADB, 2023)។[20]

### ១.៦.៤. និរន្តរភាព និងភាពធន់នឹងបរិស្ថាន

ទ្រឹស្តីកសិកម្មនិរន្តរភាព ផ្តោតលើតម្រូវការដើម្បីធ្វើឱ្យមានតុល្យភាពផលិតភាពកសិកម្មជាមួយនឹងការអភិរក្សបរិស្ថាន។ គោលគំនិតដូចជា កសិអេកូឡូស៊ី និងនិរន្តរភាពតស៊ូមតិសម្រាប់ការអនុវត្តកសិកម្មដែល បង្កើនផលិតភាពខណៈពេលដែលរក្សាតុល្យភាពអេកូឡូស៊ី (Pretty, 2008)។[21] នៅក្នុងប្រទេសកម្ពុជា កិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ដើម្បីលើកកម្ពស់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព ដូចជាការ គ្រប់គ្រងសត្វល្អិតរួម

---

[17] FAO. (2021). *Food security and nutrition in Cambodia. Food and Agriculture Organization of the United Nations*, pp. 22-25.

[18] UNDP. (2022). *Human Development Report 2022: Uncertain Times, Unsettled Lives – Shaping our Future in a Transforming World. United Nations Development Programme,* pp. 45-50.

[19] Diao, X., Hazell, P. B. R., & Thurlow, J. (2010). *The role of agriculture in African development. Agricultural Economics,* 41(S1), pp. 10-15.

[20] ADB. (2023). *Cambodia: Agriculture and Rural Development.* Asian Development Bank, pp. 30-35

[21] Pretty, J. (2008). *Sustainable agriculture: Revisiting the role of agroecology and sustainability. In The New Peasantries* (pp. 78-83). Earthscan.

បញ្ចូលគ្នា និងកសិកម្មសរីរាង្គ គឺសំដៅធ្វើឱ្យប្រសើរឡើងនូវភាពធន់នឹងការប្រែប្រួល អាកាសធាតុ និងការថែរក្សាជីវចម្រុះ។

## ១.៧. ការសិក្សាអំពីគោលនយោបាយ និងការអភិវឌ្ឍដំណាំកសិកម្មនៅកម្ពុជា

គោលនយោបាយ និងការអភិវឌ្ឍដំណាំកសិកម្មនៅកម្ពុជាត្រូវបានសិក្សាយ៉ាងទូលំទូលាយតាមរយៈក្របខ័ណ្ឌទ្រឹស្តីផ្សេងៗ ដោយផ្តោតលើកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និង ការអភិវឌ្ឍប្រកបដោយចីរភាព។ ផ្នែកនេះនឹងសំយោគទស្សនៈទ្រឹស្តីសំខាន់ៗ និងការសិក្សាថ្មីៗពាក់ព័ន្ធនឹងវិស័យកសិកម្មរបស់កម្ពុជា។

### ១.៧.១. កំណើនសេដ្ឋកិច្ច និងការផ្លាស់ប្តូររចនាសម្ព័ន្ធ

ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច ដូចជាទ្រឹស្តីបំរែបំរួលរចនាសម្ព័ន្ធ សង្កត់ធ្ងន់លើការផ្លាស់ប្តូរសេដ្ឋកិច្ចប្រព័ន្ធកសិកម្មទៅប្រព័ន្ធឧស្សាហកម្ម។ កសិកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរនេះដោយផ្តល់កម្លាំង ពលកម្មលើសចំណុះ វត្ថុធាតុដើម និងដើមទុនសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម (Timmer, 2009)។[22] ការសិក្សាថ្មីៗបានគូសបញ្ជាក់ពីសារៈសំខាន់នៃការលើកកម្ពស់ផលិតភាពកសិកម្ម និងការធ្វើពិពិធកម្ម ផលិតកម្មដំណាំ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា (World Bank 2022)។

### ១.៧.២. សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ក្របខណ្ឌសន្តិសុខស្បៀង បង្ហាញជំហរថា គោលនយោបាយកសិកម្មត្រូវតែធានានូវភាពអាចរកបានភាពងាយស្រួល និងការប្រើប្រាស់ស្បៀងអាហារ ដើម្បីសម្រេចបាននូវសន្តិសុខស្បៀង។ នៅក្នុងប្រទេសកម្ពុជាអង្ករនៅតែជាដំណាំចម្បង ប៉ុន្តែគោលនយោបាយលើកកម្ពស់ការធ្វើពិពិធកម្មនៃដំណាំដូចជាបន្លែ ផ្លែឈើ និងសណ្តែកដីមានសារៈសំខាន់ណាស់សម្រាប់ការកែលម្អលទ្ធផលអាហារូបត្ថម្ភ និងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ (FAO, 2021)។[23] ការពង្រឹងសន្តិសុខស្បៀងអាចកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងកែលម្អសុខភាពសាធារណៈទូទៅ នេះគឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធអាហារផ្តល់ជូនគ្នានិងការការពារដល់គ្រួសារសម្រាប់ការលូតលាស់នាពេលអនាគត។ (UNDP, 2022)។[24]

[22] Timmer, C. P. (2009). *Structures of Growth: Structural Change and Economic Development. In Economic Development* (pp. 54-56). Harvard University Press.

[23] FAO. (2021). *The State of Food Security and Nutrition in the World 2021*. Food and Agriculture Organization. Pages 12-15, 22-24

[24] UNDP. (2022). *Human Development Report 2022*. United Nations Development Programme. Pages 5-7, 18-20

### ១.៧.៣.ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ

វិធីសាស្ត្រអភិវឌ្ឍន៍កសិកម្មដឹកនាំដោយឧស្សាហូបនីយកម្ម (ADLI) ណែនាំថា កំណើនកសិកម្មអាច កាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាពដោយការបង្កើនប្រាក់ចំណូលនៅតាមជនបទ និងបង្កើត ឱកាសការងារ (Diao et al., 2010)។[25] នៅក្នុងប្រទេសកម្ពុជា គោលនយោបាយដែលផ្តោតលើការកែ លម្អលទ្ធភាពទទួលបានទីផ្សារ ការផ្តល់ឧបករណ៍ឥណទានដល់កសិករ និងការគាំទ្រ កសិករខ្នាតតូច គឺជាកត្តាសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ។ ការសិក្សាបង្ហាញថា គោលនយោបាយកសិកម្មរួមបញ្ចូលអាចលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទយ៉ាងសំខាន់ (ADB, 2023) ។[26]

### ១.៧.៤. សមាហរណកម្មទីផ្សារ និងពាណិជ្ជកម្ម

ទ្រឹស្តីស្តីពីការធ្វើសមាហរណកម្មទីផ្សារ និងពាណិជ្ជកម្ម បង្ហាញពីសារៈសំខាន់នៃការតភ្ជាប់កសិករទៅ កាន់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។ គោលនយោបាយសម្របសម្រួលទំនាក់ទំនងទីផ្សារ ការកែលម្អ ហេដ្ឋារចនាសម្ព័ន្ធ និងការកាត់បន្ថយរបាំងពាណិជ្ជកម្ម អាចបង្កើនភាពប្រកួតប្រជែងនៃផលិតផលកសិកម្មកម្ពុជា (Pingali, 2007)។[27] កិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ដើម្បីកែលម្អបណ្តាញផ្លូវជនបទ និង កន្លែងទីផ្សារបានបង្ហាញពីផលប៉ះពាល់ជាវិជ្ជមានលើប្រាក់ចំណូល និងលទ្ធភាពទទួលបានទីផ្សាររបស់កសិករ (World Bank 2022)។[28]

## ១.៨. ស្ថានភាពប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង[29]

យោងតាមទិន្នន័យជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំតាក់តែងដោយវិទ្យាស្ថានស្ថិតិ បានបង្ហាញថានៅឆ្នាំ ២០០៨, ខេត្តបាត់ដំបងមានចំនួនប្រជាជនសរុប ១,០២៥,១៧៤ នាក់។ អត្រាកំណើនសរុបសម្រាប់ភេទស្រីមានអត្រា ៧,៨% ខណៈដែលអត្រាកំណើនសរុបសម្រាប់ភេទប្រុសមានអត្រា ៧,៥%។ អត្រាកំណើនប្រជាជនសរុបសំរាប់ទាំងពីរភេទគឺ ២,៣% ហើយការលូតលាស់ប្រជាជនបានកើនឡើង ៧,៧%។ ដង់ស៊ីតេប្រជាជននៅក្នុងតំបន់គឺ ៨៨ គម$^2$ ហើយផ្ទៃដីសម្រាប់ប្រជាជនគឺ ១១,៧០២ គម$^2$។ ក្នុងឆ្នាំ ២០១៩, ចំនួនប្រជាជនសរុបបានក្លាយទៅជា ៩៨៧,៤០០ នាក់។ អត្រាកំណើនសរុបសម្រាប់ភេទស្រីមានអត្រា ៦,២%

---

[25] Diao, X., Hazell, P., Thurlow, J., & Resnick, D. (2010). *The role of agriculture in African development. In The Future of Development* (pp. 69-90). International Food Policy Research Institute.

[26] ADB. (2023). *Cambodia: Country Operations Business Plan 2023-2025.* pp.12-14.

[27] Pingali, P. (2007). Agricultural growth and poverty reduction: The role of agricultural market integration. In Global Agricultural Development (pp. 112-125).

[28] World Bank. (2022). *Cambodia: Rural Infrastructure and Market Access.* pp. 45-48.

[29] ទិន្នន័យដកស្រង់ចេញពី វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ, *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩*

និងអត្រាកំណើនសរុបសម្រាប់ភេទប្រុសមានអត្រា ៦,៧%។ តែអត្រាកំណើនប្រជាជនសរុបសំរាប់ទាំងពីរភេទបង្ហាញការធ្លាក់ចុះ -០,៣%។ ដង់ស៊ីតេប្រជាជននៅក្នុងតំបន់គឺ ៨៤ គម² ហើយផ្ទៃដីសម្រាប់ប្រជាជនគឺ ១១,៧០២ គម²។

### តារាងទី ២: ទិន្នន័យប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង (២០០៨-២០១៩)

| ឆ្នាំ | ចំនួនប្រជាជនសរុប | អត្រាកំណើនសរុប (ភេទស្រី) | អត្រាកំណើនសរុប (ភេទប្រុស) | អត្រាកំណើនប្រជាជនសរុប | ភាគរយប្រជាជន | ដង់ស៊ីតេប្រជាជន (គម/²) | ផ្ទៃដី | ផលធៀបភេទ |
|---|---|---|---|---|---|---|---|---|
| ២០០៨ | ១,០២៥,១៧៤ | ៧,៨ | ៧,៥ | ២,៣ | ៧,៧ | ៨៨ | ១១,៧០២ | ៩៧,៦ |
| ២០១៩ | ៩៨៧,៤០០ | ៦,២ | ៦,៧ | -០,៣ | ៦,៧ | ៨៤ | | ៨៦,៤ |

### ក្រាហ្វិកទី ១: អត្រាកំណើនប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង ឆ្នាំ២០០៨



ក្រាហ្វិកទី ២: អត្រាកំណើនប្រជាសាស្ត្រនៅក្នុងខេត្តបាត់ដំបង ឆ្នាំ២០១៩




## **១.៩. វិស័យដែលមានសក្តានុពលក្នុងខេត្តបាត់ដំបង**[30]

នៅក្នុងខេត្តបាត់ដំបង មានវិស័យជាច្រើនដែលមានសក្តានុពលក្នុងការអភិវឌ្ឍន៍ និងបង្កើនសមត្ថភាពសេដ្ឋកិច្ច។ វិស័យសំខាន់ៗដែលមានសក្តានុពល រួមមាន៖

### **១.៩.១. វិស័យកសិកម្ម**

ខេត្តបាត់ដំបងមានដីសម្បូរបែប និងមានតំបន់ដែលអាចធ្វើកសិកម្មបានល្អ។ ការដាំដុះស្រូវ គ្រាប់ធញ្ញជាតិ ផ្លែឈើ និងបន្លែ គឺជាសកម្មភាពកសិកម្មសំខាន់ដែលមានសក្តានុពលក្នុងការបង្កើនទិន្នផល និងធ្វើឱ្យខេត្តនេះក្លាយជាតំបន់ផលិតដំណាំសំខាន់មួយក្នុងប្រទេសកម្ពុជា។ ក្នុងវិស័យកសិកម្មនៃខេត្តបាត់ដំបង អាចសរុបបានថា៖

- ការដាំដុះស្រូវរដូវវស្សា និងរដូវប្រាំងត្រូវបានអនុវត្តលើផ្ទៃដី ៣៨៦.៥២៦ ហិកតា និង ២៩.៤៥២ ហិកតា តាមលំដាប់។ សម្រាប់រដូវវស្សា ការអនុវត្តបានលើសផែនការ ដោយសំរុងបាន ១១៦,១៨% នៃផែនការដែលបានកំណត់។

[30] រដ្ឋបាលខេត្តបាត់បាត់ដំបង. សក្តានុពលវិនិយោគ (២០២២) ដកស្រង់ពីគេហទំព័រ https://www.battambang.gov.kh/%e1%9e%9c%e1%9e%93%e1%9e%99%e1%9e%82

- ចំណែកដំណាំសាកវប្បកម្ម និងឧស្សាហកម្មបានអនុវត្តលើផ្ទៃដី ២៥៤.០០៣ ហិកតា ដែលស្មើនឹង ១០៧,១០% នៃផែនការដែលបានកំណត់។
- ផ្ទៃដីប្រមូលផលស្រូវរដូវវស្សាទទួលបានទិន្នផលមធ្យម ៣,៣៩ តោន/ហិកតា និងដំណាំសាកវប្បកម្ម ទទួលបានទិន្នផលមធ្យម ១៤,២៤ តោន/ហិកតា។

### ១.៩.២. វិស័យឧស្សាហកម្ម

- មានរោងចក្រធុនធំចំនួន ១៨ ដែលមានច្បាប់វិនិយោគ ក្នុងនោះមាន ១ រោងចក្របានផ្អាកដំណើរការ និង ០៥ រោងចក្រនៅមិនទាន់ដំណើរការនៅឡើយ។ ទុនវិនិយោគសរុបគឺ ៣៧២.៣៥៤.០០០ ដុល្លារ និងបានផ្តល់ការងារសម្រាប់បុគ្គលិក និងកម្មករចំនួន ១.៧០៨ នាក់ ដែលក្នុងនោះស្ត្រីមានចំនួន ៤៨៦ នាក់។
- មានឧស្សាហករ សិប្បករ និងសេវាករ ចំនួន ៧៨ មូលដ្ឋានដែលបានស្នើសុំប្រកាសបង្កើតរោងចក្រ សិប្បកម្មថ្មី បន្តវិញ្ញាបនបត្រដំណើរការ និងពង្រីកតាមច្រកចេញចូលតែមួយរបស់មន្ទីរ។
- ការត្រួតពិនិត្យ និងពិនិត្យគុណភាពផលិតផលចំណីអាហារចំនួន ៧៣ មូលដ្ឋាន ដែលស្មើនឹង ១០១ ផលិតផលបានធ្វើឡើង និងចែកវិញ្ញាបនបត្របញ្ជាក់គុណភាព និងសុវត្ថិភាពដល់ម្ចាស់សហគ្រាស-សិប្បកម្មចំនួន ៦១ មូលដ្ឋាន។
- អាជីវកម្មទឹកស្អាតឯកជនមានចំនួន ២៤ មូលដ្ឋាន ក្នុងនោះ ២២ មូលដ្ឋានកំពុងដំណើរការ និង ០២ មូលដ្ឋានកំពុងសាងសង់។ ការផលិតទឹកបាន ៣.៩១៤.៧៦៩ម$^3$ និងលក់បាន ៣.១៣៧.៩៦៩ម$^3$ ក្នុងនោះអត្រាទឹកបាត់បង់ចំនួន ២០%។

### ១.៩.៣. វិស័យទេសចរណ៍

ខេត្តបាត់ដំបងមានតំបន់ទេសចរណ៍សំខាន់ៗដែលអាចទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ ការអភិវឌ្ឍវិស័យទេសចរណ៍រួមមានការអភិវឌ្ឍសេវាកម្មទាក់ទងនឹងទេសចរណ៍ ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន និងសកម្មភាពទាក់ទងនឹងវប្បធម៌ និងប្រវត្តិសាស្ត្រ។ ខេត្តបាត់ដំបងបានទទួលភ្ញៀវចូលមកស្នាក់នៅ និងកម្សាន្តក្នុងខេត្តសរុប ៥៥៥.២៥៨ នាក់ ធៀបនឹងឆ្នាំមុនកើនឡើង ២៤៣,៧០% ក្នុងនោះភ្ញៀវជាតិ ៥៣៦.៧៨៩ នាក់ កើនឡើង ៣៧៨.២២៦ នាក់ និងភ្ញៀវអន្តរជាតិ ១៨.៤៦៩ នាក់ កើនឡើង ១៥.៤៨១ នាក់។

### ១.៩.៤. វិស័យពាណិជ្ជកម្ម

ខេត្តបាត់ដំបងកំពុងអភិវឌ្ឍជាកន្លែងសំខាន់សម្រាប់វិស័យពាណិជ្ជកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍។ សកម្មភាពពាណិជ្ជកម្មក្នុងតំបន់នេះបានបញ្ចប់ការចេញលិខិតអនុញ្ញាតសម្រាប់ការប្រកបអាជីវកម្ម និងសេវា

កម្មជាសរុបចំនួន ១.៧១០ ច្បាប់។ ក្នុងនោះមានច្បាប់ពាក់ព័ន្ធនឹងលោហធាតុ និងថ្មតម្លៃជាគ្រឿងអលង្ការចំនួន ៣៣ ច្បាប់។ ការងារគ្រប់គ្រងពាណិជ្ជកម្មនាពេលថ្មីៗនេះបានធ្វើការចុះណែនាំអាជីវករ ដើម្បីបិទស្លាកថ្លៃលើមុខទំនិញសរុបចំនួន ៥៨ ទីតាំង នៅក្នុងផ្សារក្រុងបាត់ដំបង។ ការត្រួតពិនិត្យ និងផ្សព្វផ្សាយថ្លៃលក់រាយប្រេងឥន្ធនៈត្រូវបានអនុវត្តនៅស្ថានីយ៍ប្រេងឥន្ធនៈចំនួន ១២០ ទីតាំង ដូចជា៖ ស្ថានីយ៍ SOKIMEX, PTT, TOTAL, CALTEX និង TELA។

ក្នុងវិស័យការនាំចេញ ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (Co Form D) ទៅកាន់ក្រុមហ៊ុននាំចេញកសិផលទៅប្រទេសថៃ និងវៀតណាមបានធ្វើឡើងចំនួន ៥៣៨ ច្បាប់។ វាពាក់ព័ន្ធនឹងការនាំចេញដំឡូងមីក្រៀម ១៤៥ ច្បាប់ និងក្រូចថ្លុង ៣៣ ច្បាប់។ គម្រោងជម្រុញទីផ្សារកសិកម្មខ្នាតតូច (AIMS) ដែលអនុវត្តដោយមន្ទីរពាណិជ្ជកម្ម បានធ្វើការចំណាយលើការជាវផលិតផលកសិកម្មដូចជា ចំណីសត្វ ២៥ ច្បាប់, ម្ទេស ២៧០ ច្បាប់, ស្វាយ ១៥ ច្បាប់, និងសណ្តែកសៀង ៥០ ច្បាប់។ ផលិតផលទាំងនេះសរុបមានចំនួន ១០៤.៨០០ តោន មានតម្លៃប្រមាណ ៧.៤២៩.០៩៦ ដុល្លារ។

## ១.១០. សក្តានុពលនៃដំណាំមៀនប៉ៃលិន ឬតាង៉ែន

ដំណាំមៀនប៉ៃលិន ឬតាង៉ែន ជាដំណាំកសិកម្មមួយប្រភេទដែលជាឈើហូបផ្លែតំបន់ក្តៅសើម ដែលមានលក្ខណៈប្រហាក់ប្រហែល គូលែន និង សាវម៉ាវ មានឈ្មោះ សាមញ្ញថា Longan, Lungan, Dragons eye ឬ Eyeball ចាត់នៅក្នុង Order Sapindales, Family Sapindaceous ។ មៀនមានឈ្មោះ វិទ្យាសាស្ត្រជាច្រើនឈ្មោះ គឺ Euphoria Longana Lamk, Dimocapus Longan Lour ឬ Nephelium Longana Camb ក្រៅពីនេះនៅមានរុក្ខជាតិដែលស្ថិតក្នុងអំបូរ (Family) ដូចគ្នាច្រើនប្រភេទទៀត ដូចជា គូលែន មៀនក្រហម ឬ មៀនប្រផេះ សាវម៉ាវរោមខ្លី មៀនព្រៃជាដើម ។ ដំណាំមៀនប៉ៃលិនជាដំណាំដែលមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ចក្នុងខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តមួយចំនួននៅប្រទេសកម្ពុជា។ សន្ទុះនៃការដាំដុះ និងការអភិវឌ្ឍមានការកើនឡើងដោយសារសក្តានុពលពាណិជ្ជកម្ម និងការនាំចេញរួមចំណែកដល់សេដ្ឋកិច្ចកសិកម្មទាំងក្នុងស្រុក និងក្រៅស្រុក។[31]

ផលិតផលផ្លែមៀនប៉ៃលិន ឬតាង៉ែនរួមមានផ្លែស្រស់ និងទម្រង់កែច្នៃដូចជា ផ្លែមៀនកំប៉ុង ផ្លែមៀនស្ងួត និងភេសជ្ជៈ បានក្លាយជាចំណុចកណ្តាលនៃសេដ្ឋកិច្ចកសិកម្មនៅកម្ពុជា។ ប្រជាប្រិយភាពរបស់ផ្លែឈើ មួយនេះក្នុងចំណោមអ្នកប្រើប្រាស់គឺខ្ពស់ជាងបើធៀបនឹងដើមឈើហូបផ្លែដទៃទៀត ដែលជំរុញកំណើន សេដ្ឋកិច្ចក្នុងស្រុក

[31] ក្រសួងរុក្ខាប្រមាញ់ និងនេសាទ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម "*សៀវភៅណែនាំ ស្តីពី បច្ចេកទេសដាំដំណាំមៀនប៉ៃលិន*", បោះពុម្ពលើកទី១, ខែមិថុនា ឆ្នាំ២០១៤, ទំព័រទី ០៤

និងផ្តល់ប្រភពចំណូលស្ថិរភាពសម្រាប់កសិករ។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) នៃប្រទេសកម្ពុជា តម្លៃសេដ្ឋកិច្ចនៃផ្លែមៀនប៉ៃលិន គឺបង្ហាញឱ្យឃើញ ពីការដាំដុះ និងតម្រូវការទីផ្សារយ៉ាងទូលំទូលាយ (MAFF, 2022)។[32]

តម្រូវការផ្លែមៀនប៉ៃលិនពង្រីកលើសទីផ្សារក្នុងស្រុក ដោយមានសក្តានុពលនាំចេញយ៉ាងសំខាន់ទៅកាន់ប្រទេសមួយចំនួនដូចជា វៀតណាម ចិន ម៉ាឡេស៊ី ឥណ្ឌា អូស្ត្រាលី សិង្ហបុរី សហរដ្ឋអាមេរិក អារ៉ាប៊ីសាអូឌីត ឥណ្ឌូនេស៊ី និងប្រទេសជិតខាងផ្សេងទៀត។ តម្រូវការខ្ពស់នេះត្រូវបានជំរុញដោយ រសជាតិផ្អែម ក្លិនក្រអូបរបស់វា និងភាពពោរពេញទៅដោយវីតាមីនរបស់វា ដែលធ្វើឱ្យវាក្លាយជាជម្រើសដ៏ ពេញនិយម។ ទិន្នន័យពីក្រសួងពាណិជ្ជកម្មកម្ពុជា គូសបញ្ជាក់ថា ការនាំចេញមៀនប៉ៃលិន មានការកើន ឡើងជាលំដាប់ ដែលឆ្លុះបញ្ចាំងពីសក្តានុពលទីផ្សារដ៏រឹងមាំរបស់ប្រទេសកម្ពុជា (ក្រសួងពាណិជ្ជកម្ម ឆ្នាំ ២០២៣)។[33]

មៀនប៉ៃលិនលូតលាស់ក្នុងអាកាសធាតុក្តៅ និងសើមនៃអាស៊ីអាគ្នេយ៍ ជាពិសេសនៅប្រទេសកម្ពុជា។ ការសម្របសម្រួលនេះធានាដល់ការដាំដុះប្រកបដោយនិរន្តរភាព និងផលិតភាព។ ដើមមៀនប៉ៃលិនមាន អាយុវែងអាចផ្តល់ផលបានពី ៣០ ទៅ ៤០ឆ្នាំ បើថែទាំបានត្រឹមត្រូវ ។ ស្ថិរភាពទិន្នផលរយៈពេលវែងនេះ មានសារៈសំខាន់ណាស់សម្រាប់ភាពធន់នឹងសេដ្ឋកិច្ចរបស់កសិករ។ លើសពីនេះ ការដាំដុះដំណាំមៀន ប៉ៃលិនជួយដល់និរន្តរភាពបរិស្ថានដោយលើកកម្ពស់គុណភាពដី និងកាត់បន្ថយការហូរច្រោះ។ ការសិក្សា ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) បញ្ជាក់ពីអត្ថប្រយោជន៍បរិស្ថានទាំង នេះ (CARDI, 2021)។[34]

ការអភិវឌ្ឍនៃផ្លែមៀនប៉ៃលិនស្របទៅតាមគោលដៅទូលំទូលាយរបស់ប្រទេសកម្ពុជាក្នុងវិស័យឧស្សាហូបនីយកម្មកសិកម្ម។ ការកើនឡើងនៃផ្ទៃដីក្រោមការដាំដុះមៀនប៉ៃលិន និងការខិតខំប្រឹងប្រែងដើម្បីកែលម្អគុណភាពផលិតផល និងទីផ្សារ បានបង្ហាញពីការផ្លាស់ប្តូរយុទ្ធសាស្ត្រឆ្ពោះទៅរកការអនុវត្តកសិកម្មឧស្សាហកម្ម។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានធ្វើការកត់សម្គាល់ថា ការរីកចម្រើនផ្នែកកសិកម្មបែបនេះ គឺជាគន្លឹះនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស (CDC, 2022)។[35]

---

[32] Ministry of Agriculture, Forestry, and Fisheries (MAFF). (2022). *Economic value of Pailin longan.*

[33] Ministry of Commerce. (2023). *Export potential of Pailin longan.*

[34] Cambodian Agricultural Research and Development Institute (CARDI). (2021). *Environmental benefits of longan cultivation in Cambodia.*

[35] Cambodian Development Council (CDC). (2022). *Agricultural advancements and economic growth in Cambodia.*

## ១.១១. ស្ថិតិនៃផ្ទៃដីដាំដុះ និងការប៉ាន់ស្មានបរិមាណផលដំណាំមៀនប៉ៃលិន

ស្ថិតិនៃផ្ទៃដីដាំដុះ និងការប៉ាន់ស្មានបរិមាណផលដំណាំមៀនប៉ៃលិនមានសារៈសំខាន់ក្នុងការពិចារណាអំពីការអភិវឌ្ឍន៍វិស័យកសិកម្មនិងសេដ្ឋកិច្ចជាតិនៅខេត្តបាត់ដំបង និងតំបន់ជុំវិញ។ យើងអាចសង្កេតឃើញពីស្ថិតិអំពីការដាំដុះ និងការប៉ាន់ស្មានបរិមាណផលដំណាំនៅឆ្នាំ២០២១ បានដូចខាងក្រោម៖

| ល.រ | ខេត្ត | ផ្ទៃដីដាំដុះ (ហ.ត) | | ទិន្នផល | បរិមាណផល | ការប៉ាន់ស្មានបរិមាណផលតាមខែ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ផ្ទៃដីប្រមូលផល | តោន/ហ.ត | (តោន) | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ |
| ១ | បន្ទាយមានជ័យ | 799 | 478 | 15.60 | 7,457 | 373 | 447 | 2,237 | 2,983 | 1,044 | 75 | 298 |
| ២ | បាត់ដំបង | 6,050 | 5,367 | 16.17 | 86,784 | 4,339 | 5,207 | 26,035 | 34,714 | 12,150 | 868 | 3,471 |
| ៣ | កំពង់ចាម | 255 | | | | | | | | | | |
| ៤ | កំពង់ឆ្នាំង | 35 | | | | | | | | | | |
| ៥ | កំពត | 38 | 26 | 15.00 | 390 | 18 | 22 | 109 | 146 | 51 | 14 | 30 |
| ៦ | កោះកុង | 22 | | | | | | | | | | |
| ៧ | ក្រចេះ | 9 | | | | | | | | | | |
| ៨ | ព្រះវិហារ | 47 | | | | | | | | | | |
| ៩ | ពោធិ៍សាត់ | 276 | 61 | 13.00 | 793 | 222 | 119 | 190 | 159 | 92 | 11 | |
| ១០ | រតនគិរី | 1,277 | 702 | 13.60 | 9,547 | 315 | 189 | 252 | 237 | 6,057 | 1,250 | 1,247 |
| ១១ | ស្ទឹងត្រែង | 235 | | | | | | | | | | |
| ១២ | ឧត្តរមានជ័យ | 81 | 43 | 12.00 | 516 | 52 | 155 | 155 | 15 | 31 | 31 | 77 |
| ១៣ | ប៉ៃលិន | 4,389 | 250 | 15.00 | 3,750 | 363 | 1,125 | 1,125 | 113 | 220 | 210 | 594 |
| ១៤ | ត្បូងឃ្មុំ | 95 | | | | | | | | | | |
| **សរុប** | | **13,608** | **6,927** | | **109,237** | **5,682** | **7,264** | **30,103** | **38,367** | **19,645** | **2,459** | **5,717** |

ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

តាមរយៈទិន្នន័យខាងក្រោមនេះ យើងអាចសង្កេតឃើញថាបរិមាណទិន្នផលដំណាំមៀនប៉ៃលិនក្នុងតំបន់ផ្សេងៗនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ២០២១ មានសរុប ១០៩,២៣៧ តោន ដែលសម្រាប់ខេត្តបាត់ដំបងដាំមៀនប៉ៃលិនបានច្រើនបំផុត ដែលមានទិន្នផលបរិមាណសរុប ៨៦,៧៨៤ តោន។ ខេត្តរតនគិរីប្រមូលបានទិន្នផល ៩,៥៤៧ តោន, ខេត្តបន្ទាយមានជ័យប្រមូលបាន ៧,៤៥៧ តោន, ខេត្តពោធិ៍សាត់ប្រមូលបាន ៧៩៣ តោន, ខេត្តឧត្តរមានជ័យប្រមូលបាន ៥១៦ តោន, និងខេត្តកំពតប្រមូលបាន ៣៩០ តោន។

ការសង្កេតឃើញនេះបង្ហាញថា ខេត្តបាត់ដំបងមានបរិមាណផលដំណាំមៀនប៉ៃលិនច្រើនជាងខេត្តដទៃទៀត។ ទិន្នន័យនេះបញ្ជាក់ពីសារសំខាន់នៃខេត្តបាត់ដំបងក្នុងការផលិត និងចែកចាយមៀនប៉ៃលិន ដោយវាជាគោលការណ៍សំខាន់ក្នុងការបង្ហាញពីសមត្ថភាពនៃការដាំដុះនិងផលិតផលក្នុងតំបន់។ ប្រសិនបើពិនិត្យការប្រើប្រាស់ធនធានដីនិងបច្ចេកទេសកសិកម្ម នឹងឃើញថាការរីកចម្រើននៃការប្រមូលផលនៅក្នុងខេត្តបាត់ដំបងអាចធ្វើអោយវាជាអាជីវកម្មធំមួយនិងសំខាន់សម្រាប់សេដ្ឋកិច្ចក្នុងតំបន់។

## ១.១២. គោលនយោបាយ និងការគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ដំណាំម្រៀនប៉ៃលិន

ការគាំទ្ររបស់រដ្ឋាភិបាលនៅក្នុងវិស័យកសិកម្មសម្រាប់ដំណាំមៀនប៉ៃលិនគឺមានសារសំខាន់បំផុតក្នុងការធានាថាកសិករខ្មែរអាចចូលរួមក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារអន្តរជាតិ។ ការគាំទ្រនេះបានអនុញ្ញាតឱ្យមានការរីកចម្រើននិងភាពរីកចម្រើនជាបន្តជាសំខាន់ សម្រាប់សេដ្ឋកិច្ចកសិកម្មនៅក្នុងប្រទេសកម្ពុជា។ រដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយនិងវិធានការផ្សេងៗ ដើម្បីជួយសម្រួលនិងលើកកម្ពស់វិស័យកសិកម្ម ដោយផ្តោតលើការចូលរួមរបស់វិស័យឯកជន និងការធានាថាកសិករទទួលបានការគាំទ្រដែលត្រឹមត្រូវក្នុងការដាំដុះ និងផលិតផលមៀនប៉ៃលិន។ នេះរួមមានការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ ការផ្តល់ប្រាក់កម្ចីដែលមានការប្រាក់ទាប និងការចេញនូវគោលការណ៍ស្តីពីការធានាដែលអាចជួយកាត់បន្ថយហានិភ័យសម្រាប់កសិករ។ រដ្ឋាភិបាលក៏បានលើកទឹកចិត្តឱ្យមានការប្រើប្រាស់បច្ចេកវិទ្យា និងវិចារណញ្ញាណថ្មីៗក្នុងការដាំដុះ និងផលិតផលដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្ម និងទំនុកចិត្តក្នុងទីផ្សារអន្តរជាតិ។ ក្រៅពីនេះ ការគាំទ្ររបស់រដ្ឋាភិបាលក៏បានផ្តោតលើការគ្រប់គ្រងការប្រែប្រួលអាកាសធាតុដែលអាចប៉ះពាល់ដល់កសិកម្ម ដូចជាភាពរាំងស្ងួតដោយសារដោយគ្រោះមហន្តរាយធម្មជាតិ និងការបន្ថយផលប៉ះពាល់ជាលក្ខណៈអនាមិក។ ការលើកកម្ពស់នៃការបង្កើតសហគមន៍កសិកម្ម និងការអភិវឌ្ឍសហគ្រាសកសិកម្មជាពិសេសសម្រាប់ដំណាំមៀនប៉ៃលិន ក៏ជាសាច់រឿងមួយដែលរដ្ឋាភិបាលបានបង្កើនការគាំទ្រ។ រដ្ឋាភិបាលក៏បានពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយផ្តល់ជំនួយផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុ ដែលអាចជួយកសិករកម្ពុជាឱ្យមានភាពរឹងមាំក្នុងការដាំដុះដំណាំមៀនប៉ៃលិន និងធានាបាននូវការសម្រេចបាននូវគុណភាពនៃផលិតផលតាមស្តង់ដារអន្តរជាតិ។

### ១.១២.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣

រដ្ឋាភិបាលកម្ពុជានៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ បានកំណត់គោលដៅច្បាស់លាស់សម្រាប់ការរីកចម្រើននៃវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាពកសិកម្ម, ការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ, និងការលើកកម្ពស់ការនាំចេញនៃផលិតផលកសិកម្ម។ សម្រាប់ការដាំដុះមៀនប៉ៃលិន, ផែនការយុទ្ធសាស្ត្រនេះបានផ្តោតសំខាន់លើការលើកស្ទួយការតភ្ជាប់កសិករក្នុងបណ្តាញផលិតកម្ម និងការទាក់ទងតាមគម្រោងនិងក្រុមហ៊ុនពាក់ព័ន្ធ ដើម្បីធានាថាផលិតផលដែលបានផលិតអាចចូលទៅក្នុងទីផ្សារដែលមានតម្រូវការខ្ពស់នៅកាន់ក្នុងប្រទេស និងអន្តរជាតិ។[36]

[36] Ministry of Agriculture, Forestry and Fisheries (MAFF). *សៀវភៅ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣.*

### ១.១២.២. ការបង្កើតគម្រោង និងកម្មវិធីជំរុញ

រដ្ឋាភិបាលកម្ពុជា បានចាប់ផ្ដើមគម្រោង និងកម្មវិធីជាច្រើនដើម្បីជំរុញដំណាំមៀនប៉ៃលិន ហើយបានអនុវត្តន៍យ៉ាងសកម្មក្នុងការលើកស្ទួយវិស័យកសិកម្មនេះ។ ក្នុងចំណោមកម្មវិធីដែលបានដាក់ចូលដំណើរការមានការផ្ដល់កម្ចីឥណទានឥតការប្រាក់ ឬមានការប្រាក់ទាបសម្រាប់កសិករដែលចាប់អារម្មណ៍ក្នុងការដាំដុះដំណាំមៀនប៉ៃលិន។ កម្ចីឥណទាននេះមានចំណុចសំខាន់នៃការលើកកម្ពស់កសិកម្មដោយផ្ដល់ធនធានឱ្យកសិករអាចទិញឧបករណ៍ និងគ្រឿងចក្រ ឬចំនាយលើការកែលម្អវិធីសាស្ត្រការដាំដុះ។

ជាពិសេស កម្មវិធីបច្ចេកទេសដែលត្រូវបានបង្កើតឡើង មានន័យសំខាន់ក្នុងការផ្ដល់នូវការបណ្ដុះបណ្ដាល និងចំណេះដឹងថ្មីៗដល់កសិករ ដើម្បីធានាថាផលិតភាពនិងគុណភាពរបស់ផ្លែមៀនប៉ៃលិនសមស្របទៅនឹងតម្រូវការទីផ្សារអន្តរជាតិ។ ក្រៅពីនេះ រដ្ឋាភិបាលក៏បានបង្កើតគម្រោងសហគមន៍កសិកម្ម ដោយផ្ដោតលើការបង្កើតបណ្ដាញសហការ រវាងកសិករដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការចែករំលែកបទពិសោធន៍។

ការដាក់ចូលដំណើរការគម្រោងផ្សព្វផ្សាយ និងផ្សព្វផ្សាយដំណឹងអំពីតម្លៃ និងគុណភាពផលិតផលនៅទីផ្សារក៏បានជួយពង្រីកទីផ្សារនិងសម្រួលការលក់ផលិតផលកសិកម្មដោយផ្ដោតលើតម្លៃបន្ថែមនៃផ្លែមៀនប៉ៃលិន។ រដ្ឋាភិបាលក៏បានចូលរួមអនុវត្តគម្រោងសម្រួលលើការដឹកជញ្ជូន និងការផ្គត់ផ្គង់វត្ថុធាតុដើម ដែលអាចជួយកាត់បន្ថយការចំណាយផលិតកម្ម និងធានាការផ្ដល់ផលិតផលដល់ទីផ្សារពេលដែលត្រូវការ។

### ១.១២.៣. ការផ្ដល់បច្ចេកទេស និងការបណ្ដុះបណ្ដាល

រដ្ឋាភិបាលកម្ពុជា បានផ្ដល់ការគាំទ្រដល់កសិករ តាមរយៈការផ្ដល់បច្ចេកទេសនិងការបណ្ដុះបណ្ដាលសម្រាប់ការដាំដុះមៀនប៉ៃលិន ដើម្បីធានានូវផលិតភាពខ្ពស់ និងគុណភាពដែលសាកសមនឹងទីផ្សារអន្តរជាតិ។ ក្រសួងកសិកម្មបានសហការជាមួយវិស័យឯកជន ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលពិសេសដល់កសិករ និងសហគមន៍កសិករ ដោយបង្កើតសាកលវិទ្យាល័យកសិកម្ម និងវិទ្យាស្ថានបច្ចេកវិទ្យា។

បើយោងតាមរបាយការណ៍របស់មន្ទីរកសិកម្មខេត្តបាត់ដំបង ទូទាំងខេត្តបាត់ដំបងបច្ចុប្បន្នមានផ្ទៃដីដីដាំដុះមៀនសរុប ៦៥៦៣ហិកតា ក្នុងនោះមៀនប៉ៃលិន (តាង៉ែន) ចំនួន ៦០៥០ហិកតា។ មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្ត បានធ្វើ ការបណ្ដុះបណ្ដាលដល់កសិករដាំមៀនប៉ៃលិន ចំនួន ២៦៧នាក់ ក្នុងនោះនៅស្រុកកំរៀងចំនួន ៣៦នាក់ ស្រុកភ្នំព្រឹក ៩៤នាក់ ស្រុករតនៈមណ្ឌល ៣៥ នាក់ស្រុកសំពៅលូន ២២នាក់ និងមកពីបណ្ដាស្រុកផ្សេង ចំនួន ២៦នាក់ ព្រមទាំងកសិករក្នុងកម្មវិធី ASPIRE ចំនួន ៥៤នាក់ផងដែរ។[37]

[37] Kampuchea Thmey. (2023). *Pailin longan export to China in 2023 is booming.* Retrieved from

### ១.១២.៤. ការគាំទ្រដើម្បីការនាំចេញ

រដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយសន្តិសុខអាហារ និងការកែសម្រួលប្រព័ន្ធផ្គត់ផ្គង់ ដើម្បីបង្កើនការចូលទៅក្នុងទីផ្សារអន្តរជាតិ។ រដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយសន្តិសុខអាហារ និងការកែសម្រួលប្រព័ន្ធផ្គត់ផ្គង់ ដើម្បីបង្កើនការចូលទៅក្នុងទីផ្សារអន្តរជាតិ។ ក្រសួងពាណិជ្ជកម្មកម្ពុជា បានសហការជាមួយក្រសួងកសិកម្ម ដើម្បីសម្រួលការនាំចេញមៀនប៉ៃលិនទៅទីផ្សារចិន, ថៃ, និងទីផ្សារប្រទេសផ្សេងៗទៀត ដោយជំរុញឱ្យកសិករប្រើប្រាស់បច្ចេកវិទ្យាសមស្របនិងបច្ចេកទេសថ្មីៗក្នុងការផលិត និងកែច្នៃផលិតផលរបស់ពួកគេ។

### ១.១២.៥. ការសហការជាមួយវិស័យឯកជន

រដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ បានពង្រឹងការសហការជាមួយវិស័យឯកជន ដើម្បីជួយសម្រួលការអភិវឌ្ឍន៍និងពង្រឹងបណ្តាញចែកចាយនិងការនាំចេញមៀនប៉ៃលិនទៅទីផ្សារអន្តរជាតិ។ ជាក់ស្តែងកាលពីឆ្នាំ ២០២២ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA) បានចុះហត្ថលេខាលើអនុស្សរណៈជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) ដើម្បីអនុវត្តគម្រោងផ្តល់ឥណទានគាំទ្រដល់ការពង្រីកការដាំដុះបន្លែ-ផ្លែឈើ, ការចិញ្ចឹមសត្វ, វារីវប្បកម្ម, និងការកែច្នៃផលិតផលកសិកម្ម។ កិច្ចសហប្រតិបត្តិការនេះផ្តោតទៅលើការផ្តល់ឥណទានដល់តួអង្គក្នុងខ្សែច្រវាក់ផលិតកម្មក្នុងវិស័យមៀនប៉ៃលិន, ស្វាយ, និងស្វាយចន្ទី។

### ១.១២.៦. កម្មវិធីហិរញ្ញប្បទានពិសេស

ដើម្បីបន្តជួយគាំទ្រផ្តល់ឥណទានកសិកម្មក្នុងអត្រាការប្រាក់សម្បទាន ដល់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យកសិកម្ម កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២, រាជរដ្ឋាភិបាល តាមរយៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យប្រើប្រាស់ ជាផ្លូវការ នូវកញ្ចប់ថវិកាកម្មវិធីហិរញ្ញប្បទានពិសេស ដំណាក់កាលទី២ ដោយមានទឹកប្រាក់ចំនួន ៥០ លានដុល្លារអាមេរិក សម្រាប់ប្រើប្រាស់លើការផ្តល់ហិរញ្ញប្បទានផ្ទាល់ (Direct Lending) និងសម្រាប់កម្មវិធីសហហិរញ្ញប្បទានចែករំលែកហានិភ័យជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ កម្មវិធីនេះមានគោលបំណងចំបងក្នុងការគាំទ្រដល់ការដាំដុះបន្លែ-ផ្លែឈើ, ការចិញ្ចឹមសត្វ, វារីវប្បកម្ម, ការកែច្នៃផលិតផលកសិកម្ម, និងការផ្តល់ឥណទានគាំទ្រតួអង្គក្នុងខ្សែច្រវាក់ផលិតកម្មវិស័យមៀនប៉ៃលិន, ស្វាយ, និងស្វាយចន្ទី។[38]

https://www.kampucheathmey.com/local-news/184905

[38] Fresh News. "ធនាគារ ARDB និង ធនាគារអេស៊ីលីដា សហការអនុវត្តគម្រោងផ្តល់ឥណទាន គាំទ្រដល់ការពង្រីកការដាំដុះ

## ១.១៣. ទស្សនវិស័យពេលអនាគតសម្រាប់ដំណាំម្ទៀនប៉ៃលិន

### ១.១៣.១. ទីផ្សារអន្តរជាតិ

ការលូតលាស់នៃទីផ្សារអន្តរជាតិគឺមានប្រសិទ្ធភាពខ្ពស់សម្រាប់ដំណាំមៀនប៉ៃលិន។ ពីព្រោះតំបន់ខាងជើងនៃទ្វីបអាស៊ីដូចជា ចិន និងថៃ គឺជាភាគីទទួលបានផលិតផលមៀនគ្រប់គ្រងក្នុងទីផ្សារអន្តរជាតិ។ ជាពិសេស ចិនបានទទួលស្គាល់សរុបពីការនាំចេញរបស់កម្ពុជា និងមានការព្យាយាមចង់ទិញច្រើនឡើង។ ក្នុងការព្យាករណ៍ឯកសារបច្ចុប្បន្ន បានរាយការណ៍ថា ការទទួលបានស្វ័យប្រវត្តិ និងការតម្រូវការរបស់ទីផ្សារបរទេសនឹងកើនឡើង។ ជាទំនាក់ទំនងនឹងការកើនឡើងនៃការចំណាយនៅក្នុងកន្លែងដែលមានចំណូលខ្ពស់និងកំណត់ផែនការផលិតនូវគុណភាព និងចំនួនផ្លែចំនួនធំក្នុងស្រុកនឹងពង្រឹងសមត្ថភាពនៃការផ្គត់ផ្គង់ទីផ្សារ។

### ១.១៣.២. ការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលដ៏សំខាន់លើការបង្កាប់នៃការដាំដុះមៀនប៉ៃលិន។ ការកើនឡើងនៃសីតុណ្ហភាព និងការប្រែប្រួលរបស់ភេសជ្ជៈអាកាសធាតុអាចបណ្តាលឱ្យមានការផ្លាស់ប្តូរនៅក្នុងកម្រិតនៃប្រភពទឹក និងការកើនឡើងនៃការប្រហែលការលំបាកលើកម្រិតនៃសារៈសំខាន់ដូចជាការប្រយុទ្ធនឹងជំងឺ និងសត្វល្អិត។ ប៉ុន្តែ អ្នកជំនាញក៏ព្យាករណ៍ថាបច្ចេកវិទ្យានិងវិធីសាស្រ្តថ្មីៗនឹងអាចជួយសម្រួលការប្តូរនេះនិងទប់ស្កាត់ការប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

### ១.១៣.៣. ការអភិវឌ្ឍបច្ចេកវិទ្យា

ការអភិវឌ្ឍបច្ចេកវិទ្យានឹងមានឥទ្ធិពលលើការដាំដុះមៀនប៉ៃលិន។ បច្ចេកវិទ្យាថ្មីៗដូចជា បច្ចេកវិទ្យាអេឡិចត្រូនិច សង្គមបច្ចេកទេស សំភារៈនិងការគ្រប់គ្រងជីវភាពនឹងជួយកសិករជួយក្នុងការកែលម្អការផលិត។ ការចូលរួមរបស់ការចិញ្ចឹមសត្វឥតគ្រោះ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗនឹងឲ្យការសម្រេចល្អប្រសើរនៃការដាំដុះ។ វិធីសាស្រ្តសហការនឹងសម្រួលការប្រកួតប្រជែងនឹងអនុញ្ញាតឱ្យមានការប្រើប្រាស់ទាំងមូលនិងធានាប្រសិទ្ធភាពនៅលើផលិតផលដែលផលិត។

## ១.១៤. ការណែនាំសម្រាប់កសិករ និងរាជរដ្ឋាភិបាល

### ១.១៤.១. សម្រាប់កសិករ

ការណែនាំសម្រាប់កសិករ គឺសំខាន់ក្នុងការបង្កើនសមត្ថភាពទាំងនៅវិស័យកសិកម្ម ដែលមានដូចខាងក្រោម ៖

---

បន្លែ-ផ្លែឈើ ការចិញ្ចឹមសត្វ វារីវប្បកម្ម និងការកែច្នៃផលិតផលកសិកម្ម". Retrieved from https://shorturl.at/DqfBl

- ការអនុវត្តបច្ចេកវិទ្យាថ្មី: កសិករត្រូវតែអនុវត្តបច្ចេកវិទ្យាថ្មីៗដូចជាការសម្រួលប្រភពទឹក, ការកែប្រែពហុបច្ចេកទេសសាកល្បងថ្មីៗ និងការបង្កើនផលិតភាពរបស់កសិករ។
- ការអភិវឌ្ឍគុណភាពផលិតផល: ផ្តោតលើការពង្រឹងគុណភាពនៃផលិតផល ដើម្បីជួយផ្តល់ផលិតផលដែលមានភាពល្អបំផុតសម្រាប់ទីផ្សារ និងបំពេញតម្រូវការទាំងអស់។
- ការចូលរួមក្នុងបណ្តាញជួញដូរ: ចូលរួមក្នុងបណ្តាញជួញដូរជាសកល ដើម្បីបង្កើតឱកាសថ្មីៗនិងការតភ្ជាប់ស៊ុតតែល្អជាមួយទីផ្សារបរទេស។
- ការកែលម្អការគ្រប់គ្រងជីវភាព: ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងជីវភាពដើម្បីការពារបញ្ហា និងការរីវត្តនៃជំងឺនិងសត្វល្អិត។

### ១.១៤.២. សម្រាប់រាជរដ្ឋាភិបាល

- ការគាំទ្រផ្នែកហិរញ្ញវត្ថុ: ផ្តល់ការគាំទ្រក្នុងការប្រើប្រាស់សំណង់និងបច្ចេកវិទ្យាថ្មីៗ ដើម្បីអនុញ្ញាតឱ្យមានការរីវត្តន៍ក្នុងវិស័យកសិកម្ម។
- ការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ: អភិវឌ្ឍន្ទូវគម្រោងសម្រួលការប្រែប្រួលអាកាសធាតុ ដើម្បីធានាថាបានការគ្រប់គ្រងល្អលើការប៉ះពាល់ដែលអាចកើតឡើង។
- ការបង្កើត និងអភិវឌ្ឍគម្រោងសហការជាមួយវិស័យឯកជន: ធានាបានសហការជាមួយវិស័យឯកជនដើម្បីជួយពង្រឹងការចូលរួមនិងការកែលម្អផលិតភាពក្នុងវិស័យកសិកម្ម។
- ការផ្តល់សេវាកម្ម និងអប់រំ: ផ្តល់ការបណ្តុះបណ្តាល និងអប់រំនូវព័ត៌មានថ្មីៗសម្រាប់កសិករ ដើម្បីឲ្យពួកគេមានជំនាញនិងអាចប្រើប្រាស់បច្ចេកវិទ្យាថ្មីៗបាន។

## ១.១៥. ឥទ្ធិពលសង្គមដែលកើតមានអំពីកសិកម្មម្រៀនប៉ៃលិន

### ១.១៥.១. ការងារ និងជីវភាពរស់នៅ

កសិកម្មម្រៀនប៉ៃលិនគឺជាកសិកម្មដែលមានសារៈសំខាន់ជាងគេនៅក្នុងតំបន់ប៉ៃលិន ហើយវាបានបង្កើតឱកាសការងារជាច្រើនសម្រាប់ប្រជាជនក្នុងតំបន់នេះ។ កសិករជាច្រើនបានអភិវឌ្ឍជំនាញនៃការដាំដុះនិងការផលិតម្រៀនដែលមានគុណភាពខ្ពស់ ហើយបានចាប់ផ្តើមរកចំណូលសម្រាប់គ្រួសាររបស់ពួកគេ។ តាមរយៈការផលិតម្រៀនប៉ៃលិន កសិករក៏បានអាចពង្រីកការរកចំណូលរបស់ពួកគាត់ តាមរយៈការលក់ផលិតផលទាំងនេះក្នុងទីផ្សារជាតិ និងអន្តរជាតិ។

ការរីកចម្រើននៃការងារដែលទាក់ទងនឹងកសិកម្មម្រៀនប៉ៃលិនបាននាំឱ្យមានភាពរឹងមាំនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជីវភាពរស់នៅរបស់កសិករមានការអភិវឌ្ឍន៍ល្អឡើងមក ដោយសារតែមានប្រាក់ចំណូលបន្ថែមពីការលក់ផលិតផល។ កសិករអាចទិញបានអាហារដែលមានគុណភាពល្អ កែលម្អសុខភាព និងសុខុមាលភាពរបស់គ្រួសាររបស់ពួកគេ។ លើសពីនេះ ការរីកចម្រើននៃការងារនេះក៏បានជួយកាត់បន្ថយការធ្វើចំណាកស្រុកទៅទីក្រុង ឬការរកការងារស្រួលធ្វើនៅប្រទេសជិតខាង ដោយធានាថាការរស់នៅនៅក្នុងសហគមន៍កសិកម្មគឺមានសុភមង្គល និងការរួមរស់ដោយជោគជ័យ។

## ១.១៥.២. ការអភិវឌ្ឍសហគមន៍

### ១.១៥.២.១. ស្ថិរភាពសេដ្ឋកិច្ច

ការបង្កើនផលិតភាពក្នុងវិស័យកសិកម្មម្រៀនប៉ៃលិនគឺមានឥទ្ធិពលធំបំផុតទៅលើស្ថិរភាពសេដ្ឋកិច្ចនៅក្នុងសហគមន៍។ ដោយសារតែមានការចំណាយវិនិយោគក្នុងការលើកកម្ពស់ផលិតភាព និងគុណភាពនៃផលិតផល កសិករបានអាចផលិតផលិតផលដែលមានតំលៃខ្ពស់ និងមានតំរូវការច្រើននៅក្នុងទីផ្សារដែលកំពុងមានការអភិវឌ្ឍន៍យ៉ាងលឿន។ វាអាចបង្ហាញបានថា កសិកម្មម្រៀនប៉ៃលិនមិនត្រឹមតែជាភាសសម្រាប់ការរីកចម្រើនសេដ្ឋកិច្ចនៅក្នុងតំបន់ប៉ៃលិនទេ ប៉ុន្តែវាក៏ជាមូលដ្ឋានសម្រាប់ការរីកចម្រើនសម្រាប់ប្រជាជនក្នុងសហគមន៍ផ្សេងទៀតនៅក្នុងប្រទេស។

ស្ថិរភាពសេដ្ឋកិច្ចដែលបណ្តាលមកពីការដាំដុះ និងផលិតម្រៀនប៉ៃលិនក៏មានការប៉ះពាល់ដល់ការអភិវឌ្ឍន៍សហគមន៍។ ប្រជាពលរដ្ឋនៅក្នុងតំបន់ដែលពាក់ព័ន្ធនឹងការដាំដុះម្រៀនបានឃើញការកើនឡើងនៃការងារ និងការបង្កើតក្រុមហ៊ុនផលិតកម្មដែលជាធ្នូការបញ្ជូនម្រៀនទៅទីផ្សារ។ វាជាប្រភេទនៃការរីកចម្រើនដែលបានជួយសង្គ្រោះសហគមន៍ទាំងមូល ពីការរស់នៅដោយភាពក្រីក្រ និងភាពងាយខូចរបស់សហគមន៍កសិកម្ម។

### ១.១៥.២.២. ការអប់រំ និងសុខភាព

ការរីកចម្រើនក្នុងវិស័យកសិកម្មម្រៀនប៉ៃលិនមានសារសំខាន់បំផុតទៅលើការកែលម្អគុណភាពការអប់រំ និងសុខភាពនៅក្នុងសហគមន៍កសិកម្ម។ ការរកចំណូលតាមការលក់ម្រៀនបានផ្តល់ឱកាសសម្រាប់កសិករបានវិនិយោគក្នុងការអប់រំកូនៗរបស់ពួកគេ។ បុព្វជន និងកូនៗដែលធ្វើការសិក្សានៅវិទ្យាល័យ និងសាកលវិទ្យាល័យមានឱកាសល្អសម្រាប់ការរៀនសូត្រច្រើនជាងមុន ហើយក៏មានការគាំទ្រច្រើនពីឪពុកម្តាយដែលមានប្រាក់ចំណូលខ្ពស់។

លើសពីនេះ ការរីកចម្រើននៃកសិកម្មក៏បានឱ្យសហគមន៍បានចំណាយច្រើនលើសុខភាព ដោយការទិញសេវាសុខភាពប្រសើរជាងមុន និងការដឹកនាំលើកទឹកចិត្តសម្រាប់ការរស់នៅមានសុខភាពល្អ។ វាអាចសង្កេតឃើញថា កសិករដែលមានជីវភាពសេដ្ឋកិច្ចល្អច្រើនពេញចិត្តក្នុងការថែរក្សាសុខភាពដោយការទិញថ្នាំ និងបរិភោគអាហារដែលមានគុណភាពខ្ពស់។

## ១.១៥.៣. ទំនាក់ទំនងវប្បធម៌ និងសង្គម

### ១.១៥.៣.១. ការអភិរក្សប្រពៃណីកសិកម្ម

កសិកម្មមៀនប៉ៃលិនគឺជាមជ្ឈមណ្ឌលសំខាន់មួយក្នុងការអភិរក្សប្រពៃណីកសិកម្មដ៏សំខាន់នៅក្នុងតំបន់។ វាបានជួយធានាថាមេរៀននិងជំនាញកសិកម្មត្រូវបានបន្តចែកចាយទៅកាន់ជំនាន់ក្រោយ។ កសិករដែលមានបទពិសោធន៍ក្នុងការដាំដុះ និងផលិតមៀនបានបន្តការបង្រៀនកូនៗ និងកសិករអ្នកថ្មី ដែលចង់សិក្សាពីការដាំដុះ និងផលិតមៀន។ ការអភិរក្សនេះក៏បានធ្វើឱ្យមានភាពរីកចម្រើននៃការបន្តប្រពៃណី និងវប្បធម៌កសិកម្មដែលមានអត្ថន័យសំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងតំបន់។ វាក៏ជួយពង្រឹងឱ្យកាន់តែមានការដោះស្រាយបញ្ហាក្នុងការរស់នៅរបស់កសិករដែលមានបទពិសោធន៍ក្នុងវិស័យកសិកម្មនេះ។

### ១.១៥.៣.២. ការរួមរស់ក្នុងសង្គម

ការរួមរស់ក្នុងសង្គមត្រូវបានពង្រឹងតាមរយៈការធ្វើកសិកម្មមៀនប៉ៃលិន។ ការរីកចម្រើននៃការផលិតមៀនបានបង្កើតឱកាសសម្រាប់ការរួមរស់ក្នុងសង្គមជាមួយសហគមន៍កសិកម្មដែលមានជីវិតសាមញ្ញ។ កសិករដែលពាក់ព័ន្ធនឹងការដាំដុះមៀនបានរួមគ្នាស្ថាបនាក្រុមហ៊ុន និងសហគមន៍នានា ដើម្បីឱ្យមានភាពរួមបញ្ចូលគ្នានៃប្រព័ន្ធកសិកម្ម។ ការរីកចម្រើននៃកសិកម្មមៀនប៉ៃលិនក៏បានជួយបង្កើតទំនាក់ទំនងសហគមន៍ដែលរឹងមាំ និងអាចឆ្លើយតបទៅនឹងបញ្ហានានា។ ទំនាក់ទំនងរវាងកសិករ ក្រុមហ៊ុនផលិតកម្ម និងសហគមន៍នានាអាចជួយក្នុងការបង្កើនការរួមចំណែកនៃការអភិវឌ្ឍសហគមន៍ និងជួយបន្ថែមភាពអំណោយផលក្នុងការរួមរស់ក្នុងសង្គម។

## ១.១៥.៤. បញ្ហាប្រឈម និងបញ្ហាសង្គម

### ១.១៥.៤.១. លក្ខខណ្ឌការងារ

ក្នុងអំឡុងពេលដែលការងារកើតមានកាន់តែច្រើនមានបញ្ហាប្រឈមដែលកសិករគួរតែបានអនុវត្តយ៉ាងប្រុងប្រយ័ត្ន។ លក្ខខណ្ឌការងារដែលមានភាពល្អកាន់តែច្រើនក៏មានការរំពឹងទុកនៃការរីកចម្រើននៃសុខុមាលភាពរបស់អ្នកបំពេញការងារ។ បញ្ហាប្រឈមនៃលក្ខខណ្ឌការងារមានអត្ថន័យយ៉ាងសំខាន់សម្រាប់ការរស់នៅ

របស់អ្នកធ្វើការរស់នៅក្នុងតំបន់ដែលធ្វើកសិកម្មមៀនប៉ៃលិន។ ការបង្កើតស្ថានភាពដែលល្អសម្រាប់ការងារគឺសំខាន់សម្រាប់ការអភិវឌ្ឍន៍សុខុមាលភាពរបស់កសិករ។ កសិករដែលមានការងារល្អនឹងមានការរៀបចំស្រេចសម្រាប់ការរស់នៅ និងការកែលម្អបរិយាកាសនៅក្នុងសហគមន៍។

**១.១៥.៤.២. ការធ្វើចំណាកស្រុក និងនគរូបនីយកម្ម**

ការអភិវឌ្ឍកសិកម្មអាចបណ្តាលឱ្យមានការធ្វើចំណាកស្រុកពីជនបទទៅកាន់ទីក្រុង។ កសិករដែលត្រូវរុះរើចេញពីតំបន់កសិកម្មនឹងពេញចិត្តច្រើនទៅរកទីក្រុងដើម្បីស្វែងរកឱកាសការងារបានកាន់តែច្រើន និងមានចំណូលកាន់តែខ្ពស់។

បញ្ហាប្រឈមនៃការចំណាកស្រុកទៅកាន់ទីក្រុងក៏មានការពង្រឹងនៃការអភិវឌ្ឍនគរូបនីយកម្ម ដែលសម្រេចបានដោយការលើកទឹកចិត្តឱ្យមានការបង្កើនបរិមាណកសិករ និងការកែលម្អបរិយាកាសនៃទីក្រុង។

**១.១៥.៥. ការយល់ដឹងអំពីបរិស្ថាន និងនិរន្តរភាព**

កសិកម្មមៀនប៉ៃលិនបានជួយពង្រឹងការយល់ដឹងអំពីបរិស្ថាន និងនិរន្តរភាពក្នុងសហគមន៍កសិកម្ម។ កសិករដែលចូលរួមក្នុងវិស័យកសិកម្មមៀនបានទទួលយកបច្ចេកទេសនិងការអនុវត្តកសិកម្មដែលមានភាពនិរន្តរភាព និងការអភិរក្សធនធានធម្មជាតិ។ ការគាំទ្រនៃការដាំដុះមៀនប៉ៃលិនបានធានាឱ្យប្រជាពលរដ្ឋនៅក្នុងសហគមន៍មានឱកាសសម្រាប់ការរស់នៅនិងការងារដែលមានភាពរីកចម្រើន។

ការយល់ដឹងអំពីបរិស្ថានបានក្លាយជាភាពសំខាន់សម្រាប់កសិករដែលចូលរួមក្នុងវិស័យកសិកម្មនេះ។ ការអនុវត្តនិងបច្ចេកទេសនានាដែលទាក់ទងនឹងបរិស្ថាន និងនិរន្តរភាពបានជួយបង្កើតឱកាសដែលកសិករអាចរក្សាភាពរស់រវើកនៃបរិយាកាសនៃសហគមន៍។ ពីនេះទៅ ការរស់នៅរបស់កសិករនិងប្រជាពលរដ្ឋមានភាពល្អ និងជៀសវាងបញ្ហាដែលប៉ះពាល់ដល់បរិស្ថាន។

**១.១៥.៦. ការសហការរវាងកម្ពុជា និងប្រទេសនាំចូល**

នៅកម្ពុជា មានចំនួន ៧៤ ចម្ការ ដែលបានចុះបញ្ជីជាផ្លូវការឱ្យនាំចេញផ្លែមៀនទៅកាន់ទីផ្សារចិន ដែលក្នុងនោះ ៤០ ចម្ការស្ថិតនៅខេត្តប៉ៃលិន, ២៨ ចម្ការនៅខេត្តបាត់ដំបង, និង ៦ ចម្ការនៅខេត្តបន្ទាយមានជ័យ។ អមជាមួយនឹងរោងចក្រវេចខ្ចប់ ៨ រោងចក្រ ដែលមានទីតាំងនៅខេត្តកណ្តាល, ខេត្តបាត់ដំបង, ខេត្តប៉ៃលិន, និងព្រះសីហនុ។ ផ្ទៃដីដាំដុះមៀនទូទាំងប្រទេសរបស់កម្ពុជាមានចំនួន ១៣,៦០៨ ហិកតា ដែលស្ថិតនៅក្នុងខេត្តចំនួន៤។

អគ្គនាយកដ្ឋានកសិកម្ម បានចុះបញ្ជីចម្ការមៀន និងរោងចក្រវេចខ្ចប់សម្រាប់នាំចេញផ្លែមៀនស្រស់កម្ពុជាទៅកាន់ប្រទេសចិន បានចំនួន ៩៧ក្រុមហ៊ុននិងម្ចាស់ចម្ការ និង ១២រោងចក្រវេចខ្ចប់ និងទទួលបានការអនុម័តទទួលស្គាល់ជាផ្លូវការពីអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន (GACC)។ ក្រៅពីការនាំចេញទៅកាន់ទីផ្សារប្រទេសចិន សហគ្រាសនៅកម្ពុជាកំពុងកែច្នៃផ្លែមៀនស្រស់របស់ខ្មែរ ទៅជាដំណាប់មៀន ផ្លែមៀនកំប៉ុង ទឹកមៀនកៀប និងស្រាមៀន ដែលមានដាក់លក់នៅតាមផ្សារទំនើបនានានៅក្នុងប្រទេស។[39]

[39] Fresh News. Retrieved from https://freshnewsasia.com/index. php/en/localnews/318363-2023-11-20-05-42-47.html

# ជំពូកទី២

# ស្ថានភាពទូទៅនៃដំណាំមៀនប៉ៃលិន ឬតាម៉ែន

## ២.១. ប្រវត្តិនៃការដាំដុះដំណាំមៀនប៉ៃលិន និងទីតាំងភូមិសាស្ត្រ

### ២.១.១. ប្រវត្តិនៃការដាំដុះដំណាំមៀនប៉ៃលិន

ប្រវត្តិនៃការចាប់ផ្ដើមបង្កើតចម្ការសម្រាប់ដាំដំណាំមៀនប៉ៃលិន ឬតាម៉ែន របស់លោក ហ៊ាប សុភា កើតឡើងចេញអំពីការបំផុសគំនិត និងមហិច្ឆតាបន្ទាប់ពីសង្កេតឃើញភាពជោគជ័យនៅក្នុងវិស័យនេះពីអ្នកនៅជុំវិញខ្លួនរបស់លោកផ្ទាល់។ ដោយសង្កេតឃើញបងប្រុស និងមិត្តភក្ដិរបស់លោកទទួលបានភាពជោគជ័យគួរឱ្យកត់សម្គាល់ក្នុងវិស័យកសិកម្ម ជាពិសេសដំណាំមៀនប៉ៃលិន ឬតាម៉ែននេះ លោក ហ៊ាប សុភា ត្រូវបានជំរុញ និងលើកទឹកចិត្ត ហើយសម្រេចចិត្តដើរតាមគន្លងរបស់ពួកគេ ដោយជ្រើសរើសវិនិយោគទៅលើដំណាំកសិកម្មមៀនប៉ៃលិននេះ។

ដោយបានឃើញចម្ការរបស់បងប្រុស និងមិត្តភក្ដិទទួលបានទិន្នផល និងជោគជ័យខ្លាំង លោក ហ៊ាប សុភា ក៏មានចំណាប់អារម្មណ៍ បំផុសគំនិតក្នុងការបង្កើតអាជីវកម្មកសិកម្មផ្ទាល់ខ្លួនរបស់គាត់។ ដោយបានតាំងចិត្តក្នុងការកសាងចម្ការរបស់គាត់ពីចំណុចចាប់ផ្ដើមដំបូង លោកពូបានប្រឈមមុខនឹងបញ្ហាជាច្រើន ទាំងការស្វែងរកដីត្រឹមត្រូវ ការគ្រប់គ្រងនិងស្វែងរកមូលនិធិដើមទុន និងការគ្រប់គ្រងដំណាំអោយទទួលបានផលល្អ គឺជាឧបសគ្គដ៏សំខាន់ ប៉ុន្តែដោយទទួលបានការគាំទ្រ និងដំបូន្មានពីបងប្រុស និងមិត្តភក្ដិ ក៏ដូចជាចូលរួមសិក្ខាសាលាផ្សេងៗ លោក ហ៊ាប សុភា ក៏ទទួលបានជោគជ័យ និងបានបង្កើតចម្ការមៀនប៉ៃលិនដោយផ្ដោតលើដំណាំសមស្របនឹងបរិស្ថានក្នុងតំបន់ និងតម្រូវការទីផ្សារ។ តាមរយៈការប្រើប្រាស់បច្ចេកទេសកសិកម្មទំនើប និងរួមបញ្ចូលការយល់ដឹងដែលគាត់ទទួលបានពីបងប្រុស និង មិត្តភក្ដិរបស់គាត់។

ខណៈពេលដែលដំណាំមៀនប៉ៃលិនមានការរីកចម្រើន លោកហ៊ាប សុភាបានវិនិយោគលើការរីកចម្រើនរបស់ខ្លួន ដោយពង្រីកប្រតិបត្តិការ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន។ លោក ហ៊ាប សុភាក៏បានទទួលយកការអនុវត្តប្រកបដោយនិរន្តរភាព និងបានកសាងទំនាក់ទំនងរឹងមាំជាមួយសហគមន៍មូលដ្ឋាន បង្កើតការងារ និងគាំទ្រដល់ការអភិវឌ្ឍក្នុងតំបន់។

ចម្ការរបស់លោក ហ៊ាប សុភា លាតសន្ធឹងនៅលើដីគ្រួសក្រហមទំហំប្រមាណ ២៥ហិចតា ដែលលោកមិនត្រឹមតែមានដំណាំមៀនប៉ៃលិន ឬតាម៉ែនប៉ុណ្ណោះទេ ប៉ុន្តែលោកក៏មានដំណាំផ្សេងៗផងដែរដូចជា៖

- ដំណាំមៀនប៉ៃលិនឬតាម៉ែន ៦៥០ ដើមត្រូវបានដាំនៅលើដីផ្ទៃដីទំហំ ៤ ហិចតា។

- ដំណាំមៀនកោះក្របីប្រមាណ ៣០០ ដើមនៅលើដីផ្ទៃដីទំហំ ១ ហិចតា ២វ៉ែ។
- ដំណាំស្វាយប្រមាណ ១៧០០ ដើម ដើមនៅលើដីផ្ទៃដីទំហំ ១៧ ហិចតា។
- និងដំណាំដំឡូងមីត្រូវបានដាំតាមរដូវផងដែរ ដើមនៅលើដីផ្ទៃដីទំហំ ២ ហិចតា។

## ២.១.២. ទីតាំងភូមិសាស្ត្រ

លោក ហ៊ាប សុភា បានធ្វើការជ្រើសរើសទីតាំងចំការរបស់ខ្លួន នៅក្នុងស្រុកកំណើតរបស់លោកផ្ទាល់គឺនៅភូមិទឹកប្រៃ ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ ប្រសិនបើយើងធ្វើដំណើរពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ខេត្តបាត់ដំបងយើងនឹងចំណាយពេលប្រមាណជា ៥ ទៅ ៦ម៉ោង និងប្រហែល ២៩០គ.ម. ដើម្បីអាចធ្វើដំណើរទៅដល់ក្រុងបាត់ដំបង ហើយក៏បន្តដំណើរប្រហែលជា ៣០នាទី ទៅ ១ម៉ោង ពីក្រុងបាត់ដំបងបន្ថែមទៀត ដើម្បីទៅដល់ភូមិទឹកប្រៃដែលជាទីតាំងចម្ការរបស់លោក ហ៊ាប សុភាផ្ទាល់។

ដើម្បីធ្វើដំណើរទៅដល់ទីតាំងចំការរបស់លោក ហ៊ាប សុភា យើងត្រូវធ្វើដំណើរពីទីក្រុងភ្នំពេញដោយធ្វើដំណើរនៅលើកំណាត់ផ្លូវជាតិលេខ 5 (NH5) ដោយឆ្លងកាត់ខេត្តកណ្ដាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និង គោលដៅចុងក្រោយគឺជាខេត្តបាត់ដំបង ដែលជាខេត្តគំរូមួយរបស់ប្រទេសកម្ពុជា ដែល មានភាពល្បីល្បាញខាងវប្បធម៌ ប្រវត្តិសាស្ត្រ ក៏ដូចជាមុខម្ហូបខ្មែរ និងជាពិសេសគឺវិស័យកសិកម្មនេះផងដែរ។

**ឧបសម្ព័ន្ធទី ១: ទីតាំងភូមិសាស្ត្ររបស់ចម្ការ លោក ហ៊ាប សុភា**



## ២.២. ការគ្រប់គ្រង (រចនាសម្ព័ន្ធគ្រប់គ្រងរបស់ចម្ការ)

ដោយចម្ការរបស់លោក ហ៊ាប សុភាជាចម្ការលក្ខណៈគ្រួសារហេតុដូច្នេះហើយការគ្រប់គ្រងរចនាសម្ព័ន្ធផ្សេងៗគឺមិនសូវមានបុគ្គលិក ឬកម្មករច្រើននោះទេ ដោយលោក ហ៊ាប សុភាគឺជាអ្នកគ្រប់គ្រងចម្ការតែផ្ទាល់តែម្តង និងបានជួលកម្មករចំនួន ២នាក់ដើម្បីប្រចាំការនៅចម្ការ ដោយក្នុងកម្មម្នាក់ទទួលបាននៅក្នុងមួយខែនូវទឹកប្រាក់ចំនួន ៧០ ម៉ឺនរៀល និងអង្ករមួយបាវជាប្រាក់ខែ។ មូលហេតុចម្បងមួយទៀតដែលចម្ការរបស់លោកមានតែកម្មករប្រចាំការតែ ២នាក់ ពីព្រោះតែនៅពេលដែលខាងក្រុមហ៊ុនចិនដែលបានចុះកុងត្រា និងសម្រេចព្រមទិញមៀនប៉ៃលិនពីលោក គឺខាងក្រុមហ៊ុននឹងមានដាក់កម្លាំងកម្មករ ឬបុគ្គលិកដែលមានជំនាញមកធ្វើការប្រមូលផលពីចម្ការរបស់លោកតែម្តងដែលមិនចាំបាច់មានកម្មកររបស់លោកឡើយ។

**តារាងទី ៣: រចនាសម្ព័ន្ធគ្រប់គ្រងរបស់ចម្ការ**




## ២.៣. លក្ខណៈពិសេសរបស់ដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន

ដំណាំមៀនប៉ៃលិន ឬតាង៉ែន ជាផ្លែឈើហូបផ្លែមួយប្រភេទដែលប្រជាជនខ្មែរនិយមបរិភោគហើយក៏ជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរស់ជាពិសេសសម្រាប់ប្រជាកសិករនៅក្នុងខេត្តបាត់ដំបង។

ដំណាំមៀនប៉ៃលិន ឬតាង៉ែនមានលក្ខណៈដៀងគ្នានឹងផ្លែមៀនរបស់ខ្មែរ តែមានទំហំធំជាង សាច់ក្រាស់ជាងស្លឹកក៏ធំជាងស្លឹកមៀនធម្មតា។ កត្តាទាំងអស់នេះហើយ ទើបពួកគាត់ហៅមៀនប៉ៃលិននេះថា ដើមតាង៉ែន ឫផ្លែតាង៉ែន។

ពលរដ្ឋខ្មែរបានលើកឡើងថា ផ្លែមៀនប៉ៃលិនជាប្រភេទផ្លែឈើ ដែលមានរសជាតិផ្អែមស្រដៀងទៅនឹងមៀនធម្មតា តែវាមានសាច់ច្រើនជាង និងមិនសូវមានក្លិនក្រអូបដូចមៀនធម្មតា តែពណ៌សម្បុរវាដូចគ្នានឹងមៀនធម្មតាស្ទើរតែច្រឡំ។

## ២.៤. ការសិក្សាអំពីបច្ចេកទេស និងដំណើរការដាំដុះដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន

### ២.៤.១. ការរៀបចំដី និងបច្ចេកទេសគ្រប់គ្រងដី

ការរៀបចំដីឲ្យបានត្រឹមត្រូវ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព គឺជាកត្តាចាំបាច់សម្រាប់ធានាបាន នូវការលូតលាស់ប្រកបដោយសុខភាពល្អ និងទិន្នផលខ្ពស់នៃផ្លែមៀនប៉ៃលិន ឬតាង៉ែន។ ជំហានដំបូង ក្នុងការរៀបចំដីគឺត្រូវជ្រើសរើសទីតាំងដែលមានអាកាសធាតុសមរម្យ និងដីដែលមានទឹកល្អ។ ផ្លែមៀន ប៉ៃលិនដុះលូតលាស់ក្នុងដីមានជីជាតិ ជាពិសេសដីល្បាវ ដីខ្សាច់ ឬដីឥដ្ឋ។ បន្ទាប់ពីការជ្រើសរើស កន្លែងហើយ ដីត្រូវតែជម្រះស្មៅ ដើមឈើ និងឫសធំៗ ដើម្បីធានាបាននូវផ្ទៃដាំដែលស្មើ។ ការធ្វើតេស្ត ដីមានសារៈសំខាន់ណាស់ ដើម្បីកំណត់កម្រិត pH ចន្លោះ ៦ ទៅ ៧ និងបរិមាណសារធាតុចិញ្ចឹម ព្រោះថា មៀនប៉ៃលិនលូតលាស់ល្អនៅលើដីអាស៊ីតបន្តិច ហើយការកែប្រែដីដោយប្រើកំបោរ និងសារធាតុសរីរាង្គ ដូចជាជីកំប៉ុស ដើម្បីបង្កើនជីជាតិ។

ការភ្ជួរដីគួរធ្វើដល់ជម្រៅ ៣០-៤០ ស.ម ដើម្បីបំបែកដីបង្រួម និងបញ្ចូលសារធាតុសរីរាង្គ។ រណ្តៅដាំដែលមានអង្កត់ផ្ចិត និងជម្រៅប្រហែល ៦០ ស.ម គួរតែមានចម្ងាយពី ៨ ទៅ ១០ ម៉ែត្រ។ ការគ្រប់គ្រងដីប្រកបដោយប្រសិទ្ធភាព រួមមានប្រព័ន្ធធារាសាស្ត្រជាប់លាប់ ដោយគេនិយមប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ បែបប្រព័ន្ធទុយោតំណក់ទឹក ដើម្បីជៀសវាងការជ្រាបទឹក និងការដាក់ស្មៅជុំវិញគល់ឈើ ដើម្បីរក្សា សំណើម និងកំចាត់ស្មៅ។ ការបង្កកំណើតមានសារៈសំខាន់ ដោយចាប់ផ្តើមជាមួយនឹងជី NPK ដែលមាន តុល្យភាពនៅពេលដាំ និងបន្តជាមួយនឹងការប្រើប្រាស់ជាប្រចាំដោយផ្អែកលើការធ្វើតេស្តដី។

ការគ្រប់គ្រងស្មៅតាមរយៈ ការដកយកចេញដោយដៃ ឬការប្រើប្រាស់ថ្នាំសំលាប់ស្មៅប្រកបដោយយុត្តិធម៌ គឺចាំបាច់ដើម្បីការពារការប្រកួតប្រជែងសម្រាប់ធនធាន។ ការគ្រប់គ្រងសត្វល្អិត និងជំងឺគួរតែមានការត្រួតពិនិត្យចម្ការដំណាំជាប្រចាំ និងយុទ្ធសាស្ត្រគ្រប់គ្រងសត្វល្អិតរួមបញ្ចូលគ្នា។ ការកាត់ចេញ និងការ បណ្តុះពូជក្មេងៗបង្កើតរចនាសម្ព័ន្ធដ៏រឹងមាំ ខណៈពេលដែលការថែរក្សាការកាត់ចេញនៅក្នុងដើមចាស់ ធានាឱ្យមានចរន្តខ្យល់ល្អ និងការជ្រាបចូលពន្លឺ។

សុខភាពដីត្រូវបានថែរក្សាដោយការបន្ថែមសារធាតុសរីរាង្គតាមកាលកំណត់ និងអនុវត្តវិធានការគ្រប់គ្រងសំណឹកដូចជាការដាំដុះឆ្លាស់ ឬការដាំបង្វិល។ ដោយអនុវត្តតាមបច្ចេកទេសរៀបចំ និងគ្រប់គ្រងដីទាំង នេះ កសិករអាចបង្កើនប្រសិទ្ធភាពកំណើន និងផលិតភាពនៃផ្លែមៀនប៉ៃលិនដោយធានាបាននូវទិន្នផលផ្លែឈើគុណភាពខ្ពស់សម្រាប់ទីផ្សារក្នុងស្រុកនិងនាំចេញ។

### ២.៤.២. វិធីសាស្ត្រដាំ និងដកឃ្លា

គម្លាតមានសារៈសំខាន់ណាស់ក្នុងការដាំដុះ ដំណាំមៀនប៉ៃលិន ដើម្បីអនុញ្ញាតឱ្យមានការជ្រៀតចូលនៃ ពន្លឺព្រះអាទិត្យ និងខ្យល់ចេញចូលគ្រប់គ្រាន់ កាត់បន្ថយហានិភ័យនៃសត្វល្អិត និងជំងឺ។ វិធីសាស្ត្រនៃការដាំដំណាំនេះគឺមានច្រើនទម្រង់ទៅតាមសណ្ឋានដី និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ម្ចាស់ ចម្ការនីមួយៗ ក្នុងករណីដាំមៀនចម្ងាយជិត ត្រូវមានការចាត់ចែងដីដូចជាការ កាត់តែងមែក ដើម្បី គ្រប់គ្រងទម្រង់ដើម ឬកាត់តែងតាមបរិវេណរបស់ដើមពេលទម្រង់ស្លឹកដល់គ្នា ដើម្បីឱ្យមៀនចេញផ្កា កាន់ផ្លែបានច្រើន ជាធម្មតាចម្ងាយសមស្របរបស់មៀនចម្ងាយរវាងពី ៨ ដល់១២ និងពី១០ ដល់ ១២ម៉ែត្រ ដែលសម្រាប់ចម្ការរបស់លោក ហ៊ាប សុភាគីលោកជ្រើសរើសដាំដោយទុកគម្លាត ៧ម៉ែត្រ បួនជ្រុង ពីគ្នាតាមលំនាំក្រឡាចត្រង្គ។ តាមបទពិសោធន៍របស់លោកផ្ទាល់ គម្លាតនេះធានាថា ដើមឈើនីមួយៗ មានគម្លាតគ្រប់គ្រាន់សម្រាប់ដុះលូតលាស់ និងដំណាំមិនមានការដណ្ដើមសារធាតុចិញ្ចឹម និងពន្លឺគ្នា។ ដើមឈើដែលមានគម្លាតត្រឹមត្រូវក៏ជួយសម្រួលដល់ សកម្មភាពថែទាំកាន់ តែងាយស្រួល ដូចជាការកាត់ចេញ ការបង្កកំណើត និងការប្រមូលផលផងដែរ។

**ឧបសម្ព័ន្ធទី ២: ទិដ្ឋភាពនៃការដាំ និងដកឃ្លា**



## ២.៤.៣. ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក

ដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែនទាមទារការយកចិត្តទុកដាក់ខ្លាំងទៅលើប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹកជាពិសេសបើធៀបទៅនឹងដំណាំស្រដៀងគ្នាដទៃ ទឹកជាធាតុចាំបាច់សម្រាប់ដំណាំមៀនប៉ៃលិន ឬតាង៉ែនពីព្រោះទឹកជាបច្ច័យកំណត់ការលូតលាស់ និងភាពធំធាត់របស់ដើមមៀនប៉ៃលិន ជាពិសេសក្នុងចន្លោះ

ពេលដែលដើមនៅតូច ឬក្រោយពេលដាំថ្មីៗបើសិនជាមៀនប៉ៃលិន ឬតាង៉ែនមិនបានទទួលទឹកគ្រប់គ្រាន់ទាំងទឹកភ្លៀង និងបឹង ស្ទឹង ទន្លេ។

ក្នុងនោះលោក ហ៊ាប សុភា ដែលជាម្ចាស់ចម្ការបានលើកឡើងថាការផ្គត់ផ្គង់ទៅលើប្រព័ន្ធទឹកជាផ្នែកមួយដ៏សំខាន់ដែលអាចធ្វើឱ្យដំណាំនេះលូតលាស់បានល្អ និងទទួលបានផលគាប់ប្រសើរ ដោយចម្ការរបស់លោកអំណោយផលដែលមានស្រះនៅក្រោយចម្ការ ដែលជាប្រភពទឹកយ៉ាងសំខាន់សម្រាប់ចម្ការដែលប្រភពទឹកស្រះនេះបានមកពីជ្រលងភ្នំជីប៉ាងដែលអាចហូរចុះមកបានតែត្រឹមខែវស្សាតែប៉ុណ្ណោះ បូកផ្សំជាមួយនឹងបច្ចេកទេសប្រព័ន្ធទឹកដែលអាចស្រោចស្រពពាសពេញផ្ទៃដីចម្ការ ជាពិសេសការរៀបប្រព័ន្ធទុយោទឹក ដោយប្រើប្រាស់ ទុយោមេ ១តឹក, ឆ្អឹង ៧ហ៊ុន, ៥ហ៊ុន, និង ២ហ៊ុន ដោយក្នុង១គុម្ពប្រើប្រាស់ទុយោ ២ក្បាលវិល ជាបួនជ្រុងដោយប្រើប្រាស់ទុយោក្បាលវិលដែលមាន ដំណាំមៀនប៉ៃលិន ឬតាង៉ែន ៤ដើម និងមានប្រព័ន្ធទុយោទឹកដែលបានបូមចេញពីស្រះមួយដើម្បីស្រោចស្រពដោយការបូមទឹកដោយប្រើប្រាស់ម៉ាស៊ីនជំនួយដែលការប្រើម៉ាស៊ូតក្នុងម្តងៗចំណាយម៉ាស៊ូតអស់ ២០លីត្រ។ ការផ្គត់ផ្គង់ទឹកនេះត្រូវមានដំណាក់កាលដែលដំណាក់ការសម្រាប់តែដើមត្រូវការស្រោចទឹកឱ្យបានជាប់ ដំណាក់កាលចេញផ្កានិងពន្លកត្រូវការបន្ថយការផ្តល់ទឹក សម្រាប់ខែប្រាំងគឺចំបាច់ត្រូវប្រើប្រាស់អណ្តូង ដែលលោកចំណាយក្នុងការបុកតម្លៃ ១,២០០ដុល្លារ ក្នុង១អណ្តូង។ រីឯស្រះដីកម្តងចំណាយអស់ ៦,០០០ដុល្លារ ដែលផ្ទុកទឹកបានច្រើនម៉ឺនគីបផងដែរ។

មៀនប៉ៃលិនលូតលាស់ល្អជានិច្ច មិនបង្អាក់ការលូតលាស់ ហើយរឹងមាំ មិនមានការរំខានពីមេរោគ ធំលឿនជាងការដាំដោយអាស្រ័យលើទឹកភ្លៀងតែមួយមុខ បើសិនដើមមៀនប៉ៃលិន ឬតាង៉ែននេះស្ថិតក្នុងចន្លោះពេលកំពុងលូតលាស់ មៀនប៉ៃលិន ឬតាង៉ែននឹងអន់ក្រោះក្រិន ឬអាចងាប់បាន។ [40]មៀនប៉ៃលិន ឬតាង៉ែនជារុក្ខជាតិត្រូវការទឹកតែមិនជោគជាំពេកទេក្នុងតំបន់ដែលគ្មានប្រភពទឹកមៀនប៉ៃលិន ត្រូវការបរិមាណទឹកភ្លៀងសមស្របគឺប្រមាណពី ១២០០ ដល់ ១៤០០ ម.ល. ឬក្នុងកម្រិតពី ១០០ ដល់ ១៥០ថ្ងៃ ក្នុង១ឆ្នាំ បើសិនជាផ្ទៃដីណាដែលមានចំនួនទឹកភ្លៀងតិចជាងនេះត្រូវមានការផ្តល់ទឹកជំនួស។ ដូចនេះហើយទើបលោក ហ៊ាប សុភា បានយកចិត្តទុកដាក់ខ្លាំងទៅលើប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹកក្នុងចន្លោះពេលខ្លះមៀនប៉ៃលិន ឬតាង៉ែនត្រូវការទឹកតិចបំផុតគឺចន្លោះមុនចេញផ្កា បើផ្តល់ទឹកច្រើនក្នុងចន្លោះពេលនេះធ្វើឱ្យពន្លកផ្កាបរិមាណពន្លកត្រួយលូតលាស់ក្លាយជាស្លឹកខ្ចី បើមៀនចេញផ្កាកាន់ផ្លែរួចហើយទើបត្រូវការទឹកច្រើនជាពិសេសក្នុងចន្លោះក្រោយចេញផ្កានិងកាន់ក្តិបក្នុង ខែមករា ដល់ ខែមេសា ពីព្រោះរយៈពេលដែលកាន់ក្តិបនេះចាំបាច់ផ្តល់ជីដល់ដីផង ដូច្នេះដីត្រូវ

[40] ក្រសួងរុក្ខាប្រមាញ់ និងនេសាទ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម "*សៀវភៅណែនាំ ស្តីពី បច្ចេកទេសដាំដំណាំមៀនប៉ៃលិន*", បោះពុម្ពលើកទី១, ខែមិថុនា ឆ្នាំ២០១៤, ទំព័រទី ២០

មានសំណើមគ្រប់គ្រាន់ដើម្បីរលាយជីផ្តល់ឱ្យឫសបានបឺតស្រូបចូលទៅដល់ដើម និងទៅដល់ស្លឹក ហើយឆ្លងកាត់ការផ្ទេរស្មើសំយោគរួចបញ្ជូនសារធាតុចិញ្ចឹមទៅដល់ផ្លែខ្ចីបាន។ បន្ទាប់ពីនេះក៏អាស្រ័យលើទឹកភ្លៀងតាំងពីខែ ឧសភា ដល់ ខែកក្កដា ហើយនឹង ខែសីហាដែលជារយៈពេលប្រមូលផល ។

### ២.៤.៤. ការអនុវត្តការបង្កកំណើត

ការបង្កកំណើតមានច្រើនរបៀបការផ្សាំតាង៉ែនអាចចំណាយពេល ប្រហែល ៣ខែ ទម្រាំតាង៉ែនដុះឫសល្អ។ យើង ផ្សាំតាង៉ែន ដោយកាត់បណ្តុះ មុនដំបូងយើងបំបៅនៅមែកតាង៉ែន រយះពេល ១ខែ រហូតដល់វាដុះឬសនៅលើមែក។ បន្ទាប់មកយើងលាយដីជាមួយស្រកីដូង ហើយផ្ចាប់វាទុករហូតដល់បាក់តេរីបំបែកដីនោះសព្វ។ ពេលហើយយើងយកដីនោះទៅដាក់ក្នុងថង់ផ្សាំជាមួយមែកដែលយើងផ្សាំនៅដើម។ ទុកអោយវាដុះឬសនៅក្នុងថង់ទើបយើងកាត់ថង់យកវាទៅដាំ។ ការបង្កកំណើតដោយជោគជ័យនៃដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែនពាក់ព័ន្ធនឹងការរួមផ្សំនៃការគ្រប់គ្រងដីការប្រើប្រាស់សារធាតុចិញ្ចឹម និងពេលខ្លះការអនុវត្តបន្ថែមដើម្បីបង្កើនទិន្នផល។ ក្នុងនោះមានការសាកមែក ការបណ្តុះគ្រាប់ ការតកូន ការផ្គោបមែកជាដើម។ ក្នុងការបង្កកំណើតនេះកសិករលោក ហ៊ាប សុភា បានជ្រើសរើសការទិញកូនពីឈ្មួញនៅខាងប្រទេសថៃដែលមានស្រាប់យកមកដាក់ដាំ និងមើលថែទៅតាមបច្ចេកទេសរបស់លោក ដោយលោកបានលើកឡើងថាការទិញកូនពីគេស្រាប់មានភាពងាយស្រួល និងឆាប់បានដាំដែលយើងត្រូវការចំណាយពេលតិច និងយកចិត្តទុកដាក់ទៅលើការមើលថែដាក់ជីបន្ថែម។ ក្នុងនោះលោកបានទិញពូជពីខាងប្រទេសថៃប្រមាណជាង ១៥០០ដើម ដែលការយកមកដាក់ដាំលើផ្ទៃដី ៤ ហិចតា ដែលដើមដែលបានបង្កកំណើតជោគជ័យមានចំនួនបាន ៦៥០ដើម ចាត់តាំងពីពេលចាប់ផ្តើម។

### ២.៤.៥. វិធីសាស្ត្រថែទាំ (ការគ្រប់គ្រងសត្វល្អិត និងជំងឺ)

តាមរយៈលោក ហ៊ាប សុភា បានមានប្រសាសន៍ថាការដាំដុះដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែនប្រកបដោយប្រសិទ្ធភាពទាមទារការថែទាំប្រចាំឆ្នាំយ៉ាងម៉ត់ចត់ ដោយចាប់ផ្តើមជាមួយនឹក្រោយការប្រមូលផលដើម្បីជំរុញការលូតលាស់ថ្មី។ ជារៀងរាល់ឆ្នាំ កសិករត្រូវដាក់ជីដូចជា លាយជាមួយលាមកសត្វ រក្សាការស្រោចទឹកជាប្រចាំ ដើម្បីការពារកុំឱ្យដីស្ងួត និងកំចាត់សត្វល្អិតដោយថ្នាំបាញ់គីមី។ ក្នុងរដូវដាំដុះ វាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយការរាតត្បាតពីសត្វល្អិត គ្រប់គ្រងស្មៅ និងធានាឱ្យមានសំណើមជាប់លាប់។ នៅពេលដែលដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែនខិតជិតដល់ការចេញផ្កា ហើយដីគួរតែត្រូវបានរក្សាសំណើម ការបង្កកំណើតគួរតែបន្តតាមរយៈការចេញផ្លែដោយផ្តោតលើការបញ្ចូលអ័រម៉ូន។

ការគ្រប់គ្រងទឹកបានត្រឹមត្រូវ និងជាពិសេសនៅពេលមានភ្លៀងធ្លាក់ខ្លាំង មានសារៈសំខាន់ណាស់ដើម្បីជៀសវាងបញ្ហាគុណភាព និងការលួយផ្លែ ចាំបាច់ត្រូវមានការព្យាបាលគីមីតាមកាលកំណត់សម្រាប់ជំងឺ និង

សត្វល្អិត។ ដោយដំណាក់កាលទាំងនោះមានចាត់តាំងពីរយៈពេលបំប៉នដើមមៀនឱ្យលូតលាស់ល្អ ក្រោយពីការប្រមូលផលត្រូវធ្វើការកាត់តែងមែក ដែលមិនត្រូវការចោល ការកាត់តែងមែកក្នុងរយៈពេលនេះគឺដើម្បីឱ្យដើមមៀនលាស់ត្រួយ និងស្លឹកថ្មីសម្រាប់រដូវក្រោយ ដែលយើងត្រូវផ្តល់ទឹកជាប្រចាំ កុំឱ្យដីស្ងួត បាញ់ថ្នាំគីមីការពារ និងកំចាត់សត្វល្អិតចង្រៃ។

### ២.៤.៥.១. រយៈពេលលាស់ស្លឹកខ្ចី និងបែកមែក

រយៈពេលលាស់សឹកខ្ចី និងបែកមែក ក្នុងដំណាក់កាលនេះទាមទារអោយមានការផ្តល់សំណើមដល់ដី បើគ្មានទឹកភ្លៀងត្រូវមានទឹកធម្មតាដែលមានស្រាប់ ក្នុងនោះអាចមានជាមួយសត្វចង្រៃដូចជាប្រភេទចៃក្រហម ដូចនេះ កសិករបានជ្រើសរើសយកការបាញ់គីមីប្រភេទស្រាល។ ការបាញ់នេះធ្វើឡើង ២ ទៅ ៣ លើក និងចន្លោះគ្នាពី ២ សប្តាហ៍។

### ២.៤.៥.២. រយៈពេលផ្កា

រយៈពេលនេះ យើងប្រើប្រាស់ជីដែលមានអាស៊ូត (N) ច្រើននិងជីធម្មជាតិក្នុងអាត្រា ១ភាគពីរ ១ គ.ក ក្នុងមួយដើម ហើយដាក់ជីតាមស្លឹកដែលមានសារជាតុចិញ្ចឹមបន្ថែម និងសារធាតុចិញ្ចឹមជំនួយរួមគ្នាជាមួយសាធាតុគីមីការពារ និងកំចាត់មេរោគ និងសត្វល្អិតចង្រៃផង។ រក្សាដីឱ្យសើមជាប់ជានិច្ចដោយប្រើកាកសំណល់សំរាមផ្សេងៗគ្របដីនៅបរិវេណគល់ ដូចជាស្មៅស្ងួត ចំបើងជាដើម តែមិនគួរប្រើស្មៅស្រស់ ចំបើងស្រស់ និងជីលាមកសត្វថ្មីគ្របគល់ព្រមៗគ្នាព្រោះអាចធ្វើឱ្យមានភាពក្តៅដល់ប្រព័ន្ធឫសដែលបង្កការខូចខាតបាន ។

**ឧបសម្ព័ន្ធទី៣: រយៈពេលផ្កា**




### ២.៤.៥.៣. រយៈពេលនៃការកាន់ផ្លែទំហំតូច

ផ្តល់ទឹកតាមធម្មតា និងជាប្រចាំ បើខ្វះខាតទឹកក្នុងរយៈពេលនេះផ្លែមៀនអាចជ្រុះ។ កំចាត់ស្មៅចង្រៃជាប្រចាំកុំទុកឱ្យស្មៅឡើងច្រើន ព្រោះអាចទៅដណ្តើមជីដែលផ្តល់ដល់ដំណាំមៀនប៉ៃលិន។ ក្នុងអំឡុងពេលនេះមានសត្វល្អិតច្រើនប្រភេទចូលមកបំផ្លាញផ្លែមៀន ដូចជាមមាចម្សៅ មមាចខៀវ មមាចភ្លើង អណ្តើកមាសធ្វើឱ្យត្រីមមៀនជ្រុះរោយ ។ ដូចនេះគួរបាញ់ថ្នាំគីមីពួក សិបពើម៉េតជិន ខាបូសាល់ហ្វែន អេនដូសាល់ហ្វែន ឬ ក្លរហ្វីរីហ្វូស ។ ចំណែកជំងឺដែលបំផ្លាញដំណាំមៀនក្នុងចន្លោះពេលនេះគឺ រោគក្រាខ្មៅ ដែលបណ្តាលមកពីពពួកមមាចខ្យល់ បើការពារមមាចខ្យល់បានរោគនេះក៏មិនសូវរាតត្បាតដែរ ។ [41]ជាធម្មតា ក្នុងអំឡុងពេលមៀនកំពុងមានផ្លែជិតចាស់ តែងស្របនឹងរដូវភ្លៀង បើមានភ្លៀងធ្លាក់ខ្លាំង គួរបញ្ចេញទឹកចេញពីគល់ហើយបញ្ឈប់ការផ្តល់ទឹកក្នុងរយៈពេលយូរដើម្បីឱ្យផ្លែមៀនមានគុណភាពល្អ ។ ក្នុងអំឡុងពេលមានមេរោគ និងសត្វល្អិតច្រើនប្រភេទចូលមកបំផ្លាញដូចជាពពួក ដង្កូវចោះក្បាលផ្លែមៀន មេអំបៅរមូស្លឹក គួរចាត់វិធានការ ដោយបាញ់សាធាតុគីមីប្រភេទជ្រាបចូល ដូចជា គួរហ្វីរីហ្វូស ខាបូសាល់ហ្វែន ជាដើម ។ ក្នុងអំឡុងពេលបច្ចុប្បន្ន រោគបែកផ្លែស្អុយដែលតែងកើតពីរោគផ្សិតជំងឺប្រភេទនេះពេលកើតតែងធ្វើឲ្យផ្លែជ្រុះ។ ចំពោះវិធានការការពារគួរប្រើសាធាតុគីមីពពួកមេតាលែកស៊ីន ២៥% បាញ់សព្វពាសពេញដើមប្រមាណ ២ ទៅ ៣ដង ឃ្លាតគ្នា ៧ ទៅ១០ ថ្ងៃម្តង។

## ២.៥. បច្ចេកទេសនៃការប្រមូលផល និងក្រោយការប្រមូលផល

ការប្រមូលផលនៅពេលដំណាំមៀនប៉ៃលិនទុំ ដែលធ្វើឡើង ១ឆ្នាំម្តងក្នុងអំឡុង ខែមករា ឬខែកុម្ភៈ តាមរយៈការលើកឡើងរបស់កសិករ លោក ហ៊ាប សុភា បានឱ្យដឹងថាការប្រមូលផលជាទូទៅគឺមានក្រុមហ៊ុនកែច្នៃចិនមកទិញដល់ចម្ការផ្ទាល់ ដោយមានកម្មករខាងក្រុមហ៊ុនស្រាប់មកប្រមូលផលតែម្តង អ្វីដែលលោកត្រូវធ្វើជាទូទៅគឺតែងដើមមៀនប៉ៃលិននេះដោយក្នុងមួយចង្កោមគួរតែមានត្រឹមតែ ៣៨គ្រាប់យ៉ាងច្រើន។ លោកក៏បានបន្ថែមផងដែរថាការចម្រាញ់ទំហំរបស់មៀនប៉ៃលិន គឺខាងក្រុមហ៊ុនចិនដែលបញ្ជាទិញនោះនឹងមាននូវឧបករណ៍សម្រាប់វាស់ទំហំផ្លែមៀនប៉ៃលិននេះ ថាតើនៅក្នុងប្រភេទ និងកម្រិតណា និងមានតម្លៃទៅតាមនោះផងដែរ។ វិធីសាស្ត្រនៃការប្រមូលផល ជាដំណាក់កាលមួយទៀតដែលមានការចាំបាច់សម្រាប់គុណភាពរបស់ផលិតផល តែការប្រមូលផលមៀនអាចទទួលផលសម្រេចយ៉ាងណានោះ គឺអាស្រ័យទៅលើភាពជំនាញរបស់ក្រុមហ៊ុន និងការតែងដើមរបស់កសិករ ដោយការប្រមូលផលដែលបានបែងចែកទៅតាមលេខដែលមានប្រភេទលេខ១ លេខ ២ គិតទៅតាមទំហំនៃផ្លែមៀន ផ្លែក្នុងមែកតែមួយមិនត្រូវមានផ្លែដែរផ្ទុះ ចាស់ ឬខ្ទីពេកដែលប៉ះពាល់ដល់គុណ

[41] ក្រសួងរុក្ខាប្រមាញ់ និងនេសាទ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម "*សៀវភៅណែនាំ ស្តីពី បច្ចេកទេសដាំដំណាំមៀនប៉ៃលិន*", បោះពុម្ពលើកទី១, ខែមិថុនា ឆ្នាំ២០១៤, ទំព័រទី ៧៦

ភាពរបស់មៀន ការកាត់ផ្លែមៀនត្រូវប្រើកម្លាំងមនុស្សជាគោល និងការកាត់ត្រូវប្រយ័ត្នមិនឱ្យមានផលប៉ះពាល់ដល់ផ្លែដែលអាចបណ្តាលអោយជាំជាដើម និងទុកប្រវែងមែកសមល្មម។

ក្រោយការប្រមូលផលរួចកសិករ ទម្លាក់ផ្លែមៀនចុះពីលើដើមហើយត្រូវនាំផ្លែមកតុបតែងដោយកាត់ធាងដែលមិនមានផ្លែ ឬមានផ្លែតូចៗ និងផ្លែដែលមានរោគ ឬសត្វល្អិតចេញ កាត់ទង ធាងត្រូវបានកាត់ចេញត្រូវនាំទៅធ្វើចំណាត់ថ្នាក់ទំហំសិន ទើបយកទៅដាក់ក្នុងសម្ភារដើម្បីធ្វើការដឹកជញ្ជូន ទៅចែកចាយ និងលក់ដូរនៅតាមទីផ្សារ ។ បន្ទប់មកកសិករត្រូវតាក់តែដើមមៀនប៉ៃលិននេះសារជាថ្មីក្នុងការធ្វើបន្តនៅឆ្នាំបន្ទាប់ៗទៀត

**ឧបសម្ព័ន្ធទី ៤: ទិដ្ឋភាពដំណាំមៀនប៉ៃលិន (តាង៉ែន) នៅចម្ការលោក ហ៊ាប សុភា ក្នុងខេត្តបាត់ដំបង**



# ជំពូកទី៣

# ការពិភាក្សាទៅលើលទ្ធផលនៃការស្រាវជ្រាវ

## ៣.១. សមិទ្ធផលនៃការដាំដុះដំណាំផ្លែមៀនប៉ៃលិន ( ទិន្នន័យពីឆ្នាំ២០១៨-២០២៣ )

### ៣.១.១. ទិន្នផលនៃដំណាំតាខែន ( ឆ្នាំ២០១៨-២០២៣ )

**តារាងទី ៤: ទិន្នផលនៃការដាំដុះដំណាំផ្លែមៀនប៉ៃលិន (ទិន្នន័យពីឆ្នាំ២០១៨-២០២៣)**

| ឆ្នាំ | ទិន្នផលសរុប (តោន) | ទិន្នផលសរុប ក្នុង១ដើម (គីឡូក្រាម) |
|---|---|---|
| ២០១៨ | ២២ | ៣៣.៨៥ |
| ២០២០ | ២៩ | ៤៤.៦២ |
| ២០២១ | ៣៥ | ៥៣.៨៥ |
| ២០២៣ | ៤៥ | ៦៩.២៣ |

**សង្ខេបនៃទិន្នផលសរុប និងទិន្នផលក្នុងមួយដើម (២០១៨ - ២០២៣)**

- ដើម្បីបម្លែងទិន្នផលពីតោនទៅជាគីឡូក្រាម:

- ទិន្នផលសរុប (គីឡូក្រាម)} = ទិន្នផលសរុប (តោន) x ១,000 គីឡូក្រាម/តោន

- ដើម្បីគណនាទិន្នផលក្នុងមួយដើម:

- ទិន្នផលក្នុងមួយដើម (គីឡូក្រាម)} = ទិន្នផលសរុប (គីឡូក្រាម) / ចំនួនដើមសរុប

**ព័ត៌មានលម្អិតនៃការគណនា (២០១៨ - ២០២៣)**

**+ សម្រាប់ឆ្នាំ ២០១៨:**

- ទិន្នផលសរុប (គីឡូក្រាម) = ២២ តោន × ១,000 គីឡូក្រាម/តោន= ២២,000 គីឡូក្រាម

- ទិន្នផលក្នុងមួយដើម (គីឡូក្រាម) = ២២,000 គីឡូក្រាម / ៦៥០ដើម ≈ ៣៣.៨៥ គីឡូក្រាម/ដើម

**+ សម្រាប់ឆ្នាំ ២០២០:**

- ទិន្នផលសរុប (គីឡូក្រាម) = ២៩ តោន × ១,០០០ គីឡូក្រាម/តោន= ២៩,០០០ គីឡូក្រាម

- ទិន្នផលក្នុងមួយដើម (គីឡូក្រាម) = ២៩,០០០ គីឡូក្រាម / ៦៥០ដើម ≈ ៤៤.៦២ គីឡូក្រាម/ដើម

**+ សម្រាប់ឆ្នាំ ២០២១:**

- ទិន្នផលសរុប (គីឡូក្រាម) = ៣៥ តោន × ១,០០០ គីឡូក្រាម/តោន= ៣៥,០០០ គីឡូក្រាម

- ទិន្នផលក្នុងមួយដើម (គីឡូក្រាម) = ៣៥,០០០ គីឡូក្រាម / ៦៥០ដើម ≈ ៥៣.៨៥ គីឡូក្រាម/ដើម

**+ សម្រាប់ឆ្នាំ ២០២៣:**

- ទិន្នផលសរុប (គីឡូក្រាម)= ៤៥ តោន × ១,០០០ គីឡូក្រាម/តោន= ៤៥,០០០ គីឡូក្រាម

- ទិន្នផលក្នុងមួយដើម (គីឡូក្រាម)= ៤៥,០០០ គីឡូក្រាម / ៦៥០ដើម ≈ ៦៩.២៣ គីឡូក្រាម/ដើម

**ក្រាហ្វិកទី ៣: ទិន្នផលនៃការដាំដុះដំណាំផ្លែមៀនប៉ៃលិន (ទិន្នន័យពីឆ្នាំ ២០១៨-២០២៣)**




## ៣.១.២. លទ្ធផលសម្រេចបាន (ឆ្នាំ ២០១៨-២០២៣)

តារាងខាងក្រោមបង្ហាញពីលិទ្ធផលសម្រេចបាននៃការដាំដុះផ្លែមៀនប៉ៃលិនសម្រាប់ឆ្នាំ ២០១៨ ដល់ ២០២៣។ តារាងនេះបង្ហាញអំពីទិន្នផលសរុប និងការលក់ដែលបានប្រមូលរួមជាមួយនឹងចំណូលសរុប និងការចំណាយសម្រាប់ឆ្នាំ២០១៨-២០២៣:

**តារាងទី ៥: លទ្ធផលសម្រេចបាន (ឆ្នាំ ២០១៨-២០២៣)**

| ឆ្នាំ | ទិន្នផលសរុប (តោន) | តម្លៃលក់ (រៀល/ក្នុងមួយគីឡូក្រាម) | ប្រាក់ចំណូលសរុប (លានរៀល) | ដើមទុនវិនិយោគសរុប (លានរៀល) | ប្រាក់ចំណេញសរុប (លានរៀល) |
|---|---|---|---|---|---|
| ២០១៨ | ២២ | ១,៧០០ | ៣៧,៤០០,000 | ២៦,000,000 | ១១,៤០០,000 |
| ២០២០ | ២៩ | ២,៥០០ | ៧២,៥០០,000 | ៣២,000,000 | ៤០,៥០០,000 |
| ២០២១ | ៣៥ | ១,000 | ៣៥,000,000 | ៤៨,000,000 | -១៣,000,000 |
| ២០២៣ | ៤៥ | ៣,៨០០ | ១៧១,000,000 | ៧៤,000,000 | ៩៧,000,000 |

យោងទៅតាមទិន្នន័យដែលទទួលបានពីលោក ហ៊ាប សុភា គាត់បានឆ្លងកាត់ទាំងការលំបាកនិងភាពជោគជ័យក្នុងការដាំដំណាំមៀនប៉ៃលិនចាប់ពីឆ្នាំ ២០១៨ ដល់ ២០២៣។ នៅឆ្នាំ ២០១៨ គាត់បានចាប់ផ្តើមដាំដំណាំមៀនប៉ៃលិនដំបូងដោយទទួលបានទិន្នផលចំនួន ២២ តោន និងចំណូល ៣៤,៦៥០,000៛។

នៅឆ្នាំ ២០២០ ការតស៊ូរបស់គាត់បាននាំមកនូវការពង្រីកការដាំដល់ ២៥ តោន ហើយចំណូលកើនឡើងដល់ ៥៦,៥០០,000៛។ ក៏ប៉ុន្តែ នៅឆ្នាំ ២០២១ ទោះបីជាទិន្នផលបានកើនដល់ ៤៥ តោន ក៏ដោយក៏ចំណូលវិញបានធ្លាក់ចុះមក ៣៥,000,000៛។ ចំណុចនេះបានបង្ហាញពីការប៉ះទង្គិចនឹងវិបត្តិជាសកលដោយសារកូវីដ ១៩ ដែលនាំមកនូវការខាតបង់ធំមួយដល់ទៅ ១៣,000,000៛។

យ៉ាងណាមិញ នៅឆ្នាំ ២០២៣ លោក ហ៊ាប សុភា បានសម្រេចចិត្តដាំដំណាំមៀនប៉ៃលិនវិញដោយអនុវត្តយុទ្ធសាស្ត្រថ្មីនៃការប្រើប្រាស់បច្ចេកវិទ្យា និងការគ្រប់គ្រងធនធានដែលមានប្រសិទ្ធភាព។ យុទ្ធសាស្ត្រនេះបាននាំមកនូវទិន្នផលអស្ចារ្យមួយជាមួយនឹងចំណូលកើនឡើងដល់ ១៧២,000,000៛។

ប្រវត្តិការងាររបស់លោក ហ៊ាប សុភា ក្នុងការដាំដំណាំមៀនប៉ៃលិននេះបានបង្ហាញពីភាពរឹងមាំ និងការលះបង់របស់គាត់ ក្នុងការប្រឈមនឹងបញ្ហាផ្សេងៗ និងស្ថានភាពអនិច្ចា។ ភាពជោគជ័យរបស់គាត់គឺជាគំរូល្អមួយសម្រាប់កសិករផ្សេងៗដែលកំពុងប្រឹងប្រែងក្នុងវិស័យកសិកម្ម ដើម្បីទទួលបាននូវការលេចធ្លោ និងភាពរឹងមាំក្នុងការដំណើរការអាជីវកម្មកសិកម្មរបស់ពួកគេ។

ក្រាហ្វិកទី ៤: ទិន្នន័យដើមទុនវិនិយោគសរុប (ឆ្នាំ ២០១៨-២០២៣)




ក្រាហ្វិកទី ៥: ទិន្នន័យប្រាក់ចំណូលសរុប (ឆ្នាំ ២០១៨-២០២៣)



**ក្រាហ្វិកទី ៦: ទិន្នន័យប្រាក់ចំណេញសរុប (ឆ្នាំ ២០១៨-២០២៣)**




## ៣.១.៣. ប្រសិទ្ធភាពសេដ្ឋកិច្ច (តារាងហិរញ្ញវត្ថុ)

តារាងខាងក្រោមបង្ហាញពីការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ចនៃការដាំដុះផ្លែមៀនប៉ៃលិនសម្រាប់ឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៣។ តារាងនេះមានការពិចារណាដល់កំណត់ត្រានៃចំណូល និងការចំណាយដែលនឹងជួយបង្ហាញពីអត្ថប្រយោជន៍ និងសមត្ថភាពសេដ្ឋកិច្ចរបស់ចម្ការលោក ហ៊ាប សុភា។

**តារាងទី ៦: ទិន្នផលសរុប និងប្រាក់ចំណូលសរុប (២០១៨-២០២៣)**

| ឆ្នាំ | ទិន្នផលសរុប (តោន) | តម្លៃលក់ (រៀល/ក្នុងមួយគីឡូក្រាម) | ប្រាក់ចំណូលសរុប (លានរៀល) | ប្រាក់ចំណូលសរុប (ដុល្លារ) |
|---|---|---|---|---|
| ២០១៨ | ២២ | ១,៧០០ | ៣៧,៤០០,០០០ | ៩,៣៥០ |
| ២០២០ | ២៩ | ២,៥០០ | ៧២,៥០០,០០០ | ១៨,១២៥ |
| ២០២១ | ៣៥ | ១,០០០ | ៣៥,០០០,០០០ | ៨,៧៥០ |
| ២០២៣ | ៤៥ | ៣,៨០០ | ១៧១,០០០,០០០ | ៤,២៧៥០ |

### ក្រាហ្វិកទី ៧: តម្លៃលក់របស់មៀនប៉ៃលិន គិតជារៀល/មួយគីឡូក្រាម (២០១៨-២០២៣)




### តារាងទី ៧: ថ្លៃដើមក្នុងមួយតោន និងដើមទុនវិនិយោគ (២០១៨-២០២៣)

| ឆ្នាំ | ទិន្នផលសរុប (តោន) | ដើមទុនវិនិយោគ (ដុល្លារ) | ថ្លៃដើមក្នុងមួយគីឡូក្រាម (ដុល្លារ/គីឡូក្រាម) | ថ្លៃដើមក្នុងមួយតោន (ដុល្លារក្នុងមួយតោន) |
|---|---|---|---|---|
| ២០១៨ | ២២ | ៦,៥០០ | ០.២៩៥ | ២៩៥.៤៥ |
| ២០២០ | ២៩ | ៨,០០០ | ០.២៧៦ | ២៧៥.៨៦ |
| ២០២១ | ៣៥ | ១២,០០០ | ០.៣៤៣ | ៣៤២.៨៦ |
| ២០២៣ | ៤៥ | ១៨,៥០០ | ០.៤១១ | ៤១១.១១ |

**តារាងទី ៨: ប្រាក់ចំណេញសុទ្ធ និងអត្រាប្រាក់ចំណេញសុទ្ធ - Net Profit Margin (២០១៨-២០២៣)**

| ឆ្នាំ | ទិន្នផលសរុប (តោន) | ប្រាក់ចំណេញសុទ្ធ (លានរៀល) | ប្រាក់ចំណេញសុទ្ធ (ដុល្លារ) | អត្រាប្រាក់ចំណេញសុទ្ធ Net Profit Margin (%) |
|---|---|---|---|---|
| ២០១៨ | ២២ | ១១,៤00,000 | ២,៨៥0 | ៣0.៨៨% |
| ២០២០ | ២៩ | ៤0,៥00,000 | ១0,១២៥ | ៥៥.៨៨% |
| ២០២១ | ៣៥ | -១៣,000,000 | -៣,២៥0 | -៣៧.១៤% |
| ២០២៣ | ៤៥ | ៩៧,000,000 | ២៤,២៥0 | ៥៦.៧៥% |

**តារាងទី ៩: ប្រាក់ចំណូលក្នុងមួយតោន និងអត្រាផលតបស្នងនៃវិនិយោគ (ROI %)**

| ឆ្នាំ | ទិន្នផលសរុប (តោន) | ប្រាក់ចំណូលក្នុងមួយតោន (ដុល្លារក្នុងមួយតោន) | ប្រាក់ចំណូលក្នុងមួយតោន (លានរៀលក្នុងមួយតោន) | អត្រាផលតបស្នងនៃវិនិយោគ (ROI %) |
|---|---|---|---|---|
| ២០១៨ | ២២ | ៤២៥.00 | ១,៧00,000 | ៤៣.៨៥% |
| ២០២០ | ២៩ | ៦២៥.00 | ២,៥00,000 | ១២៦.៥៦% |
| ២០២១ | ៣៥ | ២៥0.00 | ១,000,000 | -២៧.0៨% |
| ២០២៣ | ៤៥ | ៩៥0.00 | ៣,៨00,000 | ១៣១.0៨% |

**+ សង្ខេបនៃវិភាគសេដ្ឋកិច្ចជាមួយការពិចារណាអំពីយុទ្ធសាស្ត្រដាំដុះ (២០១៨-២០២៣)**

តារាងដែលបានផ្តល់ខាងលើបង្ហាញពីសមិទ្ធផលជាសេដ្ឋកិច្ចនៃដំណាំផ្លែមៀនប៉ៃលិននៅលើចម្ការរបស់លោក ហ៊ាប សុភា ចាប់ពីឆ្នាំ ២០១៨ ដល់ ២០២៣។

- **តារាងទី ៦: ទិន្នផលសរុប និងប្រាក់ចំណូលសរុប (២០១៨-២០២៣)**

តារាងនេះបង្ហាញពីទិន្នផលសរុប និងប្រាក់ចំណូលនៅលើឆ្នាំផ្សេងៗគ្នាក្នុងកំឡុងឆ្នាំ (២០១៨ - ២០២៣)។ ទិន្នផល និងប្រាក់ចំណូលបានកើនឡើង យ៉ាងសំខាន់ជាមួយនឹងទិន្នផល និងប្រាក់ចំណូលដែលខ្ពស់បំផុតនៅក្នុងឆ្នាំ២០២៣ គឺ **១៧១,000,000លានរៀល (៤,២៧៥០ដុល្លារ)**។ ការលូតលាស់នេះបង្ហាញពីការកែលម្អ ផលិតភាព និងប្រាក់ចំណូលទីផ្សារ។ គួរឱ្យកត់សម្គាល់ផងដែរថាដំណាំប្រភេទគឺលោក ហ៊ាប សុភា ប្រើប្រាស់យុទ្ធសាស្ត្រដាំមួយឆ្នាំរំលងមួយឆ្នាំ តែសម្រាប់ឆ្នាំ២០២១ លោកក៏សម្រេចចិត្តដាំ២ឆ្នាំជាប់គ្នាដោយសារ តែមានការអំណោយផលនៃប្រភពទឹកផងនោះ ដែលយើងសង្កេតឃើញថាទិន្នផលនាឆ្នាំនោះខ្ពស់គួរអោយកត់ សម្គាល់បើធៀបនឹងឆ្នាំ២០២០ តែជាអកុសលដោយសារតែវិបត្តកូវីដ ១៩ ចូលមកដល់ភ្លាមៗ ធ្វើឱ្យប្រាក់ចំណូល ទទួលបាន ទាបដោយក្នុង១គីឡូក្រោម ឈ្មួញទិញក្នុងតម្លៃត្រឹមតែ ១,000រៀលប៉ុណ្ណោះ។

- **តារាងទី ៧: ថ្លៃដើមក្នុងមួយតោន និងវិនិយោគទុន (២០១៨ - ២០២៣)**

តារាងនេះផ្តល់ឱកាសសម្រាប់ការវិភាគនូវដើមទុនវិនិយោគ និងថ្លៃដើមសម្រាប់ដំណាំមួយតោននៃផ្លែមៀន ប៉ៃលិន ឬតាង៉ែន។ ទិន្នផលបង្ហាញពីការប្រែប្រួលក្នុងថ្លៃ ដោយសារដើមទុនវិនិយោគនិងទិន្នផល។ នៅឆ្នាំ ២០២០-២០២១ លោក ហ៊ាប សុភា បានបម្រែបម្រួលពីវដ្តដាំដុះធម្មតា ដោយការដាំដុះជាបន្តបន្ទាប់ (ដាំ២ឆ្នាំជាប់គ្នា) ដែលនាំឲ្យមានការចំណាយផលិតភាពខ្ពស់។ ថ្លៃដើមក្នុងមួយតោនកើនឡើងនៅឆ្នាំ ២០២៣ បន្ទាប់ពីដើមទុនវិនិយោគបានកើនឡើងពី **៨,000ដុល្លារ នៅឆ្នាំ២០១៩ ទៅ ១២,000ដុល្លារ នៅឆ្នាំ២០២០**។

- **តារាងទី ៨: ប្រាក់ចំណេញសុទ្ធ និងអត្រាប្រាក់ចំណេញសុទ្ធ - Net Profit Margin (២០១៨-២០២៣)**

តារាងនេះបង្ហាញពីប្រាក់ចំណេញសុទ្ធនិងអត្រាប្រាក់ចំណេញសុទ្ធ ដែលបង្ហាញពីការចំណេញរបស់ចម្ការលោក ហ៊ាប សុភា។ ទោះបីជាចម្ការបានសម្រេចបានប្រាក់ចំណេញខ្ពស់នៅឆ្នាំ ២០២៣ ប្រមាណ ២៤,២៥០ដុល្លារក៏ដោយ តែនាឆ្នាំ ២០២១ បានបង្ហាញពីការលំបាកដោយសារថ្លៃទីផ្សារបានទាបជាផលប៉ះពាល់ពីការរីករាលដាលនៃកូវីដ-១៩។ ស្ថានភាពដូចនេះបង្ហាញពីអត្រាប្រាក់ចំណេញអវិជ្ជមាន ដោយសារថ្លៃទិន្នផលខ្ពស់ប៉ុន្តែទីផ្សារទាប។

- **តារាងទី ៩: ប្រាក់ចំណូលក្នុងមួយតោន និងអត្រាផលតបស្នងនៃវិនិយោគ (ROI %)**

តារាងនេះស្រាវជ្រាវអំពីប្រាក់ចំណូលដែលបានបង្កើតក្នុងមួយតោន និងអត្រាផលតបស្នងនៃវិនិយោគសម្រាប់ រៀងរាល់ឆ្នាំ។ ទិន្នផលបង្ហាញថា អត្រាផលតបស្នងនៃវិនិយោគ (ROI) គឺខ្ពស់បំផុតនៅឆ្នាំ ២០២០ គឺ ១២៦.៥៦% ដែលបង្ហាញពីរយៈពេលដែលប្រាក់ចំណូលក្នុងមួយតោនខ្ពស់ ប៉ុន្តែវាត្រូវបានប៉ះពាល់ដោយថ្លៃទីផ្សារទាបក្នុងអំឡុងពេលកូវីដ-១៩ គឺធ្លាក់ចុះ ២៧.០៨%។ អត្រាផលតបស្នងនៃវិនិយោគ (ROI) បានកើន ឡើងម្តងទៀតនៅឆ្នាំ ២០២៣ បង្ហាញពីការស្តារឡើងវិញនិងយុទ្ធសាស្ត្រវិនិយោគដែលមានប្រសិទ្ធភាពដែលគិតជា ភាគរយគឺ ១៣១.០៨%។

សរុបមកតាមរយៈការវិភាគសេដ្ឋកិច្ចសម្រាប់ចម្ការរបស់ លោក ហ៊ាប សុភា បង្ហាញពីភាពស្មុគស្មាញ និងការលំបាក នៃការដាំដំណាំផ្លែមៀនប៉ៃលិន ឬតាង៉ែន ដែលត្រូវបានប៉ះពាល់ដោយលក្ខខណ្ឌទីផ្សារ និងការ សម្រេចយុទ្ធសាស្ត្រផ្សេងៗ។ ការផ្លាស់ប្តូរយុទ្ធសាស្ត្រដាំដុះនៅឆ្នាំ ២០២០-២០២១ បាននាំឲ្យមានទិន្នផលខ្ពស់ ប៉ុន្តែត្រូវបានប៉ះពាល់ ដោយថ្លៃទីផ្សារទាបដែលមានការរីករាលដាលនៃកូវីដ ១៩។ ទោះបីជា ការលំបាកនេះ លោក ហ៊ាប សុភា បានបង្ហាញពីការស្តារឡើងវិញ និងការលូតលាស់ ដែលកំពុងផ្តល់អត្ថន័យសំខាន់នៃការបង្កើតចំណូល និងសមត្ថភាពក្នុងការវិនិយោគសម្រាប់ការចំណេញរយៈពេលវែងនៅក្នុងអាជីវកម្មកសិកម្មប្រភេទនេះ។

**ក្រាហ្វិកទី ៨: អត្រាប្រាក់ចំណេញសុទ្ធ Net Profit Margin (%)**



**ក្រាហ្វិកទី ៩: អត្រាផលតបស្នងនៃវិនិយោគ (ROI %)**




## ៣.២. បញ្ហាប្រឈម ឬ កត្តាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍដំណាំផ្លែមៀនប៉ៃលិន

នៅក្នុងដំណើរការនៃការដាំមៀនប៉ៃលិន ឬតាង៉ែននៅក្នុងខេត្តបាត់ដំបងនេះ លោក ហ៊ាប សុភា បាន លើកឡើងនូវបញ្ហាប្រឈមមួយចំនួនដែលលោកបានជួបប្រទះដែលបញ្ហាប្រឈមទាំងនោះរួមមាន៖

### ៣.២.១. កត្តាអាកាសធាតុ

យើងបានដឹងហើយថាសព្វថ្ងៃនេះអាកាសធាតុនៅប្រទេសកម្ពុជា យើងមានការប្រែប្រួលឥតឈប់ឈរ ជួនកាលក្តៅ ជួនកាលត្រជាក់ ជួនកាលភ្លៀង ហើយបញ្ហាប្រឈមដែលចម្បងនាពេលបច្ចុប្បន្នគឺភាពរាំងស្ងួតនា តំបន់ដែលលោក ហ៊ាប សុភារស់នៅនេះតែម្តង។ អាកាសធាតុផ្លាស់ប្តូរបែបនេះបង្កអោយមានផលវិបាកខ្លាំង ណាស់ដល់ការរស់នៅ មិនថាតែ ចំពោះការធ្វើស្រែចំការ និងជាពិសេសគឺ ការដាំដំណាំកសិកម្មនេះតែម្តង ។

ការលូតលាស់របស់ផ្លែមៀនប៉ៃលិន ឬតាង៉ែនពឹងផ្អែកយ៉ាងខ្លាំងទៅលើស្ថានភាពអាកាសធាតុ។ ផ្លែមៀនប៉ៃលិន ត្រូវការកម្តៅ និងទឹកគ្រប់គ្រាន់ដើម្បីឲ្យដំណាំប្រភេទនេះមានការលូតលាស់បានល្អ។ កម្តៅដែលខ្លាំងពេក ឬ ត្រជាក់ពេកក៏អាចបណ្តាលឲ្យដំណាំមានបញ្ហាផងដែរ។ ពេលដែលកម្តៅសំរាប់ ដំណាំមានការកើនឡើង ឬថយ ចុះខ្លាំងពេក វាអាចធ្វើឲ្យដំណាំខ្លួនមិនអាចលូតលាស់បានល្អ បណ្តាលឲ្យខូច ឬដុះមិនពេញសាច់ ឬមិនបាន

គ្រាប់ធំល្អជាដើម។ ការគ្រប់គ្រងស្ថានភាពកម្ដៅបានយ៉ាងមានប្រសិទ្ធិភាពគឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍដំណាំ។ ទោះជាមានការថែទាំយ៉ាងយកចិត្តទុកដាក់ ខ្លាំងយ៉ាងណាក៏ដោយ ក៏បញ្ហាអាកាសធាតុនេះនូវតែជាបញ្ហាស្មុគស្មាញដដែលសម្រាប់ការដាំដំណាំមៀនប៉ៃលិននេះផងដែរ។

### ៣.២.២. កត្តាហេដ្ឋារចនាសម្ព័ន្ធ

កត្តាហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានចោទជាបញ្ហាប្រឈមមួយសម្រាប់ចម្ការរបស់លោក ហ៊ាប សុភាផងដែរ ដែលបញ្ហាប្រឈមទាក់ទងហេដ្ឋារចនាសម្ព័ន្ធត្រូវបានបែងចែកជា ២គឺៈ

#### ៣.២.២.១ ការផ្គត់ផ្គង់ទឹក

លោក ហ៊ាប សុភា បានលើកឡើងអំពីសារៈសំខាន់នៃការផ្គត់ផ្គង់ទឹកសម្រាប់ចម្ការជាពិសេសក្នុងរដូវប្រាំង។ បើទោះបីជាមានអណ្ដូងទឹក និងប្រព័ន្ធច្រកទឹកមួយចំនួនក៏ដោយ ការផ្គត់ផ្គង់ទឹកនៅតែត្រូវបានពិចារណាថា មិនទាន់គ្រប់គ្រាន់សម្រាប់បំពេញតំរូវការរបស់ចម្ការនេះទេ។ ជាក់ស្ដែងដោយសារតែមូលហេតុនេះធ្វើបណ្ដាលឲ្យលោកមិនអាចធ្វើការដាំដុះនៅក្នុងឆ្នាំនេះទេ។

#### ៣.២.២.២ ភាពលំបាកក្នុងការដឹកជញ្ជូន

ការដឹកជញ្ជូនគឺជាបញ្ហាប្រឈមសំខាន់មួយទៀត។ ផ្លូវដែលដឹកទៅចម្ការមានសភាពមិនល្អ ហើយធ្វើឱ្យមានការលំបាកក្នុងការដឹកជញ្ជូនផលិតផលមៀនទៅទីផ្សារ។ លោក ហ៊ាប សុភាបានបញ្ជាក់ថា វាតែបង្កឱ្យមានការពន្យារពេល និងបង្កើនចំណាយនៃការដឹកជញ្ជូន ប៉ះពាល់ដល់ផលចំណេញសរុបរបស់លោក។

### ៣.២.៣. កត្តាប្រកួតប្រជែង (តម្លៃ និងទីផ្សារ)

លោក ហ៊ាប សុភា បានបញ្ជាក់ផងដែរថាការប្រកួតប្រជែងនៅក្នុងទីផ្សារ អាចប៉ះពាល់ដល់តម្លៃផ្លែមៀនប៉ៃលិន ដោយសារតែដំណាំប្រភេទនេះមានទីផ្សារល្អហើយមានការប្រកួតប្រជែងខ្ពស់ដែលជាពិសេសគឺមានតម្រូវការខ្លាំងនៅក្នុងប្រទេសចិន។ បើទោះបីជាយើងសង្កេតឃើញថាចម្ការរបស់លោកទទួលបាននូវតម្លៃខ្ពស់គួរសម ប៉ុន្តែបើយើងក្រឡេកមើលទៅកាន់ឆ្នាំ ២០២០ គឺតម្លៃធ្លាក់ចុះយ៉ាងខ្លាំងនៅសល់ត្រឹមតែ ១០០០រៀល ប៉ុណ្ណោះក្នុង ១គីឡូក្រាម ដែលធ្វើឲ្យលោកមានការខាតបង់ប្រាក់ផងដែរ។ លោកក៏បានបញ្ជាក់ដែរថាតម្លៃនេះគឺមានការប្រកួតប្រជែងគ្នាទៅតាមតំបន់ និងក្រុមហ៊ុនដែលធ្វើការបញ្ជាទិញដំណាំមៀនប៉ៃលិននេះ។

### ៣.២.៤. កត្តាបច្ចេកវិទ្យាថ្មី

ការបញ្ជ្រាបបច្ចេកវិទ្យាថ្មីទៅកាន់វិស័យកសិកម្មនៅតែជាបញ្ហាប្រឈមសម្រាប់ប្រជាកសិករនៅប្រទេសកម្ពុជា។ ដោយបច្ចេកវិទ្យាសម្រាប់ការធ្វើកសិកម្មទាមទារនូវការសិក្សាយ៉ាងខ្លាំង ដែលប្រជាកសិករមួយចំនួន

ធំដែលមិនមានសមត្ថភាព ឬបទពិសោធន៍ក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗសម្រាប់ការធ្វើកសិកម្ម នៅតែប្រកាន់យកនូវវិធី ឬបច្ចេកទេសដាំដុះបែបបុរាណសម្រាប់ការដាំដំណាំដែលធ្វើឲ្យផលិតភាពនៃការប្រមូលផលឬការដាំដុះមិនទទួលបាននៅទិន្នផលច្រើននោះទេ។ ជាក់ស្តែងលោក ហ៊ាប សុភាព ក៏មិនទាន់បានប្រើប្រាស់នៅបច្ចេកវិទ្យាថ្មីៗសម្រាប់ដំណាំរបស់លោកផងដែរ ដែលជាបញ្ហាមួយចាក់ស្រេះសម្រាប់លោកផងដែរ។ ចំពោះចម្ការលោក ហ៊ាប សុភាពគឺប្រើប្រាស់បច្ចេកទេសមួយចំនួន ក៏ប៉ុន្តែនៅមិនទាន់ទូលំទូលាយនៅឡើយដូចជាម៉ាស៊ីនបូមទឹក ប្រព័ន្ធទុយោបាញ់ទឹកសម្រាប់ស្រោចស្រពដំណាំ និងគ្រឿងម៉ាស៊ីនមួយចំនួនជាដើម។

### ៣.២.៥. កត្តាសេដ្ឋកិច្ច និងសង្គម

កត្តាសេដ្ឋកិច្ច និងសង្គម ក៏ត្រូវបានចោទជាបញ្ហាប្រឈមមួយសម្រាប់ចម្ការរបស់លោក ហ៊ាប សុភាក៏ដូចជាប្រជាកសិករមួយចំនួនធំដែរ ដែលបញ្ហាប្រឈមទាក់ទងហេដ្ឋារចនាសម្ព័ន្ធត្រូវបានបែងចែកជា ២គឺៈ

#### ៣.២.៥.១. បញ្ហាគោលនយោបាយ និងការគាំទ្រពីរដ្ឋាភិបាល

លោក ហ៊ាប សុភាបានបញ្ជាក់ផងដែរថា ការគ្មានការគាំទ្រផ្នែកសេដ្ឋកិច្ចពីរដ្ឋាភិបាល និងការមិនមានការផ្តល់ដំណឹងដល់អ្នកកសិករអំពីបច្ចេកវិទ្យាកសិកម្មថ្មីៗ ឬការមិនទទួលបានចំណេះដឹង ឬវគ្គសិក្សាបំប៉នស្តីពីកសិកម្មពីក្រសួងពាក់ព័ន្ធគឺជាបញ្ហាសំខាន់មួយដែលលោកបានជួបប្រទះកន្លងមក។ លោក ហ៊ាប សុភាបាននិយាយថា ក្រសួងពាក់ព័ន្ធមិនបានផ្តល់ការបណ្តុះបណ្តាល ឬការប្រឹក្សាគ្រប់គ្រាន់ដល់ប្រជាកសិករអំពីវិធីសាស្ត្រដាំដំណាំទាន់សម័យ ដែលអាចជួយបង្កើនផលិតភាពនិងប្រសិទ្ធភាពនៃការផលិត។ លោកក៏បានឃើញពីការប្រឈមមុខនឹងបញ្ហាទីផ្សារផ្លែមៀន អាស្រ័យលើភាពគ្មានការគាំទ្រផ្នែកទីផ្សារដែលរដ្ឋាភិបាលអាចផ្តល់បាន។ គាត់បានលើកឡើងថា ទោះបីកសិករមានផលិតផលច្រើនក៏ដោយ ក៏ពួកគេមិនអាចរកទីផ្សារត្រឹមត្រូវ និងមានតម្លៃល្អបាននោះដែរ ដោយសារមិនសូវមានការជួយជ្រុមជ្រែងពីក្រសួងពាក់ព័ន្ធ ដែលជាទូទៅប្រជាកសិករត្រូវស្វែងរកទីផ្សារ ឬឈ្មួញដោយខ្លួនឯង និងតាមរយៈអ្នកស្គាល់គ្នា។ លោកបានសង្ឃឹមថា រដ្ឋាភិបាលអាចយកចិត្តទុកដាក់ដល់ការផ្តល់ចំណេះដឹង និងការគាំទ្រផ្នែកបច្ចេកទេសដល់កសិករ ដែលនេះអាចជួយពង្រឹងការអភិវឌ្ឍ និងការរីកចម្រើនក្នុងវិស័យកសិកម្មបន្ថែមទៀត។

#### ៣.២.៥.២. បញ្ហាវិបត្តិសកល

បញ្ហាវិបត្តិសកល មានផលប៉ះពាល់ដក់ការអភិវឌ្ឍការដាំដុះដំណាំមៀនប៉ៃលិនយ៉ាងខ្លាំង។ ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ ១៩ វិស័យកសិកម្មបានជួបប្រទះនឹងការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងកង្វះកម្លាំងពលកម្ម ដែលធ្វើឱ្យមានការលំបាកក្នុងផលិតកម្ម និងការចែកចាយ។ ការកើនឡើងនៃតម្លៃប្រេងបានធ្វើឱ្យបញ្ហាកាន់តែស្មុគស្មាញ បង្កើនថ្លៃដើមផលិតកម្ម និងខាត់បង់ប្រាក់ចំនេញរបស់កសិករ។ ទន្ទឹមនឹងនេះ ភាព

តានតឹងភូមិសាស្ត្រនយោបាយ ដូចជាសង្គ្រាមដែលកំពុងបន្តរវាង រុស្ស៊ី និង អ៊ុយក្រែន និងជម្លោះពាក់ព័ន្ធនឹងអ៊ីស្រាអែល និងប៉ាឡេស្ទីនបានបន្ថែមទៅលើអស្ថិរភាពសេដ្ឋកិច្ច និងភាពមិនច្បាស់លាស់នៃទីផ្សារ។ នៅពេលដែលបញ្ហាសកលទាំងនេះកើតឡើង កសិករមិនត្រឹមតែប្រឈមមុខនឹងការមិនមានស្ថេរភាពនៃទីផ្សាររបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កនូវភាពស្មុគស្មាញផ្នែកសេដ្ឋកិច្ច និងសង្គមផងដែរ ដែលវាប៉ះពាល់ដល់អាជីវកម្ម និងចំណូលរបស់ពួកគេ។

#### ៣.២.៥.៣. បញ្ហាតម្រូវការទីផ្សារ និងភាពមិនស្ថិតស្ថេររបស់ទីផ្សារ

ភាពមិនស្ថិតស្ថេររបស់ទីផ្សារ គឺជាបញ្ហាសំខាន់ដែលប៉ះពាល់ដល់ការលក់ផ្លែមៀនប៉ៃលិន។ លោក ហ៊ាប សុភា បានបញ្ជាក់ថា តម្លៃផ្លែមៀនប៉ៃលិនអាស្រ័យទៅលើតម្រូវការទីផ្សារ និងការប្រកួតប្រជែងពីផលិតផលផ្សេងៗ។ នៅពេលដែលមានផលផលិតផ្លែមៀនច្រើនលើសពីតម្រូវការ ឬបើមានការចូលរួមនៃផ្លែឈើផ្សេងៗនៅក្នុងទីផ្សារដែលមានរដូវផលត្រូវគ្នា ឬការរីកចម្រើននៃកសិករច្រើនក្នុងការផលិតផ្លែឈើដូចគ្នា ការប្រកួតប្រជែងនឹងកើនឡើងយ៉ាងខ្លាំង។ ដោយសារតែបញ្ហានេះ តម្លៃរបស់ផ្លែមៀនត្រូវធ្លាក់ចុះ និងអាចបង្កឲ្យកសិករមានការខាតបង់ចំណូលបានយ៉ាងសំខាន់។ បញ្ហានេះបានធ្វើឱ្យកសិករត្រូវមានការប្រុងប្រយ័ត្នក្នុងការកំណត់វិនិយោគរបស់ពួកគេ និងការគ្រប់គ្រងសន្និធិផលិតផលឱ្យបានត្រឹមត្រូវ ដើម្បីបន្ថយការបាក់ស្នះក្នុងតម្លៃ និងរក្សាបាននូវភាពស្ថិតស្ថេរនៃចំណូលពីការលក់ផ្លែឈើនៅលើទីផ្សារ។

## ៣.៣. ដំណោះស្រាយទៅលើកត្តាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍដំណាំផ្លែមៀនប៉ៃលិន

### ៣.៣.១. កត្តាអាកាសធាតុ

ដើម្បីដោះស្រាយបញ្ហាអាកាសធាតុដែលមានផលប៉ះពាល់ដល់ការលូតលាស់របស់ផ្លែមៀនប៉ៃលិន លោក ហ៊ាប សុភាបានព្យាយាមដាក់ការគ្រប់គ្រងយ៉ាងជិតដល់ចំណេះដឹងល្អពាក់ព័ន្ធនឹងប្រព័ន្ធធារាសាស្ត្រ។ លោកបានដាក់ប្រព័ន្ធបង្ហូទឹកដោយស្វ័យប្រវត្តិ ដើម្បីឲ្យមានការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់នៅពេលមានភាពរាំងស្ងួត និងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីតាមដានស្ថានភាពអាកាសធាតុ និងទម្លាប់អាកាសធាតុជាប្រចាំ។ លោកក៏ស្វែងរកការអនុវត្តការផ្គត់ផ្គង់កម្តៅជួយអោយដំណាំមានការលូតលាស់បានល្អ។ ការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងការអនុវត្តបច្ចេកទេសធម្មជាតិក៏ជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាអាកាសធាតុនេះនៅតែមិនអាចដោះស្រាយបានយ៉ាងពេញលេញ និងនៅតែជាបញ្ហាអស្ថិរភាពសម្រាប់ការដាំដំណាំមៀនប៉ៃលិន។

### ៣.៣.២. កត្តាហេដ្ឋារចនាសម្ព័ន្ធ

#### ៣.៣.២.១ ការផ្គត់ផ្គង់ទឹក

ចំពោះបញ្ហាការផ្គត់ផ្គង់ទឹក គឺលោក ហ៊ាប សុភា បានធ្វើការជីកស្រះមួយដោយខ្លួនឯងនៅក្រោយចម្ការ តែម្តងដែលចំណាយទឹកប្រាក់ប្រមាណ ៤០០០ដុល្លារ និងបានបុកអណ្តូងមួយផងដែរ ដែលចំណាយអស់ប្រមាណ ១២០០ដុល្លារ និងមានបំពាក់នៅម៉ាស៊ីនបូមទឹកសម្រាប់ធ្វើការប្រើប្រាស់ស្រោចស្រពដំណាំរបស់លោក និងប្រព័ន្ធទុយោស្រោចស្រពដំណាំ បើទោះបីជាមានភាពរាំងស្ងួតក៏ស្រះនេះអាចធ្វើការផ្គត់ផ្គង់ទឹកបានសមល្មមសម្រាប់ដំណាំរបស់លោកផងដែរ។

### ៣.៣.២.២ ភាពលំបាកក្នុងការដឹកជញ្ជូន

ចំណែកឯបញ្ហាលើការដឹកជញ្ជូន ដែលផ្លូវចូលទៅកាន់ចម្ការរបស់លោក ហ៊ាប សុភាមិនសូវអំណោយផល ដើម្បីដោះស្រាយបញ្ហានេះ លោកបានបញ្ជាក់ថាសម្រាប់ផ្លូវដែលមានសភាពមិនល្អ លោកបានអនុវត្តការជួសជុលផ្លូវ និងធ្វើការតភ្ជាប់ជាមួយម្ចាស់ចម្ការនៅជុំវិញនោះ និងអាជីវករ ដើម្បីធានាថា ផ្លូវមានសភាពល្អ និងសមស្របសម្រាប់ការដឹកជញ្ជូន។ ការផ្តល់ឧបករណ៍ដឹកជញ្ជូនគុណភាពខ្ពស់ និងការអនុវត្តវិធីសាស្ត្រប្រសើរបានជួយបន្ថយពេលវេលាការដឹកជញ្ជូន និងកាត់បន្ថយចំណាយបន្ថែម។

### ៣.៣.៣. កត្តាប្រកួតប្រជែង (តម្លៃ និងទីផ្សារ)

បើទោះបីជាការប្រកួតប្រជែង ឬតម្លៃ និងទីផ្សាររបស់ផ្លែមៀនប៉ៃលិនជាបញ្ហាប្រឈមមួយ ប៉ុន្តែលោក ហ៊ាប សុភាក៏នៅតែបន្តខិតខំប្រឹងប្រែងស្វែងរកនៅឈ្មួញដើម្បីធ្វើការលក់នៅដំណាំរបស់លោក ដោយបច្ចុប្បន្នលោកបានចុះកុងត្រាជាមួយនឹងក្រុមហ៊ុនចិននៅក្នុងការដឹកជញ្ជូន និងទិញផ្លែមៀនប៉ៃលិនរបស់លោកយកទៅលក់នៅឯប្រទេសចិន។

### ៣.៣.៤. កត្តាបច្ចេកវិទ្យាថ្មី

ចំពោះបញ្ហាកត្តាបច្ចេកវិទ្យាថ្មីវិញ លោក ហ៊ាប សុភា មានតែសង្ឃឹមថានឹងទទួលបានការបណ្តុះបណ្តាលបន្ថែមពីសំណាក់ក្រសួងពាក់ព័ន្ធ ដើម្បីជាទុននៅក្នុងការបញ្ជ្រាបបច្ចេកវិទ្យាថ្មីៗចូលទៅក្នុងបច្ចេកទេសដាំដុះរបស់លោក ដើម្បីបង្កើននូវទិន្នផលសម្រាប់ចម្ការរបស់លោក។ លោកក៏នៅតែបន្តធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៅលើបច្ចេកទេសកសិកម្មទំនើបថ្មី ដើម្បីមកអនុវត្តន៍សម្រាប់ចម្ការរបស់លោកផងដែរ។

### ៣.៣.៥. កត្តាសេដ្ឋកិច្ច និងសង្គម

### ៣.៣.៥.១. បញ្ហាគោលនយោបាយ និងការគាំទ្រពីរដ្ឋាភិបាល

ពាក់ព័ន្ធជាមួយនឹងបញ្ហាគោលនយោបាយ និងការគាំទ្រពីរាជរដ្ឋាភិបាល លោក ហ៊ាប សុភាពក៏បានស្នើសុំឲ្យរាជរដ្ឋាភិបាលជួយបន្ត និងគាំទ្រសម្រាប់វិស័យកសិកម្មដោយស្នើសុំឲ្យក្រសួងពាក់ព័ន្ធ បើកបង្រៀននៅ

វគ្គសិក្សាផ្សេងៗ ឬសិក្ខាសាលាស្ដីពីបច្ចេកទេសដាំដុះថ្មីៗ ក៏ដូចជាបង្ហាញផ្លូវទៅកាន់ទីផ្សារនៅក្នុងស្រុក និងក្រៅប្រទេសសម្រាប់ប្រជាកសិករនៅកម្ពុជាផងដែរ។

### ៣.២.៥.២. បញ្ហាវិបត្តិសកល

ដើម្បីដោះស្រាយបញ្ហាវិបត្តិសកលដែលប៉ះពាល់ដល់ការដាំដុះដំណាំមៀនប៉ៃលិន កសិករគួរតែពង្រីកទីផ្សារ និងជ្រើសរើសទីផ្សារថ្មី ដើម្បីកាត់បន្ថយការពឹងផ្អែកលើទីផ្សារតែមួយ ហើយគួរប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្ម។ ការបង្កើតសហគមន៍ និងសហគ្រិនកសិកម្ម អាចជួយកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនភាពរឹងមាំក្នុងទីផ្សារ។ ការទទួលយកវិធានការគ្រប់គ្រងហានិភ័យ និងការសហការជាមួយរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (NGO) អាចផ្ដល់នូវការគាំទ្រសេដ្ឋកិច្ច និងបណ្ដុះបណ្ដាលកសិកម្មប្រកបដោយចីរភាព ដើម្បីទប់ទល់នឹងបញ្ហាសកល និងធានាការអភិវឌ្ឍដំណាំតាំងនឹងត្រាប់តាមនីតិវិធីអន្តរជាតិ។

### ៣.២.៥.៣. បញ្ហាតម្រូវការទីផ្សារ និងភាពមិនស្ថិតស្ថេររបស់ទីផ្សារ

ដើម្បីដោះស្រាយបញ្ហាតម្រូវការទីផ្សារ និងភាពមិនស្ថិតស្ថេររបស់ទីផ្សារ កសិករគួរតែព្យាយាមតាមដានព័ត៌មានអំពីទីផ្សារ និងតម្លៃផ្លែឈើជានិច្ច ដើម្បីដឹងពីតម្រូវការទីផ្សារជាក់ស្ដែង។ កសិករក៏គួរព្យាយាមបែងចែកនូវទីផ្សារដោយស្វែងរកទីផ្សារថ្មីៗ និងផ្គត់ផ្គង់ផ្លែឈើដែលមានគុណភាពខ្ពស់ ដើម្បីបន្ថយភាពមិនស្ថិតស្ថេរនៃតម្លៃផងដែរ។ ដូច្នេះ កសិករគួរតែសហការជាមួយកសិករផ្សេងទៀតក្នុងការចែកចាយផលិតផល និងការកំណត់តម្លៃផ្លែឈើ ដើម្បីមិនឲ្យមានការប្រកួតប្រជែងគ្នាខ្លាំងពេក និងគួរប្រើវិធីគ្រប់គ្រងស្តុកផលិតផលឱ្យបានល្អ ដើម្បីអាចរង់ចាំការតម្លើងតម្លៃវិញនៅពេលតម្លៃធ្លាក់ចុះ ហើយផ្ដោតលើការផលិតផ្លែឈើ ឬដំណាំណាដែលមានគុណភាពខ្ពស់ ដើម្បីទាក់ទាញអតិថិជន និងបង្កើនតម្លៃនៃផលិតផលរបស់ខ្លួន។

## ៣.៤. ការវិភាគ SWOT

ក្រោយពីបានធ្វើការស្រាវជ្រាវ នៅក្នុងចម្ការមៀនប៉ៃលិន ដែលស្ថិតនៅភូមិទឹកប្រៃ ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ ពីដំណើរការនៃការអភិវឌ្ឍដំណាំមៀនប៉ៃលិន (តាង៉ែន) រួចមក យើងខ្ញុំបានយល់ដឹងអំពី ដំណើរការនៃការធ្វើកសិកម្ម វិធីសាស្ត្រក្នុងការធ្វើផែនការ យុទ្ធសាស្ត្រនៃការអភិវឌ្ឍ និងដំណើរការនៃការអភិវឌ្ឍរបស់ចម្ការកាន់តែច្បាស់។

យើងខ្ញុំបានសង្កេតឃើញ ចម្ការដំណាំមៀនប៉ៃលិនទាំងមូលក៏មាននូវ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគម្រាមកំហែងផងដែរ។ ចំណុចទាំងអស់នោះ ត្រូវបានធ្វើការវិភាគដូចខាងក្រោមនេះ ៖

### ៣.៤.១. **ការវិភាគទៅលើភាពខ្លាំង** (Strengths)

- ផ្លែមៀនប៉ៃលិនមានគុណភាពខ្ពស់ និងមាន តម្រូវការល្អក្នុងទីផ្សារខ្លាំង។
- ការចូលរួមក្នុងសហគមន៍កសិករ និងបទពិសោធន៍ច្រើនក្នុងការដាំដំណាំអាចជួយការគ្រប់គ្រងកសិកម្មបានល្អ។
- ការទទួលបានការគាំទ្រពីអង្គការទទួលខុសត្រូវ និងជំនួយពីគម្រោងផ្សេងៗអាចជួយបង្កើនផលិតភាព និងជួយដល់ការអភិវឌ្ឍអាជីវកម្ម។
- ទទួលបាននូវទិន្នផលខ្ពស់ និងប្រាក់ចំណេញច្រើនគួរឲ្យកត់សម្គាល់។

### ៣.៤.២. **ការវិភាគទៅលើភាពខ្សោយ** (Weaknesses)

- ស្ថានភាពអាកាសធាតុដែលមិនស្ថិតស្ថេរ និងការរីករាលដាលបញ្ហាផ្សេងៗធ្វើឲ្យការលូតលាស់របស់ផ្លែមៀនប៉ៃលិនមានការលំបាក។
- ផ្លូវដឹកជញ្ជូនមានសភាពមិនល្អ ដែលបង្កឲ្យមានការពន្យារពេល និងចំណាយបន្ថែម។
- ភាពខ្វះឧបករណ៍ និងបច្ចេកវិទ្យាថ្មីៗសម្រាប់បង្កើនផលិតភាព និងការសម្រួលការងារ។

### ៣.៤.៣. **ការវិភាគទៅលើឱកាស** (Opportunities)

- តម្រូវការកើនឡើងនៃផ្លែមៀនប៉ៃលិននៅទីផ្សារអន្តរជាតិ ផ្តល់ឱកាសដ៏ល្អសម្រាប់ការលក់បន្ថែម។
- ការអនុវត្តបច្ចេកវិទ្យាថ្មីសម្រាប់ការគ្រប់គ្រង និងព្យាបាលកសិកម្មអាចជួយបង្កើនផលិតភាព។
- ការបង្កើតសម្ព័ន្ធភាពជាមួយអ្នកផ្សព្វផ្សាយផលិតផលអាចជួយបង្កើនការលក់ និងបង្ហាញផលិតផលក្នុងទីផ្សារថ្មី។
- មានការគាំទ្រពីអង្គការក្នុង និងក្រៅរដ្ឋាភិបាលដូចជា ActionAid, ADI, CACC, CARDI, CEDAC, CWCDD, FACT, FAO, GIZ, JICA, KE, MAFF, SDC, WB/IFC, និងអង្គការផ្សេងៗទៀត

### ៣.៤.៤. **ការវិភាគទៅលើហានិភ័យ** (Threats)

- ភាពមិនអាចគ្រប់គ្រងអាកាសធាតុបាន និងបញ្ហានៃការប្រែប្រួលអាកាសធាតុអាចបណ្តាលឲ្យមានការខូចខាតទៅលើដំណាំ។
- ការប្រកួតប្រជែងពីកសិករផ្សេងទៀតអាចធ្វើឲ្យតម្លៃផ្លែឈើធ្លាក់ចុះ។
- បញ្ហាសេដ្ឋកិច្ច និងសង្គមដូចជាវិបត្តិសកល និងការប្រឈមនឹងសេដ្ឋកិច្ចអាចធ្វើឲ្យការលក់ធ្លាក់ចុះ និងចំណូលមានការខាតបង់។

ការវិភាគ SWOT នេះអាចជួយសម្រាប់ លោក ហ៊ាប សុភា ក្នុងការច្នៃប្រឌិតយុទ្ធសាស្ត្រ និងវិធីសាស្ត្រ ដើម្បីដោះស្រាយបញ្ហានានា និងបង្កើនសមត្ថភាពការលូតលាស់និងការប្រកួតប្រជែងនៃផ្លែមៀនប៉ៃលិន។

## ៣.៥. ការជ្រៀបចូលក្នុងទីផ្សារ និងបណ្ដាញចែកចាយរបស់មៀនប៉ៃលិន

### ៣.៥.១. និន្នាភាពទូទៅនៃទីផ្សារសម្រាប់មៀនប៉ៃលិន

ក្នុងនាមជាផលិតផលកសិកម្មសំខាន់មួយដែលកំពុងទទួលបានការយកចិត្តទុកដាក់នៅក្នុងទីផ្សារអន្តរជាតិ មៀនប៉ៃលិនរបស់កម្ពុជាបានឈានចូលទៅទីផ្សារទីផ្សារចិនដោយទទួលបានការគាំទ្រយ៉ាងខ្លាំង។ លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានឲ្យដឹងថា ក្នុងរយៈពេលត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ ក្រោយពីក្រសួងពាណិជ្ជកម្មបានធ្វើការសហការជាមួយវិស័យឯកជន ដើម្បីនាំចេញផ្លែឈើនេះទៅលក់នៅលើថ្នាលបច្ចេកវិទ្យារបស់ក្រុមហ៊ុន Alibaba មៀនប៉ៃលិនស្រស់របស់កម្ពុជានៅទីផ្សារចិនបានលក់ចេញរហូតដល់ ១៨ តោន។ យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គិតត្រឹមឆមាសទី១ ឆ្នាំ ២០២៤ ការនាំចេញផ្លែមៀនស្រស់របស់កម្ពុជាទៅទីផ្សារអន្តរជាតិ សម្រេចបានជាង ១ ម៉ឺន ៤ ពាន់តោន កើនឡើងជាង ១២០ ភាគរយ បើបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការនាំចេញផ្លែមៀនប៉ៃលិនក្នុងទំហំទឹកប្រាក់ប្រមាណ ២២ លានដុល្លារ ការកើនឡើង ១២៩ ភាគរយ នៅក្នុងឆមាសទី១ឆ្នាំនេះ។ នៅក្នុងឆ្នាំ២០២៣ កម្ពុជាបាននាំចេញផ្លែមៀនស្រស់មានបរិមាណសរុបជាង ១៧ ៤៩៧ តោន គិតជាទឹកប្រាក់សរុបចំនួន ២៤,៧៥ លានដុល្លារ។[42]

### ៣.៥.២. ការជ្រៀបចូលទីផ្សារ (Market Entry)

ការចូលទៅក្នុងទីផ្សារចិនតាមរយៈក្រុមហ៊ុន Alibaba គឺជាបទឧទាហរណ៍នៃការរួមបញ្ចូលបច្ចេកវិទ្យា និងកសិកម្ម ដែលមានសក្ដានុពលក្នុងការពង្រីកទីផ្សារសម្រាប់កសិផលខ្មែរ។ លោក ប៉ាន សូរស័ក្តិ បានបន្ថែមថា នៅពេលខាងមុខ ក្រសួងពាណិជ្ជកម្មនឹងព្យាយាមពង្រីកទីផ្សារបន្ថែមជាមួយ Alibaba និងក្រុមហ៊ុនផ្សេងៗ ដើម្បីជំរុញចលនាភូមិមួយ ផលិតផលមួយ និងការបង្កើនការនាំចេញ។

### ៣.៥.៣. បណ្ដាញចែកចាយ (Distribution Network)

ក្រុមហ៊ុន Alibaba Group មានគម្រោងនាំចូលផ្លែមៀនប៉ៃលិនពីកម្ពុជារហូតដល់ ២០,០០០ តោន ក្នុងមួយឆ្នាំសម្រាប់ដាក់លក់នៅលើទីផ្សារចិន។ វាពង្រឹងការចែកចាយមៀនប៉ៃលិនទៅស្រុកចិន និងទីផ្សារពិភព

[42] Kampuchea Thmey, retrieved from https://www.kampucheathmey.com/business-economic/758630

លោកតាមរយៈក្របខ័ណ្ឌបច្ចេកវិទ្យានិងបណ្តាញអ៊ីកាម៉ែរ។ នេះជាការបង្កើតទំនាក់ទំនងថ្មីដែលនឹងផ្តល់នូវអត្ថប្រយោជន៍ដល់កសិករខ្មែរបន្ថែមទៀត។

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ដោយយោងទៅតាមរបាយការណ៍ស្រាវជ្រាវ និងតាមការសិក្សាទៅលើលទ្ធផលបានបង្ហាញពីទិដ្ឋភាពយ៉ាងស៊ីជម្រៅអំពីដំណើរនៃការដាំដុះដំណាំមៀនប៉ៃលិន ឬ តាង៉ែន នៅក្នុងខេត្តបាត់ដំបង ជាពិសេសតាមរយៈការសិក្សាករណីចម្ការរបស់លោក ហ៊ាប សុភា។ ជាក់ស្តែងកសិករដែលប្រកបរបរនេះបានប្រឈមនឹងឧបសគ្គជាច្រើនដែលបានរារាំងការរីកចម្រើនរបស់ពួកគេ។ បញ្ហាសំខាន់ៗរួមមានការប្រែប្រួលអាកាសធាតុ ដែលបានប៉ះពាល់ដល់ការដាំដុះ និងផលិតភាព។ បន្ថែមពីនេះ ការប្រកួតប្រជែងទីផ្សារ ភាពមិនស្ថិរភាពនៃទីផ្សារ និងតម្រូវការទីផ្សារមិនទៀងទាត់បានបង្កបញ្ហាយ៉ាងធ្ងន់ធ្ងរដល់កសិករ។ បញ្ហាហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ ដូចជាផ្លូវដឹកជញ្ជូន ប្រព័ន្ធធារាសាស្ត្រ និងទីផ្សារកសិផល បានកំណត់ការអភិវឌ្ឍវិស័យនេះ។ លើសពីនេះ វិបត្តិសកលដូចជាជំងឺកូវីដ-១៩ សង្គ្រាម ការឡើងថ្លៃនៃតម្លៃប្រេងបានបង្កើនភាពស្មុគស្មាញដល់បញ្ហាដែលកសិករប្រឈមមុខ។

យ៉ាងណាក៏ដោយ ការគាំទ្រពីរដ្ឋ វិស័យឯកជន និងសហគមន៍ គឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍវិស័យមៀនប៉ៃលិនប្រកបដោយចីរភាព។ ការបណ្តុះបណ្តាល ការផ្ទេរបច្ចេកវិទ្យា និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគឺជាវិធានការចាំបាច់ដើម្បីជួយដល់កសិករ។ ការសិក្សាបានបង្ហាញពីសារៈសំខាន់នៃការផ្លាស់ប្តូរយុទ្ធសាស្ត្រដើម្បីបង្កើនផលិតភាព និងប្រកួតប្រជែង។ ការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក៏ដូចជាការបណ្តុះបណ្តាលកសិករ អាចជួយដល់ការបង្កើតជម្រើសថ្មីៗ និងប្រសិទ្ធភាព។

ស្របតាមទិន្នន័យរបស់លោក ហ៊ាប សុភា បានបង្ហាញថា បើទោះបីជួបប្រទះការលំបាកក្នុងឆ្នាំ ២០២១ ដែលចម្ការរបស់លោកទទួលបានទិន្នផលខ្ពស់គួរសមប្រមាណ ២៩ តោន តែត្រូវខាតបង់ប្រាក់ប្រមាណ ១៣ លានរៀល ដោយសារតែការធ្លាក់ចុះខ្លាំងនៃតម្លៃ ក៏ដោយ ក៏លោកបានសម្រេចបាននូវការកើនឡើងផលិតភាព និងប្រាក់ចំណូលក្នុងឆ្នាំបន្តបន្ទាប់ដែលជាទិន្នផល ខ្ពស់បំផុតនៅក្នុងឆ្នាំ ២០២៣ គឺចំនួន ៤៥ តោន ដែលគិតជាប្រាក់ចំណេញប្រមាណ ៩៧ លានរៀល។ នេះបង្ហាញពីសក្តានុពលនៃការដាំដុះមៀនប៉ៃលិន និងសារៈសំខាន់នៃការអនុវត្តយុទ្ធសាស្ត្រត្រឹមត្រូវ។

បន្ថែមពីនេះ ការសិក្សានេះបានបង្ហាញពីសារៈសំខាន់នៃការសហការ និងបណ្តាញទំនាក់ទំនងរវាងកសិករ អ្នកជំនាញ អង្គការក្នុង និងក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ។ ការបែងចែកចំណេះដឹង និងបទពិសោធន៍ អាចជួយដល់ការបង្កើនសមត្ថភាពកសិករ និងការអភិវឌ្ឍវិស័យកសិកម្មផងដែរ។

សរុបមក ការសិក្សានេះបានផ្តល់នូវមូលដ្ឋានដ៏មានតម្លៃសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍបន្ថែមទៀតក្នុងវិស័យមៀនប៉ៃលិន។ ការអនុវត្តន៍យុទ្ធសាស្ត្រដែលបានណែនាំអាចជួយដល់ការកែលម្អជីវភាពរស់នៅរបស់កសិករ និងការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យកសិកម្ម។

## ២. ការផ្តល់អនុសាសន៍

ដើម្បីដោះស្រាយបញ្ហាដែលបានបង្ហាញក្នុងការស្រាវជ្រាវនេះ និងកែលម្អដំណើរការលូតលាស់របស់ដំណាំផ្លែមៀនប៉ៃលិននៅលើដីចម្ការរបស់លោក ហ៊ាប សុភា មានការអនុវត្តជាចម្បងមួយចំនួនដែលអាចជួយទប់ស្កាត់បញ្ហា និងអភិវឌ្ឍសមត្ថភាពរបស់លោកបាន។ ខាងក្រោមនេះគឺជាការអនុវត្តសម្រាប់ការលើកកម្ពស់សេដ្ឋកិច្ច និងការលូតលាស់របស់ដំណាំផ្លែមៀនប៉ៃលិនៈ

### ២.១. ការប្រើប្រាស់បច្ចេកវិទ្យាថ្មីសម្រាប់ការគ្រប់គ្រងអាកាសធាតុ

- **ការគ្រប់គ្រងអាកាសធាតុ ៖** អនុវត្តបច្ចេកវិទ្យាថ្មីសម្រាប់ការគ្រប់គ្រងអាកាសធាតុ ដូចជាការត្រួតពិនិត្យស្ថានភាពអាកាសធាតុ និងការកែប្រែប្រព័ន្ធដំណាំ ដើម្បីកាត់បន្ថយផលប៉ះពាល់អាកាសធាតុដែលអាចបង្កគ្រោះថ្នាក់ដល់ដំណាំ។ ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការត្រួតពិនិត្យអាកាសធាតុ និងប្រព័ន្ធសូឡា អាចជួយកែលម្អការលូតលាស់ និងបង្កើនសមត្ថភាពផលិតផលប៉ៃលិន។

### ២.២. ការវិនិយោគក្នុងការជួសជុលផ្លូវ និងការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន

- **ជួសជុលផ្លូវ ៖** ដើម្បីដោះស្រាយបញ្ហាសភាពផ្លូវដែលមានការលំបាក និងមិនល្អ គួរបានចំណាយប្រាក់សម្រាប់ការជួសជុលផ្លូវដែលនាំទៅកាន់ចម្ការ។ ផ្លូវនេះមានចម្ងាយប្រមាណ ៣គម. ចេញពីផ្លូវជាតិ និងត្រូវចំណាយថវិកាអស់ប្រមាណ ៣,៥០០,០០០រៀល។ ការជួសជុលនេះចាំបាច់ត្រូវចាក់ដីក្រហមចំនួនប្រមាណ ១០០០ឡាន ដែលក្នុងមួយឡានចំណាយប្រមាណ ៣៥,០០០រៀល។ ផ្លូវដែលមានសភាពល្អនឹងជួយកាត់បន្ថយពេលវេលាក្នុងការដឹកជញ្ជូន បង្កើនប្រសិទ្ធភាពនៃការចេញផ្សារ និងបន្ថយការពន្យារពេលក្នុងដំណើរការសេដ្ឋកិច្ច។
- **ប្រព័ន្ធដឹកជញ្ជូន ៖** ដើម្បីសម្រួល និងកាត់បន្ថយការចំណាយនៃការដឹកជញ្ជូនតាមរយៈការវិនិយោគក្នុងការផ្គត់ផ្គង់ឧបករណ៍ដឹកជញ្ជូនដែលមានគុណភាពខ្ពស់ ដោយគួរតែទិញរថយន្តដឹកខ្នាតធំដែលមានបច្ចេកវិទ្យាថ្មី ដើម្បីបង្កើនសមត្ថភាពនៃការដឹកជញ្ជូន និងធានាការដឹកជញ្ជូនមានប្រសិទ្ធភាពខ្ពស់។

### ២.៣. ការបង្រៀន និងបណ្តុះបណ្តាលបុគ្គលិក (កម្មករ)

- **ការបណ្តុះបណ្តាលជំនាញ ៖** ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក (កម្មករ) អំពីបច្ចេកវិទ្យាថ្មី និងវិធីសាស្ត្រកសិកម្មសម្រាប់ការលូតលាស់ដំណាំផ្លែមៀន។ ការអភិវឌ្ឍជំនាញសម្រាប់បុគ្គលិកនឹងជួយដល់ការអនុវត្តន៍ និងការគ្រប់គ្រងដីដាំបានប្រសើរឡើង, ពីព្រោះបច្ចេកវិទ្យាថ្មីអាចបង្កើនសមត្ថភាពនៃការលូតលាស់ និងការគ្រប់គ្រង។
- **ការអភិវឌ្ឍជំនាញ ៖** បណ្តុះបណ្តាលអំពីការគ្រប់គ្រងសម្រួល និងការគ្រប់គ្រងធនធានសម្រាប់ការអភិវឌ្ឍនៃការប្រតិបត្តិការនិងការគ្រប់គ្រងដំណាំផ្លែមៀនមានជំនាញសមស្របនឹងបង្កើនការអនុវត្តន៍ និងប្រសិទ្ធភាពសម្រាប់ការលូតលាស់។

## ២.៤. ការបង្កើតផែនការគ្រប់គ្រងស្តុក និងការប្រកួតប្រជែង

- **ការគ្រប់គ្រងស្តុក ៖** អនុវត្តផែនការគ្រប់គ្រងស្តុកដែលមានប្រសិទ្ធភាពដើម្បីកាត់បន្ថយការបាត់បង់ និងការធ្លាក់ចុះតម្លៃស្តុក។ ការគ្រប់គ្រងស្តុកល្អនឹងជួយទប់ស្កាត់បញ្ហាការប្រកួតប្រជែង និងធានាថាមានការចេញផ្សារដោយមានប្រសិទ្ធភាព។
- **ការប្រកួតប្រជែង ៖** វិនិយោគក្នុងការបង្កើតយុទ្ធសាស្ត្រប្រកួតប្រជែងដើម្បីបង្កើនការចំណេញ និងទប់ស្កាត់ការធ្លាក់ចុះតម្លៃផលិតផល។ ការបង្កើតយុទ្ធសាស្ត្រផ្គត់ផ្គង់ផលិតផលដែលមានប្រសិទ្ធភាពអាចជួយត្រួតពិនិត្យតម្លៃ និងធានាការលក់ប្រកបដោយជោគជ័យ។

## ២.៥. ការអភិវឌ្ឍយុទ្ធសាស្ត្រផ្សព្វផ្សាយ និងការអភិវឌ្ឍទីផ្សារ

- **យុទ្ធសាស្ត្រផ្សព្វផ្សាយ ៖** បង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយដើម្បីបង្ហាញផលិតផលនៅក្នុងទីផ្សារថ្មី ការប្រើប្រាស់បច្ចេកវិទ្យាថ្មីដូចជាការផ្សព្វផ្សាយតាមអ៊ីនធឺណិត និងសេវាកម្មផ្សព្វផ្សាយផ្សេងៗដូចជា Facebook, Telegram, TikTok អាចជួយបង្កើនការលក់ និងការបង្ហាញផលិតផល។
- **ការអភិវឌ្ឍទីផ្សារ ៖** សហការជាមួយអ្នកដឹកជញ្ជូន និងអ្នករាយការណ៍ដើម្បីបង្កើតទីផ្សារថ្មី និងបង្កើនការលក់ផលិតផល។ ការបង្កើតភាពសហការនិងការបង្ហាញផលិតផលថ្មីៗអាចជួយបង្កើនតម្លៃនិងជួយការចេញផ្សារចំនួនច្រើន។

# ឯកសារយោង


ក្រសួងរុក្ខាប្រមាញ់ និងនេសាទ (MAFF), សៀវភៅ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣.

ក្រសួងរុក្ខាប្រមាញ់ និងនេសាទ, អគ្គនាយកដ្ឋានកសិកម្ម និងគម្រោង SRECA អនុវត្តដោយអង្គការ GIZ និង BMZ "គោលការណ៍ណែនាំស្តីអំពី ការនាំចេញមៀនប៉ៃលិនពីប្រទេសកម្ពុជាទៅប្រទេសចិន", ឆ្នាំ២០២០, ទំព័រ ២ ដល់ ៤, ទំព័រ ៣០ ដល់ ៣៤)

ក្រសួងរុក្ខាប្រមាញ់ និងនេសាទ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម "សៀវភៅណែនាំស្តីពី បច្ចេកទេសដាំដំណាំមៀនប៉ៃលិន", បោះពុម្ពលើកទី១, ខែមិថុនា ឆ្នាំ២០១៤, ទាញយកពីគេហទំព័រ https://elibrary.maff.gov.kh/book/5b7e200c033a2

រដ្ឋបាលខេត្តបាត់ដំបង. សក្តានុពលវិនិយោគ (២០២២) ដកស្រង់ និងទាញយកពីគេហទំព័រ https://www.battambang.gov.kh/%e1%9e%9c%e1%9e%93%e1%9e%99%e1%9e%82

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ, ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

សារណាបញ្ចប់ការសិក្សា ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា(ឡៃ បូរ៉ាពីន,២០១៧)

សៀវភៅ សេដ្ឋកិច្ចកម្ពុជា មាគ៌ាទៅរកអនាគតភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត (បណ្ឌិត ហង់ ជួន ណារ៉ុន, ឆ្នាំ២០១៥)

ADB. (2023). *Agricultural development and rural poverty in Cambodia*. Asian Development Bank.

Altieri, M. A. (1995). Agroecology: The science of sustainable agriculture. Westview Press.

Altieri, M. A., & Nicholls, C. I. (2021). *Agroecology and regenerative agriculture: Sustainable solutions for hunger, poverty, and climate change*. CRC Press.

Berkes, F., & Folke, C. (1998). *Linking social and ecological systems: Management practices and social mechanisms for building resilience*. Cambridge University Press.

Cambodian Agricultural Research and Development Institute (CARDI). (2021). *Environmental benefits of longan cultivation in Cambodia.*

Cambodian Development Council (CDC). (2022). *Agricultural advancements and economic growth in Cambodia.*

Deere, C. D., & Doss, C. R. (2006). *The gender asset gap: What do we know and why does it matter? Feminist Economics*, 12 (1-2), 1-50.

Diamond, J. (1997). *Guns, germs, and steel: The fates of human societies.* W.W. Norton & Company.

Diao, X., Hazell, P., & Thurlow, J. (2010). *The role of agriculture in African development. World Development*, 38 (10), 1375-1383.

Fanning, S. L. (2008). *The birth of agriculture.* ABC-CLIO.

FAO. (2020). *The state of food and agriculture 2020: Overcoming water challenges in agriculture.*

FAO. (2021). *Food security and nutrition in Cambodia*. Food and Agriculture Organization of the United Nations.

Finberg, H. P. R. (1967). *The agrarian history of England and Wales.* Cambridge University Press.

Food and Agriculture Organization of the United Nations (FAO). (2014). *Modernizing agriculture: A review of successes and challenges.* FAO.

Food and Agriculture Organization of the United Nations (FAO). (2017). *The future of food and agriculture: Trends and challenges.* FAO.

Fresh News. Retrieved from https://freshnewsasia.com/index. php/en/localnews/318363-2023-11-20-05-42-47.html

Fresh News. "ធនាគារ ARDB និង ធនាគារអេស៊ីលីដា សហការអនុវត្តគម្រោងផ្តល់ឥណទាន គាំទ្រដល់ការពង្រីកការដាំដុះ បន្លែ-ផ្លែឈើ ការចិញ្ចឹមសត្វ វារីវប្បកម្ម និងការកែច្នៃផលិតផលកសិកម្ម". Retrieved from https://shorturl.at/DqfBl

IFAD. (2023). *Sustainable farming practices in Cambodia*. International Fund for Agricultural Development.

International Fund for Agricultural Development (IFAD). *Agricultural modernization: Concepts and practices. IFAD.*

Inwood, S., & Sharp, J. S. (2019). *Family farms in the United States: Perspectives on farm succession and retention.* Food, Culture & Society, 22 (3), 351-368.

Kampuchea Thmey. (2023). *Pailin longan export to China in 2023 is booming*. Retrieved from https://www.kampucheathmey.com/local-news/184905

Kampuchea Thmey, retrieved from https://www.kampucheathmey.com/business-economic/758630

Khmer SME. (2023). *Pailin longan exports to China surge in 2023.* Retrieved from https://www.khmersme.gov.kh/en/news/pailin-longan-exports-to-china-surge-in-2023/

Lewis, W. A. (1954). *Economic development with unlimited supplies of labour.* The Manchester School, 22 (2), 139-191.

Lowder, S. K., Skoet, J., & Raney, T. (2021). *The number, size, and distribution of farms, smallholder farms, and family farms worldwide.* World Development, 140, 105271.

Marsh, J. (2021, August 18). *The history of agriculture. Environment.co*. Retrieved from https://environment.co/the-history-of-agriculture/

Ministry of Agriculture, Forestry, and Fisheries (MAFF). (2022). *Economic value of Pailin longan*.

Ministry of Commerce. (2023). *Export potential of Pailin longan*.

Ministry of Information. (2023). *Pailin longan yield expected at 110,000 tonnes this year.* Retrieved from https://www.information.gov.kh/articles/53225

Mundlak, Y. (2001). *Production and supply. In B. Gardner & G. Rausser (Eds.), Handbook of agricultural economics* (Vol. 1, pp. 313-372). Elsevier.

Pingali, P. (2007). Agricultural growth and economic development: A view through the globalization lens. Agricultural Economics, 37 (S1), 1-12.

Phnom Penh Post News. (2023). *Kingdom marks inaugural official fresh-longan shipments to China.* Retrieved from https://www.phnompenhpost.com/business/kingdom-marks-inaugural-official-fresh-longan-shipments-china

Ploeg, J. D. (2008). *The new peasantries: Struggles for autonomy and sustainability in an era of empire and globalization.* Earthscan.

Porter, M. E. (1990). *The competitive advantage of nations.* Free Press.

Pretty, J. (2008). *Agricultural sustainability: Concepts, principles, and evidence. Philosophical Transactions of the Royal Society B: Biological Sciences*, 363 (1491), 447-465.

Ricardo, D. (1817). *On the Principles of Political Economy and Taxation. John Murray.*

Rostow, W. W. (1960). *The stages of economic growth: A non-communist manifesto.* Cambridge University Press.

Schultz, T. W. (1964). *Transforming traditional agriculture.* Yale University Press.

Scoones, I. (1998). *Sustainable rural livelihoods: A framework for analysis*. IDS Working Paper 72. Institute of Development Studies.

Sen, A. (1981). *Poverty and famines: An essay on entitlement and deprivation*. Oxford University Press.

Sen, A. (1999). *Development as freedom*. Alfred A. Knopf.

Streeten, P. (1981). *Basic needs: A new perspective on development.* Heinemann Educational Books.

Timmer, C. P. (2009). *A world without agriculture: The structural transformation in historical perspective.* American Enterprise Institute.

World Bank. *Agricultural modernization and the role of the government.*

World Bank. (2022). *Cambodia economic update: Agricultural development*. World Bank.

ឧបសម្ព័ន្ធ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

៣៣៣*៤៤៤

---

## កម្រងសំណួរស្រាវជ្រាវ

### ជាបឋមយើងខ្ញុំ សូមធ្វើការទកិច្ចគោរព និងជម្រាបសួរដល់លោក ហ៊ាប សុភា ដែលជាម្ចាស់ចម្ការ ក្នុងឱកាសថ្ងៃនេះ យើងខ្ញុំសូមការអនុញ្ញាត ដើម្បីសួរនូវសំណួរស្រាវជ្រាវ

កម្រងសំណួរនេះ ត្រូវបានរៀបរៀងឡើងដោយក្រុមយើងខ្ញុំ ដែលជានិស្សិតឆ្នាំទី ៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមប្រធានបទ «**ដំណើរការនៃការអភិវឌ្ឍដំណាំកសិកម្មដំណាំមៀន ប៉ៃលិន (តាង៉ែង) នៅក្នុងខេត្តបាត់ដំបងករណីសិក្សាចម្ការ លោក ហ៊ាប សុភា**» ក្នុងគោលបំណងសិក្សាស្វែងយល់ អំពីរបៀបនៃការដាំដុះ ការគ្រប់គ្រង បញ្ហាប្រឈម ដំណោះស្រាយ និងផលចំណេញ ដែលទទួលបានពីការដាំដុះដំណាំមៀនប៉ៃលិន។ យើងខ្ញុំសន្យាថា នឹងប្រើប្រាស់ព័ត៌មានដែលទទួលបានឲ្យបានត្រឹមត្រូវក្នុង បរិបទនៃការសិក្សា និងរក្សានូវការសំងាត់ជូនម្ចាស់ចម្ការលោកហ៊ាប សុភា។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ហ៊ាប សុភា ក្នុងការចំណាយពេលវេលាដល់មានតម្លៃដើម្បីផ្តល់កិច្ចសម្ភាសន៍ និង បទពិសោធន៍ល្អៗដល់ក្រុមយើងខ្ញុំ។

១. ឈ្មោះ........................ ២. អាយុ........................ ៣. ផ្ទៃដី ឬ ទំហំចម្ការ........................

៤. ទំហំចម្ការ..........................................................................................................................

៥.ចំនួនមៀនប៉ៃលិននាពេលបច្ចុប្បន្ន.................................................................................................

៦.សូមលោកពូរៀបរាប់ពីស្ថានទូទៅនៅចម្ការនេះបានទេ?...................................................................

៧.សូមលោកពូរៀបរាប់ពីប្រវត្តិនៃការដាំដំណាំមៀនប៉ៃលិន?..............................................................

៨. តើមូលហេតុអ្វីដែលបណ្តាលឱ្យលោកពូមានបំណងបង្កើតចម្ការនេះឡើង?..........................................

..........................................................................................................................................

៩. សូមលោកពូអធិប្បាយពីដំណើរការនៃការដាំដំណាំមៀនប៉ៃលិន?....................................................

.......................................................................................................................................................

១០. តើមានបញ្ហាប្រឈមអ្វីខ្លះដែលលោកពូធ្លាប់ជួបប្រទះកន្លងមក នៅក្នុងដំណើរការនៃការដាំដំណាំមៀនប៉ៃលិននេះ?......................................................................................................................

.......................................................................................................................................................

១១. ក្នុងបញ្ហាដែលលោកពូជួបប្រទះខាងលើ តើលោកពូដោះស្រាយយ៉ាងដូចម្ដេចខ្លះដែរ?.........................

.......................................................................................................................................................

១២. តើលោកពូមានសំណូមពរអ្វីខ្លះ សម្រាប់ជាដំណោះស្រាយចំពោះបញ្ហាដែលលោកពូបានជួបប្រទះ? ......

.......................................................................................................................................................

១៣. តើមៀនប៉ៃលិនអាចលក់បានតម្លៃប៉ុន្មានក្នុងមួយឆ្នាំៗ?..................................................................

.......................................................................................................................................................

១៣. តើលោកពូទទួលបានប្រាក់ចំណូលប៉ុន្មានក្នុងមួយឆ្នាំៗ? ..............................................................

.......................................................................................................................................................

១៤. តើលោកពូចំណាយអស់ប៉ុន្មានក្នុងមួយឆ្នាំទៅលើការដាំដំណាំមៀនប៉ៃលិននេះ? ...............................

.......................................................................................................................................................

១៥. ទិន្នផលដែលទទួលបាន តើលោកពូយកទៅលក់នៅទីផ្សារណាខ្លះ?.................................................

.......................................................................................................................................................

.......................................................................................................................................................

១៦. តើមានការប្រកួតប្រជែងខ្លាំងឬទេ? តើអ្នកណាជាដៃគូប្រកួតប្រជែងរបស់លោកពូ? .............................

.......................................................................................................................................................

.......................................................................................................................................................

សូមអរគុណ!

ឧបសម្ព័ន្ធទី ៥: រូបភាពនៅក្នុងចម្ការមៀនប៉ៃលិន




ឧបសម្ព័ន្ធទី ៦: រូបភាពជាមួយនឹងម្ចាស់ចម្ការ លោក ហ៊ាប សុភា




ឧបសម្ព័ន្ធទី ៧: កិច្ចសម្ភាសន៍ជាមួយនឹងម្ចាស់ចម្ការ លោក ហ៊ាប សុភា




ឧបសម្ព័ន្ធទី ៨: ផ្នែកផ្សេងៗនៃដំណាំមៀនប៉ៃលិន









ឧបសម្ព័ន្ធទី ៩: ប្រភពទឹករបស់ចម្ការ លោក ហ៊ាប សុភា









ឧបសម្ព័ន្ធទី ១០: ជី និងថ្នាំសម្រាប់ដំណាំមៀនប៉ៃលិន












## ឧបសម្ព័ន្ធទី ១១: រូបភាពសត្វល្អិតដែលបំផ្លាញដំណាំមៀនប៉ៃលិន




រូបភាពសត្វមមាច



រូបភាពសត្វដង្កូវ

## ឧបសម្ព័ន្ធទី ១២: រូបភាពម៉ាស៊ីនបូមទឹករបស់ចម្ការ



ឧបសម្ព័ន្ធទី ១៣: រូបភាពពេលប្រមូលផលមៀនប៉ៃលិន







